# ជីវិតលោកឪពុក



រៀបរៀងដោយ

យុវសមណ គង់ ច័ន្ទសុភ័ក្រ

ផ្សាយចេញពីក្រុមយុវសមណអ្នកនិពន្ធ

www.elibraryofcambodia.org

ជាអំណោយពីលោក ខៀវ ឃុនសំរៀង ដល់ក្រុមការងារ
ដើម្បីរក្សាទុកក្នុង eLibrary of Cambodia
កញ្ញា 2015

# ជីវិតលោកឪពុក



រៀបរៀងដោយ

យុវសមណ **គង់ ច័ន្ទសុភ័ក្រ**

ផ្សាយចេញពីក្រុមយុវសមណអ្នកនិពន្ធ

www.elibraryofcambodia.org

www.elibraryofcambodia.org

- ឈ្មោះសៀវភៅ : **ជីវិតលោកឪពុក**
- រៀបរៀងដោយ : និក្ខុឧបតិស្សោ **គង់ ច័ន្ទសុភ័ក្រ**
- រចនាក្របដោយ : សាមណេរ **ឆិម ប៊ុនឆា**
- ពិនិត្យដោយ : សាមណេរ **សា ចាន់រ៉ាត់** លោកគ្រូ **មូ ស៊ីថូ**
- ទីកន្លែងធ្វើ : វត្ត **ស៊ិនជិមធម្មនិមិត្ត** (ស្រែ ១០០) ឃុំស្លាកែត ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៃព្រះរាជាណាចក្រកម្ពុជា។
- កាលបរិច្ឆេទធ្វើចប់ : ថ្ងៃ ១៥ កើត ខែអស្សុជ ឆ្នាំរោង ត្រីស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១២។
- ការផ្សាយរបស់ : ក្រុមយុវសមណអ្នកនិពន្ធ (ខេត្តបាត់ដំបង)
- រក្សាសិទ្ធិដោយ : វិទ្យាស្ថានសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា
- ឈ្មោះរោងពុម្ព : **ម៉ៅ ផុន**
- បោះពុម្ពលើកទី ១ : ចំនួន ២.០០០ ក្បាល
- អស់ទឹកប្រាក់ចំនួន : ៤.៤០០.០០០៛
- ចែកផ្សាយក្នុង : ឱកាសបុណ្យកឋិនទាន និងចែកសៀវភៅ
- ផ្ដល់មតិយោបល់ : ០១២ ៤០៥ ៩៩០.០៨៨ ៩៧ ២២២ ៦៦



www.elibraryofcambodia.org

# សេចក្តីជូនដំណឹង

ដោយវិរិយភាព ប្រកបជាមួយឆន្ទៈដ៏មោះមុត និងសេចក្តីប្រឹងប្រែង ការស្រឡាញ់ពេញចិត្តរបស់ខ្ញុំ ក្នុងការសរសេរ ខ្ញុំបានត្រៀមរៀបចំសៀវភៅ ក្នុងការរៀបរៀងបន្ថែមទៀត នៅក្នុងក្រុមយុវសមណអ្នកនិពន្ធ ដែលត្រៀម នឹងចេញផ្សាយជាធម្មទានក្នុងពេលឆាប់ៗនេះ មានចំណងជើងដូចខាងក្រោមៈ

| | |
|---|---|
| **ជីវិតគ្រូចការព្រះធម៌** | (ភិក្ខុ គង់ ច័ន្ទសុភ័ក្រ) |
| **នេះឬសង្សារ** | (ភិក្ខុគង់ ច័ន្ទសុភ័ក្រ) |
| **លួមគ្នាក់ខ្លួនហើយ** | (សាមណេរ សា ចាន់រ៉ាត់) |
| **គង់មានថ្ងៃមួយ** | (សាមណេរ សា ចាន់រ៉ាត់) |
| **ស្នូរសៀងសំនៀងម៉ែ** | (សាមណេរ ឆិម ប៊ុនឆា) |
| **ស្លាដែសមណ** | (សាមណេរ សា ចាន់រ៉ាត់) |
| **ទស្សនអប់រំ** | (សាមណេរ សា ចាន់រ៉ាត់) |

អាស្រ័យហេតុនេះ ប្រសិនបើសប្បុរសជន អស់លោក អ្នកមានបំណងចង់ចូលរួម ឧបត្ថម្ភក្នុងការបោះពុម្ពផ្សព្វផ្សាយ ឬមានបំណងចង់បានសៀវភៅនេះ អាចទាក់ទងតាមរយៈ

Email.www.koung.chansopheak@yahoo.com
facebook.koung chansopheak@yahoo.com
ទូរស័ព្ទ:(៨៥៥)០១២ ៤០ ៥៩ ៩០.០៨៨ ៩៧ ២២២ ៦៦



www.elibraryofcambodia.org

## សៀវភៅដែលក្រុមយុវសមណអ្នកនិពន្ធបានបោះពុម្ពផ្សាយរួចហើយ

| | |
|---|---|
| កម្រងអក្សរ | សាមណេរ សា ចាន់រ៉ាត់ |
| ធំពីរជីវិត | សាមណេរ សា ចាន់រ៉ាត់ |
| វិចារណកំណាព្យ | ភិក្ខុឧបតិស្សោ គង់ ច័ន្ទសុភ័ក្រ |
| តំណក់ទឹកភ្នែក | សាមណេរ ឆិម ប៊ុនឆា |
| ដួងហឫទ័យនៃអ្នកមានគុណ | សាមណេរ ឆិម ប៊ុនឆា |
| ជីវិតកូនពិតជាត្រូវការម៉ែ | ភិក្ខុឧបតិស្សោ គង់ ច័ន្ទសុភ័ក្រ |
| គួរសិក្សាធម៌ | សាមណេរ សា ចាន់រ៉ាត់ |
| ទឹកចិត្តអ្នកម្ដាយ | សាមណេរ សា ចាន់រ៉ាត់ |
| ខ្ញុំតែងជូនអ្នក | សាមណេរ សា ចាន់រ៉ាត់ |
| ដឹងគុណតបគុណ | សាមណេរ ឆិម ប៊ុនឆា |
| កម្រងធម្មការី | សាមណេរ សួន សំឡូត |
| ម៉ែអើយកូនសុំទោស | សាមណេរ ឆិម ប៊ុនឆា |
| បណ្ដាំពុកម៉ែ | សាមណេរ ធី ចាន់ណា |
| មាគ៌ា នៃព្រះធម៌ | សាមណេរ ធី ចាន់ណា |
| តម្រង់ផ្លូវជីវិត | សាមណេរ ឆិម ប៊ុនឆា |
| រស់ក្រោមម្លប់ព្រះធម៌ | ភិក្ខុ ចិន្តកវី ទូច ចន្ថា |



www.elibraryofcambodia.org

## **នាមលោកអ្នកមានឧបការៈក្នុងការចារធម៌ទាន**

-លោកម្ចាស់ភិក្ខុ **ទូច ចន្ថា**
-លោកម្ចាស់ **សា ចាន់រ៉ាត់**
-លោកម្ចាស់ **ចេង សុជា**
-លោកម្ចាស់គ្រូ **ម៉ី ហ្វ** (វត្តរលួស)
-បងប្រុស **រ៉េត សុវណ្ណលក្ខ**
-ឧ.ស.**ទួន គង់**
-ឧ.ស.**ប៊ី ផុន**
-បងប្រុស **ហាច្យ ឃាង**
-បងស្រី **ម៉ក់ ចាន់ធារ៉ា.ស្វាមី**
-ឧ.សិ.**យ៉ាំង សុបិន្ត**
-ឧ.សិ. **គួ ធាវី**
-ឧ.សិ. **កែវ សុគន្ធ**
-ឧ.សិ. **ជុង សុជា**
-ឧ.សិ.**ផាន់ សុវណ្ណ**
-ឧ.សិ.**អៀម អៀ**
-ឧ.សិ.**ម៉ៅ វណ្ណី**
-ឧ.សិ.**ឡេង ប៊ុនស្រេង**.ភរិយា
-ឧ.សិ.**អ៊ឹម អ៊ុម**.កូន
-ឧ.សិ.**ឈុន សុខា**.កូន

-លោកម្ចាស់ភិក្ខុ **សំ ស៊ីណាង**
-លោកម្ចាស់ **ធិម ប៊ុនធា**
-លោកម្ចាស់ភិក្ខុ **អន សំអុល**
-លោកម្ចាស់ **ធី ចាន់ណា**
-ឧ.សិ.**កែវ វណ្ណា**
-ឧ.សិ.**ហ្វត សុខេង**
-ឧ.សិ.**ស៊ាន សុវណ្ណៈ**
-បងប្រុស**ចាន់ ទូច** និងភរិយា
-បងប្រុស **ម៉ៅ មុនី** និងភរិយា
-ឧ.សិ.**សំ សានី**ព្រមទាំងបុត្រ
-ឧ.សិ. **ឈឹម វណ្ណៈ** និងបងប្អូន
-ឧ.សិ. **ណាក់ ណាស់**(U.S.A)
-ឧ.សិ. **មុំ ស្រីទូច និងស្វាមី**
-ឧ.សិ. **ឆាន គឹមឃី**.កូនចៅ
-ឧ.សិ. **គឹម ធឿម**.កូន
-ឧ.សិ .**ចេង គាង**.កូនចៅ
-ឧ.សិ **ណែម ជុំ**
-ឧ.សិ.**សៅរ៍ នី**.កូន
-ឧ.សិ.**ទ្រី**.កូនចៅ



www.elibraryofcambodia.org

-ឧ.សិ.**សរ យឿង**

-ឧ.សិ.**ឌី សួរ**

-ឧ.សិ.**អ៊ឹង មួយ**.កូនចៅ

-ឧ.សិ.**ថន សុវណ្ណៈ**.កូន

-ឧ.សិ.**យាង ស៊ីផល**.កូន

-ឧ.សិ.**យាង ស៊ីផាត**.ស្វាមី.បុត្រ

-ឧ.សិ.**ហ៊ាន់ ម៉េងហ៊ាន**.កូនចៅ

-ទាយិកា **យី មូច័ន្ទ**

-ឧ.សិ.**សំ រី**.កូនចៅ

-ឧ.សិ.**ខែត ទិប៊ុល**.កូនចៅ

-ឧ.សិ.**រឿង យឿង**

-ឧ.ស.**ស៊ឹម កុយ.ឆម ឈួយ**

-ឧ.សិ.**ឈុន ហ៊ាង**.កូនចៅ

-ឧ.សិ .**រស់ សារ៉េត**.កូន

-ឧ.សិ .**យាង ស៊ីផាន**.ស្វាមី.បុត្រ

-ឧ.សិ.**យាង ស៊ីផូ**.ស្វាមី.បុត្រ

-ឧ.សិ.**តាន់ គីមគ្រុយ**.ស្វាមី.កូន

-ឧ.ស.**ហោ ផល្លី**.ភរិយា.កូន

-ឧ.សិ. **សេត សឿន**.កូនចៅ

-ឧ.សិ.**សោម ណាត**

-មិត្តធម៌ក្នុងខេត្តបាត់ដំបង.កំពង់ចាម.បន្ទាយមានជ័យ.ប៉ៃលិន...



www.elibraryofcambodia.org

# វាចាបេះដូងរបស់អ្នកនិពន្ធ

ជំនោរត្រជាក់ធ្លាក់ពេលរាត្រីកាល ដ៏សែនស្ងាត់ជ្រងំលោយឡំ ជាមួយនឹងសំឡេងខ្យល់បក់បោករំភើយៗ នាកណ្តាលអធ្រាត្រ ឆ្លៀតផ្តើមសរសេរអក្សរ រៀបរាប់អំពីរឿងរ៉ាវជីវិតរបស់លោកឪពុក ដែលលោកបានធ្វើពលិកម្មដ៏ធំធេង ចំពោះកូនប្រុសស្រី ។

ពុក តស៊ូប្តូរផ្តាច់គ្រប់បញ្ហា ទាំងកម្លាំងកាយចិត្ត ផ្តិតរឿងរ៉ាវជូរចត់អត់ឃ្លាន ក្នុងការរស់នៅប្រចាំថ្ងៃដ៏សែនលំបាក ក្នុងមួយឆាកជីវិតរបស់លោកឪពុក ដែលខំប្រឹងធ្វើការងារ ដើម្បីកូនមិនថាក្តៅរងាភ្លៀងផ្គរនោះទេ ពុកព្យាយាមតស៊ូពុះពារឆ្លងកាត់គ្រប់ឧបសគ្គ ដែលប្រុងនឹងកើតមានឡើង ចំពោះខ្សែនៃជីវិតទៅថ្ងៃមុខ មិនដឹងជាត្រូវជួបនូវឧបសគ្គ ឬបញ្ហាអ្វីខ្លះនោះទេ។

រសជាតិជីវិត គិតទៅមានគ្រប់រសជាតិទាំងអស់ ត្រូវកើតឡើងចំពោះជីវិត សប្បាយក្លាយទៅជាទុក្ខ ស្រណុកគូវេទនា។

នៅក្នុងយុគសម័យ នាពេលបច្ចុប្បន្ននេះ កូនបានវិវត្តខ្លួនទៅតាមសម័យកាល ភ្លេចថ្នាលជីវិត ភ្លេចកំណើតរបស់ខ្លួន



www.elibraryofcambodia.org

បិទពួនដោយវប្បធម៌គេ ចេះដើរលេងសប្បាយ ស៊ីចាយផឹកស្រាដល់យប់អធ្រាត្រ មិនស្តាប់មេបា សេពគប់មិត្តភក្តិ បងតូចបងធំ មានគំនុំគុំកួនពេញខ្លួន អាងកាប់អាងចាក់ អាចកម្លាំងបាយដោះស្រាយបញ្ហា ប្រើហិង្សាបង្អួតកម្លាំងគ្នា សុទ្ធសឹងតែជាអ្នកខ្លាំងគ្មាននរណាម្នាក់ខ្សោយទ្បើយ ទីបំផុតបានត្រឹមតែបំពេញនូវសេចក្តីទុក្ខ ឱ្យឪពុកម្តាយតែប៉ុណ្ណោះ អ្នកចាញ់ដេកជាទុក្ខ អ្នកឈ្នះរមែងបាននូវពៀរ ឬសមដូចពាក្យមួយឃ្លាទៀតថាអ្នកចាញ់ចូលពេទ្យ អ្នកឈ្នះចូលគុក នេះហើយគឺជាលទ្ធ-ផល ដែលនឹងទទួលបាន។

ហេតុដូច្នេះហើយ បានជាខ្ញុំលើកយក នូវរឿងរ៉ាវនៃខ្សែជីវិតរបស់លោកឪពុក ដែលត្រូវកូនប្រុសស្រីធ្វើបាប ទាំងផ្លូវកាយទាំងផ្លូវចិត្ត អាណិតស្រណោះ ដល់លោកឪពុកគ្រប់រូបមិនថាឪពុកគេ ឬឪពុកខ្ញុំនោះទេ គឺកូនមិនគិតទៅដល់ដួងចិត្តរបស់លោនោះទេ ថាពុកត្រូវជួបប្រទះនូវការលំបាកអ្វីខ្លះទៅ? តើកូនគ្រប់គ្នាដែលបានសួរឪពុកខ្លះទេ ថាតើ ពុកទៅធ្វើការរកលុយ ជារៀងរាល់ថ្ងៃហ្នឹង តើពុកមានការលំបាកដែរឬទេ? តើយើងជាកូនៗដែលធ្លាប់បានសួរទេ? កូនៗគ្រប់គ្នាមិនដែលបាន



www.elibraryofcambodia.org

សួរគាត់សោះឡើយ ទោះបីជាពុក ត្រូវទទួលរងនូវការលំបាកយ៉ាកយ៉ាប់យ៉ាងណាក៏ដោយ ក៏ពុកតស៊ូលំបាកតែម្នាក់ឯង មិនឱ្យកូនៗដឹងឡើយ តែថ្ងៃខ្លះពុកលំបាកពេក ពុកស្រក់ទឹកភ្នែកតែម្នាក់ឯង គឺព្រោះដើម្បីកូន ចេះតែទ្រាំទៅ។

បានឃើញ នូវទិដ្ឋភាពដ៏ជាក់ស្តែង ដែលលោកឪពុកគ្រប់រូបមានភាពក្លាហានទទួលខុសត្រូវ ដែលបានលះបង់ទាំងពេលវេលា ទាំងកម្លាំងកាយចិត្ត ទាំងអាយុជីវិតរបស់គាត់ ដើម្បីកូន តើមានកូនប៉ុន្មាននាក់បានមើលឃើញនូវទុក្ខលំបាករបស់ពុក? ឬមួយមើលឃើញតែលុយរបស់គាត់ទេ? ប្រហែលជាអ៊ីចឹងហើយ មើលទៅ។

បាត់ដំបង ថ្ងៃ ១៥ កើត ខែអស្សុជ ឆ្នាំ រោង ព.ស.២៥៥៦

ដោយភិក្ខុ ឧបតិស្សោ គង់ ច័ន្ទសុភ័ក្រ



www.elibraryofcambodia.org

# ប្រវត្តិរូបសង្ខេប

ខ្ញុំព្រះករុណា អាត្មាភាពព្រះនាម ឧបតិស្សោ គង់ ច័ន្ទសុភ័ក្រ កើតនៅថ្ងៃពុធ ទី ០៩ ខែមករា ឆ្នាំ(រោង)១៩៨៨ វេលាម៉ោង ៤ ទៀបភ្លឺ ស្ថិតក្នុងភូមិវាលធ្នុង ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។ ជាកូនរបស់លោកឪពុក នួន គង់ និងអ្នកម្តាយ ហួត សុខេង មានបងប្អូនចំនួន ៤ នាក់ ប្រុស ២ ស្រី២ ជាកូនទី ៤ នៅក្នុងគ្រួសារ(កូនពៅ)។

អាយុ៧ឆ្នាំបានចូលសិក្សា នៅសាលាបឋមសិក្សាវាលធ្នុង ថ្នាក់ទី ១ ជាមួយនឹងលោកគ្រូ ញ៉ វ៉យវិវត្តបានអាយុ ៨ ឆ្នាំ បានរៀនថ្នាក់ទី ២ ជាមួយនឹងអ្នកគ្រូធី អាយុ ៩ ឆ្នាំបានទៅស្នាក់នៅក្នុងវត្តស្ទឹងក្តី លុះអាយុបាន ១២ ឆ្នាំ លោកឪពុកអ្នកម្តាយ បានបញ្ជូនឱ្យទៅស្នាក់ នៅក្នុងវត្តមង្គលសិលារាមរលួសមាស បានចូលសិក្សាបន្ត ជាមួយនឹងលោកគ្រូ យាង សុខរី ថ្នាក់ទី៥ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ព្រះគ្រូចៅអធិការវត្តរលួស ព្រះនាម ម៉ុ ហួរ។

នៅចុងឆ្នាំ ២០០០ លោកគ្រូបានបំបួស ជាសាមណេរក្នុងព្រះជន្មាយុ ១៥ វស្សា ក្នុងឆ្នាំ ២០០៩ បានបំពេញ



www.elibraryofcambodia.org

ឧបសម្បទា។ ក្នុងឆ្នាំ ២០១១ បានប្រឡងជាប់ វិញ្ញាបនបត្រទុតិយភូមិបាក់ឌុប រហូតមកដល់ឆ្នាំ ២០១២ ឈានចូលឆ្នាំ ២០១៣ ចូលបួសក្នុងសំណាក់ព្រះពុទ្ធសាសនា បាន ១២ ព្រះវស្សា ហើយនាពេលបច្ចុប្បន្ននេះ បានកំពុងបន្តការសិក្សានៅសាកលវិទ្យាល័យបៀលប្រាយ(BBU) សាខាខេត្តបាត់ដំបង ស្នាក់នៅក្នុងវត្ត ស៊ិនជិមធម៌និមិត្ត (ស្រែ១០០) ក្នុងព្រះជន្មាយុ ២៥ វស្សា។



www.elibraryofcambodia.org

# មាតិកា


លរ ឈ្មោះអត្ថបទ លេខទំព័រ

១.ជីវិតលោកឪពុក ............................................ ១

២.ពុកធ្វើគ្រប់យ៉ាងដើម្បីកូន ................................ ៨

៣.ដើម្បីកូនស៊ូសូន្យសង្ខារ .................................... ១៥

៤.ពុករស់ព្រោះដើម្បីកូន ...................................... ២៣

៥.ទឹកភ្នែកឪពុកជាជនពិការ ................................ ២៧

៦.សែនអនិច្ចាវាសនាឪពុកចាស់ ............................ ៣១

៧.ទឹកភ្នែកប្រពន្ធដើម ........................................ ៣៨

៨.ជីវិតម៉ែវាសនាកូន .......................................... ៤០

៩.វាសនាអភ័ព្វ ................................................ ៤៥

១០.អាក្រក់ឬល្អក៏កូននៅតែជាកូនរបស់ពុក .............. ៥០

១១.សប្បាយក្លាយជាទុក្ខ ...................................... ៥៧

១២.ពុកម៉ែស្រក់ទឹកភ្នែកដោយសារកូន .................. ៥៩

១៣.ពុកម៉ែនៅរស់កូនឈ្លោះដណ្តើមកេរ្តិ៍ .................. ៦៨

១៤.ពុកសែនឈឺចិត្ត .......................................... ៧៣

១៥.ខំអើយសែនខំៗដើម្បីកូន ................................ ៧៧




www.elibraryofcambodia.org

១៦.សំឡេងព្រះធម៌ ............................................ ៧៩
១៧.បើចង់ម្ដេចក៏មិនធ្វើ ........................................ ៨១
១៨.ចូលឆ្នាំថ្មីហើយ .............................................. ៨៣
១៩.អំណាចនៃលុយ ............................................ ៨៥
២០.សេចក្ដីល្អជាលម្អនៃជីវិត ................................... ៨៨
២១.ខំយកទៅណា? ............................................. ៩០
២២.ខ្មែរនៅឯណា? ............................................. ៩១
២៣.ចំណង់ចងមិនចេះចប់ ....................................... ៩៤
២៤.ជីវិតគ្រប់គ្នា ................................................... ៩៥
២៥.កូនមាសឪពុក ................................................ ៩៦
២៦.ត្រៃលក្ខណ៍ធម៌ ................................................. ៩៨
២៧.លាមួយរយៈ .................................................. ១០១
២៨.ស្គាល់រូបស្គាល់រាងតែមិនស្គាល់ចិត្ត .......................... ១០៤
២៩.តើកូនចាំទេ? ................................................ ១០៦
៣០.ទឹកចិត្តលោកគ្រូ ............................................ ១០៩



www.elibraryofcambodia.org

# ១.ជីវិតលោកឪពុក

អ្វីៗគ្រប់យ៉ាង ដែលយើងឃើញផ្ទាល់នឹងភ្នែក ឮផ្ទាល់ នឹងត្រចៀក យើងគ្រប់គ្នាតែងតែគិតថា វាហាក់បីដូចជាងាយស្រួលសម្រាប់យើងគិត ប៉ុន្តែសម្រាប់យើងធ្វើ ឬយើងប្រព្រឹត្តវិញនោះ អ្វីៗទាំងអស់ គឺមិនងាយស្រួលដូចអ្វីដែល យើងគិតនោះទេ ការគិតវាងាយស្រួលជាជាងការធ្វើ។

ដូចជារឿង ចង់ជ្រើសរើសគូស្រករ រៀបចំជីវិតបង្កើតគ្រួសារមួយ មានភរិយាមានស្វាមី និងការគ្រប់គ្រងគ្រួសារនោះ ការរៀបចំបង្កើតគ្រួសារមួយ វាមិនលំបាកនោះទេ តែការគ្រប់គ្រងគ្រួសារ ឱ្យមានសុភមង្គលទើបជារឿងលំបាក យ៉ាកយ៉ាប់យ៉ាងពិតប្រាកដ ហើយក៏មាន រយៈពេលដ៏យូរអង្វែងផងដែរ គឺយ៉ាប់រហូតអស់មួយជីវិត ដំណើរជីវិតបែបណា ត្រូវដើរបែបនោះ មិនអាចកែប្រែមិនអាច បន្ទោសអ្នកណាម្នាក់បានឡើយ



www.elibraryofcambodia.org

ព្រោះយើងជាអ្នកជ្រើសរើស ហើយយើងក៏ជាអ្នកសម្រេចចិត្ត ដោយខ្លួនឯង ។

ដូចមានពាក្យគេលើកឡើងថា ធ្វើស្រែខុសមួយឆ្នាំត្រូវមួយឆ្នាំ បើខុសឆ្នាំនេះ អាចធ្វើឆ្នាំក្រោយសាជាថ្មីបានវិញ ព្រោះថាធ្វើស្រែរំពឹងទឹកភ្លៀង ប្រវាស់ជាមួយនឹងមេឃ បើមេឃភ្លៀងភោគផលដំណាំក៏បានផល តែបើមេឃមិនភ្លៀង ផលដំណាំក៏មិនបានផ្លែផ្កាអ្វីដែរ។

ប៉ុន្តែ រឿងរៀបចំអនាគតជីវិតវិញនោះ បើរើសគូស្រករឬប្រពន្ធប្ដីវិញនោះ បើខុសតែម្តងហើយ គឺពិតជាខុសអស់មួយជីវិត ហើយគ្មាននរណា អាចជួយនរណាបានឡើយ។

ហេតុដូច្នេះហើយ បានជាពេលនេះ ខ្ញុំលើកយក នូវរឿងរ៉ាវខ្លះៗ ដែលទាក់ទងទៅនឹង ជីវិតរបស់លោកឪពុក មកសរសេររៀបរាប់រ៉ាយរ៉ាប់ ប្រាប់ដល់អ្នកគ្រប់គ្នា ឱ្យបានអានគ្រាន់នឹងបានពិចារណាសិក្សាឱ្យបានដឹង នូវអត្ថន័យសេចក្តី



www.elibraryofcambodia.org

ខ្លឹមសារ នៃខ្សែជីវិតរបស់លោកឪពុក ឱ្យបានដឹងកាន់តែច្បាស់ ថា ពាក្យថាឪពុក គឺជាពាក្យមួយម៉ាត់ ដែលក្នុងនាមយើង ជាកូនៗគ្រប់គ្នា តែងតែហៅមិនដាច់ពីមាត់ អ្នកខ្លះហៅថា ពុក អ្នកខ្លះហៅថា ប៉ា ហើយអ្នកខ្លះទៀតក៏ហៅថា ឪ មានតែពាក្យ ថា ពុកនេះទេ ដែលអ្នកម្តាយគ្រប់រូប តែងតែបង្គាប់ឬបង្ហាត់ ឱ្យកូនរៀនហៅ ឬបង្រៀនកូនឱ្យចេះហៅ ពាក្យដែលកូនខ្មែរ គ្រប់រូបចេះនិយាយ ឬចេះថាមុនគេទាំងមិនច្បាស់ផងនោះ គឺជា ពាក្យពុកពាក្យម៉ែនេះឯង ដែលកូនខ្មែរចេះហៅមុនគេបង្អស់ ហើយក៏ដក់ជាប់នៅក្នុងចិត្ត ឬក្នុងបេះដូងរបស់កូនៗគ្រប់គ្នា ដែលមិនអាចបំភ្លេចបាន។

ហើយពាក្យថា ពុកនេះដែរ គឺជាពាក្យ ដ៏ពេញនិយមច្រើន ជាងគេ ដែលកូនហៅហើយ មិនចេះធុញណាយ ហើយក៏មិន ហួសសម័យកាលដែរ សម័យណាក៏គេហៅដែរ គឺគ្រប់សម័យ កាល ណាៗទាំងអស់ មិនថាសម័យកាលនេះ ឬសម័យកាល



www.elibraryofcambodia.org

មុនៗនោះទេ គឺគេហៅដូចគ្នា ហៅពេញៗមាត់គ្រប់រូបគ្រប់គ្នា ហៅហើយចង់ហៅទៀត ហៅដោយរីករាយ ហៅដោយពេញចិត្តគឺជាពាក្យ ដ៏ពីរោះរណ្ដំលាយឡំ ទៅដោយការអាណិត និងសេចក្ដីស្រឡាញ់ ចេញពីដួងចិត្តចេញពីបេះដូងរបស់ឪពុក ដែល មានចំពោះកូនៗ។

ប៉ុន្ដែ យើងជាកូនៗគ្រប់គ្នា គឺមិនបានយល់ដឹង នូវខ្សែជីវិតរបស់លោកឪពុក ថាតើជីវិតរបស់លោកឪពុក ត្រូវជួបប្រទះនូវរឿងរ៉ាវអ្វីខ្លះ? ក្នុងមួយឆាកជីវិតរបស់គាត់ តើបានឆ្លងកាត់នូវបញ្ហា ឬឧបសគ្គអ្វីខ្លះ? តើគាត់ត្រូវធ្វើអ្វីខ្លះ?

ពុក ត្រូវទទួលខុសត្រូវ នៅក្នុងគ្រួសារទាំងមូល ពុកត្រូវចិញ្ចឹមកូន និងភរិយា ត្រូវធ្វើការងារស្វែងរកទ្រព្យសម្បត្តិ ដើម្បីយកមក ទុកផ្គត់ផ្គង់នៅក្នុងគ្រួសារជារៀងរាល់ថ្ងៃ ពុកត្រូវបញ្ជូនកូនឱ្យបានរៀនសូត្រ តាំងពីថ្នាក់មតេយ្យរហូតដល់ថ្នាក់ខ្ពស់ មានចំណេះដឹងខ្ពង់ខ្ពស់ អាចរស់ទីពឹងខ្លួនឯងបាន នៅថ្ងៃ



www.elibraryofcambodia.org

ក្រោយ ពុកត្រូវខិតខំខ្នះខ្នែង ប្រឹងប្រែងស្វែងរកអនាគត ឱ្យកូន ទោះបី ជាពុកត្រូវលំបាកយ៉ាកយ៉ាប់ ធ្វើការនឿយហត់យ៉ាង ណាក៏ដោយ ដើម្បីកូន ពុកធ្វើទាំងអស់ ពុកធ្វើគ្រប់យ៉ាងមិនរួញ រាមិនរាថយឡើយ នេះហើយគឺជាទឹកចិត្តពិតរបស់ពុក ដែល មានចំពោះកូន គឺជាភារៈដ៏ធ្ងន់ណាស់សម្រាប់ពុកផងដែរ ពុក ខ្លះមានមុខរបរជាថៅកែក្រុមហ៊ុន ខ្លះជាគ្រូពេទ្យ ខ្លះជាគ្រូ បង្រៀន ខ្លះជាអាជីវករ ខ្លះជាកសិករ ខ្លះជាកម្មករសំណង់ ខ្លះជាអ្នករត់ម៉ូតូឌុប ខ្លះជាអ្នកសុំទាន ខ្លះជាអ្នកបម្រើគេ ខ្លះជា អ្នកនេសាទ ខ្លះជាអ្នកប្រមាញ់បរបាញ់សម្លាប់សត្វ ដោយ គ្មានញញើតដៃទាំងតូចទាំងធំ ខ្លះជាអ្នកលក់សៀសហាល ខ្លះជាអ្នករើសអេតចាយ ខ្លះជាកម្មករឆ្លងដែន ទាំងអស់នេះ គឺជាការងាររបស់លោកឪពុក គឺជាភារៈរបស់លោកឪពុក អ្វីក៏ ពុកធ្វើដែរឱ្យតែបានប្រាក់ ដើម្បីយកមកចិញ្ចឹមកូន ពុកមិនដែល



www.elibraryofcambodia.org

រើសអើងថាការងារនោះ ជាការងារថោកទាប ត្រូវគេមើលងាយមើលថោកក៏ដោយ ក៏ពុកធ្វើដែរព្រោះដើម្បីកូន។

ពុកខំធ្វើការដើម្បីលុយ ពុកហ៊ានប្រថុយដើម្បីប្រាក់
ពុកខំលីសែងញើសស្រោក់ ពុករកទុកដាក់ចិញ្ចឹមកូន។
ពុកខំពុករកទាំងយប់ថ្ងៃ ពុកខំសំចៃទុកឱ្យស្ងួន
ពុកនឿយម្ដេចម្ដាបិទមាត់ស្ងួន្យ ពុកស្ទើរស្លាប់ខ្លួនក៏មិនស្ដី។
ពុកខំរាល់ថ្ងៃគ្មានទំនេរ ពុកស៊ីឈ្នួលគេទិញចំណី
ពុកធ្វើសំណង់ខំរែកដី ពុកធ្វើអ្វីៗឱ្យកូនឆ្អែត។
ពុករកប៉ុន្មានបានផ្គត់ផ្គង់ ពុករៀបបម្រុងទុកថ្ងៃស្អែក
ពុកចិញ្ចឹមកូនទាំងទឹកភ្នែក ពុកខំពុនរែកតែម្នាក់ឯង។
ពុកខំស្វះស្វែងក្រែងវេទនា ពុកធ្វើការងារក្រោមសូរ្យសែង
ពុកខំពុនរែកថ្ងៃក្ដៅហែង ពុកខំប្រឹងប្រែងរកទ្រព្យា។
ពុកខំពីក្មេងរហូតចាស់ ពុកនឿយហត់ណាស់កូនពុំងា
ពុកគ្មានកម្លាំងព្រោះគ្រាំគ្រា ពុកគ្មានវេលាមើលថែកូន។



www.elibraryofcambodia.org

ពុកមានភារៈត្រូវរ៉ាប់រង ពុកជាបង្គងសម្រាប់សួន
ពុកសែនលំបាកទុក្ខផ្ទួនៗ ពុកស៊ូយកខ្លួនការពារថ្លៃ។
ពុកយកកម្លាំងធ្វើដើមទុន ពុកធ្វើការធ្ងន់រៀងរាល់ថ្ងៃ
ពុកឈឺទាំងអស់សព្វសរសៃ ពុកឈឺស្មើរក្បួយពេញរាងកាយ។
ពុកខំបំពេញសព្វកិច្ចការ ពុកឈឺម្តេចម្តាចិត្តខ្វល់ខ្វាយ
ពុកនៅមិនសុខពេលឃ្លាតឆ្ងាយ ពុកដើរសុំបាយឱ្យកូនហូប។
ពុកហ៊ានសម្លាប់សត្វបក្សី ពុកនេសាទត្រីយកធ្វើម្ហូប
ពុកអាណិតកូនគ្មានអ្វីហូប ពុកយកបាយស្រូបទឹកអំបិល។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

## ២.ពុកធ្វើគ្រប់យ៉ាងដើម្បីកូន

ពន្លឺរស្មីនៃព្រះអាទិត្យ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ភពផែនដីទាំងមូលនេះ ដែលមានមនុស្សសត្វ រុក្ខជាតិព្រៃព្រឹក្សាទាំងឡាយ កំពុងរស់នៅ។

ពេលណាដែលព្រះអាទិត្យរះឡើង ចរចេញយាត្រាបន្តិចម្តងៗព្រៀងៗបញ្ចេញពន្លឺរស្មីច្បាស់ ត្រចះត្រចង់ ពណ៌ក្រហមឆ្អិនឆ្អៅ មូលក្រឡង់លើផ្ទៃនៃអាកាស ពពកទាំងឡាយបានរសាត់ជាត់ទៅតាមខ្យល់ ធ្វើឱ្យពិភពលោកទាំងមូល មានរុក្ខជាតិតូចធំ មានពណ៌ស្រស់បំព្រងខៀវស្រងាត់ ដោយសារពន្លឺនៃរស្មីព្រះអាទិត្យ។

ចំណែក ឯមនុស្សម្នាទាំងឡាយ ក៏ធ្វើដំណើរចាកចេញពីផ្ទះសំបែងរៀងៗខ្លួន ដើម្បីទៅប្រកបមុខរបរ ទៅតាមមុខងារនិង តួនាទីរបស់ខ្លួន ដើម្បីស្វែងរកប្រាក់កម្រៃ យកមកចិញ្ចឹមជីវិត និងចិញ្ចឹមគ្រួសារ មានប្រពន្ធកូនជាដើម ទៅតាមកម្លាំង



www.elibraryofcambodia.org

របស់ខ្លួន ជាមេគ្រួសារ ឬជាអ្នកទទួលខុសត្រូវ នៅក្នុងក្រុមគ្រួសារទាំងមូលនោះ ដោយមានភរិយារង់ចាំមើលផ្លូវ។

តែប្រសិនបើ ព្រះអាទិត្យមិនរះឡើងនោះទេ ថ្ងៃនោះគឺជាថ្ងៃ ដែលមេឃអួអាប់ងងឹតសូន្យសុង បម្រុងនឹងភ្លៀង ថ្ងៃនោះហើយគឺថ្ងៃដែលពុក គ្មានអាហារអ្វីទាល់តែសោះយកមកឱ្យកូនបរិភោគ ព្រោះថាពុកមិនបានទៅធ្វើការ ពុកខ្លោចផ្សាក្នុងចិត្តអាណិតកូនយ៉ាងក្រៃលែង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ពុកតស៊ូពុះពារគ្រប់បែបយ៉ាង នឹងឆ្លងឱ្យផុតពីភាពក្រីក្រនេះ។

ថ្វីដ្បិតតែពុកក្រ ក៏ពុកនៅតែចិញ្ចឹមកូន រហូតដល់កូនធំដឹងក្តី សព្វថ្ងៃនេះ ពុកខំណាស់ខំគ្មានពេលសម្រាកឡើយ ពុកខ្លាចកូនអត់ ខ្លាចកូនឃ្លាន ទោះបីជាការងារស្រាលធ្ងន់យ៉ាងណាក៏ដោយ ក៏ពុកធ្វើទាំងអស់ឥតមានរួញរាឬរាថយឡើយ ព្រោះពុកនឹកឃើញថា បើពុកមិនរកពុកមិនធ្វើ តើពុកបានអ្វីយកមកចិញ្ចឹមកូន?ពុកគ្មានអ្វីនោះទេ ដូច្នេះហើយការងារអ្វី ក៏ដោយ



www.elibraryofcambodia.org

ឱ្យតែបានប្រាក់កម្រៃ ដើម្បីបានយកមកចិញ្ចឹមកូន ការងារនោះពុកធ្វើទាំងអស់ ព្រោះពុកនឹកស្រណោះអាណិតកូន ពេលណាដែលពុករកលុយមិនបាន ដើម្បីទិញបាយឱ្យកូនបរិភោគ ជំ-ហានដំបូងនៃការគិតរបស់ពុក គឺពុកគិតពីកូន មុននឹងពុកគិតអ្វីៗទាំងអស់ ព្រោះជីវិតរបស់កូន គឺជាជីវិតដ៏សំខាន់ខ្លាំងណាស់សម្រាប់ពុក ការលះបង់របស់ពុកចំពោះកូន ក្នុងមួយឆាកជីវិតពុកនេះ គឺពុកលះបង់ដើម្បីកូន លះបង់ទាំងកម្លាំងកាយចិត្តតាំងពីសក់ខ្មៅរហូតដល់សក់ស បង្ហូរញើសឈាម បង្ហូរទឹកភ្នែកនិងការខិតខំប្រឹងប្រែងស្វែងរក សព្វគ្រប់បែបយ៉ាងរបស់ពុកនាពេលសព្វថ្ងៃនេះ គឺពុកធ្វើដើម្បីតែរូបកូនប៉ុណ្ណោះ។

កូនអើយ ដ្បិតតែពុកមិនមានអាហារ ឱ្យកូនបរិភោគ ពុកដាច់ចិត្តដើរសុំអាហារគេ យកមកឱ្យកូនបរិភោគ ពុកអត់ក៏អត់ទៅចុះឱ្យតែកូនរបស់ពុកបានឆ្អែត ប៉ុណ្ណឹងពុកសប្បាយចិត្តណាស់ហើយ។



www.elibraryofcambodia.org

គ្រប់ពេលវេលា ទោះបីជាឱ្យពុកធ្វើអ្វីក៏ពុកព្រមដែរ ពុកមិនដែលឆ្លើយថានោះឡើយ ពុកគិតៗពីកូន គិតពីកិច្ចការត្រូវធ្វើនៅថ្ងៃស្អែក គិតរហូតដល់អស់ជីវិតរបស់ពុកពីលោកនេះទៅថាតើពុកត្រូវធ្វើអ្វី រកអ្វីដើម្បីចិញ្ចឹមកូននៅថ្ងៃស្អែកបន្តទៀត? ដ្បិតថា ពុកយកកម្លាំងធ្វើជាដើមទុន ក្នុងការរកប្រាក់មកយកចិញ្ចឹមកូន ទៅតាមកម្លាំងបាយ និងកម្លាំងញើសឈាមរបស់ពុកដែល ពុកអាចរកបាន ពុកមិនបានសិក្សារៀនសូត្ររហូតដល់ថ្នាក់ខ្ពស់ដូចគេនោះទេ ហេតុដូច្នេះហើយ មានតែប្រើកម្លាំងបាយ គឺដៃពីរជើងពីរតែប៉ុណ្ណឹង ដើម្បីធ្វើជាដើមទុនដើម្បីស្វែងរក អាហារយកមកចិញ្ចឹមកូន ឱ្យបានរស់ធំដឹងក្តី។

ទោះបីជា ពុកគ្មានចំណេះដឹង ក៏ពុកខិតខំចិញ្ចឹមកូនមិនបោះបង់ចោលកូនឡើយ ពុកចិញ្ចឹមកូនឱ្យរស់ដោយដៃរបស់ពុកផ្ទាល់ រហូតដល់កូនធំដឹងក្តី ចេះហៅពុក ថាពុកដោយមាត់ផ្ទាល់របស់កូន ប៉ុន្តែការចិញ្ចឹមកូន គឺជាភារៈដ៏ធ្ងន់ណាស់



www.elibraryofcambodia.org

សម្រាប់ពុក ទោះបីជាធ្ងន់យ៉ាងណាក៏ដោយ ក៏ពុកសុខចិត្តធ្វើដើម្បីកូនដែរ។

ពុក តស៊ូពុះពារ រាល់ឧបសគ្គគ្រប់បែបយ៉ាង ពុកមិនរាថយឡើយ ពុកលះបង់ទាំងពេលវេលា លះបង់ទាំងកម្លាំងកាយចិត្តដើម្បីកូន ឱ្យតែកូនបានរស់ប្រកបដោយសេចក្ដីសុខ ឱ្យពុកធ្វើអ្វីក៏ពុកព្រមដែរ ក្នុងមួយជីវិតរបស់ពុកនេះ តាំងពីក្មេងរហូតដល់ចាស់ គឺពុកធ្វើអ្វីៗគ្រប់យ៉ាងដើម្បីកូនតែប៉ុណ្ណោះ។

កូនសំឡាញ់មាសឪពុក តើកូនដឹងទេ? ពេលខ្លះពុកធ្វើការងារបណ្ដើរ បីកូនបណ្ដើរ ដៃម្ខាងឱបកូន ហើយដៃម្ខាងទៀតពុកធ្វើការងារស៊ីឈ្នួលគេ ពុកមិនហ៊ានទុកកូនចោល ឱ្យនៅម្នាក់ឯងនោះទេ ពុកខ្លាចកូនមានគ្រោះថ្នាក់ និងខ្លាចកូនយំ។

ការលះបង់របស់ពុក ចំពោះកូន គឺវាធំធេងណាស់ សូម្បីតែជីវិតរបស់ពុក ក៏ពុកហ៊ានលះបង់ដើម្បីការពារជីវិតរបស់កូន ឱ្យតែកូនបានរស់រានមានជីវិត ក៏ពុកហ៊ានលះបង់ដោយគ្មានការស្ដាយស្រណោះឡើយ។



www.elibraryofcambodia.org

ជីវិតពុកស្លាប់ក៏ស្លាប់ទៅចុះ ឱ្យតែជីវិតរបស់កូនបានរស់ប៉ុណ្ណឹង ពុកសប្បាយចិត្តណាស់ហើយ តើចុះចិត្តកូនវិញហ៊ានលះបង់អ្វីខ្លះដើម្បីពុកដែរឬទេ? ប្រហែលជាអត់ទេមើលទៅ។

នៅពេលដែលពុកឈឺម្តងៗ ពុកតែងរង់ចាំមើលផ្លូវកូន មកមើលថែទាំ តែមិនឃើញស្រមោលកូនណាម្នាក់ មកមើលថែពុកឡើយ ដូចជាពាក្យ បុរាណមួយឃ្លា បានពោលថា ឪពុកម្តាយនឹកកូន ដូចប្រវាប្រដេញ កូននឹកឪពុកម្តាយវិញ ដូចព្រះបៃរខ្នង នេះគឺជាទឹកចិត្តរបស់កូនចំពោះពុក។

ពុកធ្វើគ្រប់យ៉ាងដើម្បីកូន ទោះជីវិតសូន្យក៏សុខចិត្ត
ឱ្យតែកូនរស់ពុកមិនគិត ត្រូវបង់ជីវិតក៏ព្រមដែរ។
ការងារស្រាលធ្ងន់ពុកមិនខ្វល់ ក្នុងទ្រូងអំពល់កូនមាសស្នេហ៍
ពុកថ្នាក់ពុកថ្នមបីបមថៃ ពុកសូមឱ្យតែកូនបានសុខ។
ជីវិតខ្លួនឯងពុកមិនព្រួយ ជីវិតកូនមួយព្រួយគ្រប់មុខ
ខ្លាចឈឺរងាដល់កូនពុក បណ្តាញស្នាញស្មុគក្នុងហឫទ័យ។



www.elibraryofcambodia.org

បើកូនបានសុខឪសប្បាយ ទោះអត់ប្រាក់ចាយមិនចេញស្តី
ធ្វើការស៊ីឈ្នួលទោះរែកដី ធូន់ស្រាលម្តេចក្តីពុកមិនថា។
ពេលព្រឹកព្រាងៗមុនថ្ងៃរះ ពុកចេញពីផ្ទះទៅធ្វើការ
កាប់គាស់ដកស្លងពុនដោយស្មា ក្រោមព្រះសុរិយាក្តៅចាំងចែង។
ពុកខំតស៊ូហើយពុះពារ ឧបសគ្គនានាតែម្នាក់ឯង
រស្មីព្រិចៗក្តៅហួតហែង ក្រោមព្រះសូរ្យសែងក្តៅស្មើរឆេះ។
ពុកប្រឹងធ្វើការរកកម្រៃ លីសែងដោយដៃបែកក្រៀមប្រេះ
ព្រលឹមព្រលប់យប់ដូច្នេះ តើក្នុងថ្ងៃនេះបានម្ហូបអ្វី។
ពីព្រឹកដល់ល្ងាចមិនហ៊ានឈប់ ដល់ពេលព្រលប់ចូលរាត្រី
វិលមកផ្ទះវិញឃ្លានចំណី ទោះតិចតួចក្តីហូបជុំគ្នា។
ពុកសែនសប្បាយកាយនឿយហត់ ទោះបីក្រខ្សត់ខំពុះពារ
ព្រោះដើម្បីកូនស្ងួនពុំងា ស៊ូទ្រាំវេទនាឱ្យកូនរស់។

**និពន្ធដោយ គង់ ច័ន្ទសុត្រ័**



www.elibraryofcambodia.org

# ៣.ដើម្បីកូនស៊ូសូត្រសន្ធារ

កូនសំឡាញ់ ក្នុងមួយឆាកជីវិតរបស់ពុក គឺពុកមានសេចក្ដីសុខណាស់ នៅពេលដែលពុកមានរូបកូន និងពេលដែលកូនមានសេចក្ដីសុខ ពុកក៏បានសុខដែរ នៅពេលដែលកូនមានទុក្ខ ពុកក៏មានទុក្ខជាមួយនឹងកូនដែរ ពេលនេះពុកចាស់ណាស់ទៅហើយ ពុកតែងតែដាស់តឿនក្រើនរំលឹកដល់កូនពុកជារៀងរាល់ថ្ងៃ ឱ្យកូនខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ព្រោះថាពុកមិនអាចចិញ្ចឹមកូនបានរហូតទេ ហើយពុកក៏មិនអាចនៅមើលថែកូនអស់មួយជីវិតបានដែរ មានតែចំណេះវិជ្ជាតែមួយគត់ ដែលអាចជួយកូនបាន នៅពេលដែលអត់ពីពុកទៅ។

ពុក គ្មានទ្រព្យអ្វី ដើម្បីបន្សល់ទុកឱ្យកូននោះទេ មានតែពាក្យពេចន៍សម្ដីខ្លះៗ ដើម្បីណែនាំប្រាប់កូន ទាន់ពេលពុកនៅមានដង្ហើម ពុកឱ្យខិតខំរៀនសូត្រតែប៉ុណ្ណោះ ផុតពីហ្នឹងទៅគឺកូនត្រូវតែពឹងលើសមត្ថភាពខ្លួនឯង ជីវិតនិងវាសនារបស់កូន



www.elibraryofcambodia.org

គឺស្ថិតនៅក្នុងកណ្ដាប់ដៃរបស់កូនហើយ ថ្ងៃក្រោយទៅ សុខទុក្ខ គឺរូបកូនជាអ្នករៀបចំ បើកូនមិនចេះស្រឡាញ់ខ្លួនឯងទេ ថ្ងៃមុខទៅ ជីវិតរបស់កូនប្រាកដជាជួបការលំបាកហើយ ដំណើរនៃជីវិតរបស់កូន គឺនៅយូរអង្វែងណាស់ បើយើងមិនរៀបចំវាទេ កូនមិនដឹងថា ជីវិតរបស់កូនត្រូវជួបប្រទះ នូវបញ្ហាអ្វីខ្លះនោះទេ ដែលនឹងត្រូវកើតឡើង ចំពោះជីវិតរបស់កូន នាពេលខាងមុខនោះ។

កូនអើយ ជីវិតគឺជាការតស៊ូ បើមិនតស៊ូព្យាយាមទេ ជីវិតនឹងទទួលផលវិបាក គ្មានអ្នកណាម្នាក់ដែលអាចជួយ កូនបានឡើយ ក្រៅតែអំពីខ្លួនកូន ចេះជួយខ្លួនឯងតែប៉ុណ្ណោះ។

ចំណែក ឯជីវិតរបស់កូនវិញក៏ដូចគ្នាដែរ គឺគ្មានអ្វីខុសគ្នាអំពីជីវិតរបស់អ្នកដទៃទៀយ បើអ្នកណាម្នាក់ មានការព្យាយាម មានការអត់ធ្មត់ មានការតស៊ូពុះពារ រាល់ឧបសគ្គសព្វគ្រប់បែបយ៉ាង ដែលបានកើតឡើងចំពោះជីវិត ហើយចេះដោះ



www.elibraryofcambodia.org

ស្រាយបញ្ហាចំពោះមុខ ដោយបញ្ញាស្មារតី អ្នកនោះប្រាកដជាទទួលបាន នូវសេចក្តីសុខ សុភមង្គលជាក់ជាមិនខាន នៅក្នុងឆាកជីវិត។

ហេតុដូច្នេះហើយ បានជាពុកព្យាយាមដាស់តឿនក្រើនរំលឹក ដល់ស្មារតីរបស់កូនជារៀងរាល់ថ្ងៃ ពុកសង្ឃឹមថាកូនរបស់ពុកនឹងចេះគិត កូននឹងចេះស្រឡាញ់ខ្លួនឯង មិនចាំបាច់ឱ្យពុកនិយាយច្រើនឡើយ តែការសង្ឃឹមនិងការជឿជាក់របស់ពុក គឺមិនដូចបំណងឡើយ ពុកបានត្រឹមតែការខកចិត្ត និងខុសបំណង ចំពោះរូបកូនយ៉ាងខ្លាំង ពុកអង្គុយដកដង្ហើមធំ ដោយការអស់សង្ឃឹមចំពោះរូបកូន។

កូនមិនអាណិត ដល់ទ្រូងឪពុកបន្តិចសោះឡើយ កូនដើរលេងសប្បាយ ស៊ីចាយហ៊ឹហា តាំងពីព្រលឹមទល់ព្រលប់ដើរលេងបាត់ៗ ពុកស្មានតែកូនទៅរៀន ព្រោះថាកូនបានប្រាប់ពុកថា កូនត្រូវទៅរៀនគួ ទារលុយពីពុក ថាយកទៅបង់ឱ្យគ្រូ កូន



www.elibraryofcambodia.org

ទារលុយប៉ុន្មាន ពុកឱ្យកូនប៉ុណ្ណឹង ទោះបីជាពុក អត់លុយសូម្បី តែមួយរយរៀល នៅក្នុងហោប៉ៅក៏ដោយ ក៏ពុកស៊ូទ្រាំទៅខ្ចីបុល លុយគេយកមកឱ្យកូន ដើម្បីឱ្យបានទៅរៀន តែតាមការពិត កូនកុហកពុកសោះ កូនមិនបានយកលុយពុក ដែលពុកឱ្យនោះ យកទៅរៀនទេ កូនបែរជាយកញើសឈាមរបស់ពុក ទៅចាយ វាយហ៊ុំហា ផឹកស្រា សេពគ្រឿងញៀន អាភៀនកញ្ឆា ជាមួយនឹងមិត្តភក្តិ បងតូចបងធំយ៉ាងសប្បាយរីករាយទៅវិញ នៅពេលដែលពុកបានដឹងដំណឹង ពុកធ្លាក់ថ្លើមក្តុក ដូចជាត្រូវ គេមកពុះទ្រូងរូងយកបេះដូងថ្លើមប្រមាត់របស់ពុកអ៊ីចឹងណាកូន តើឪពុកឯណាទៅដែលថាមិនខឹង? ហើយក៏ខឹងនឹងខ្លួនឯង ណាស់ដែរ មិនគួរណាបណ្តោយឱ្យកូន ក្លាយទៅជាបែបនេះ តើពុកឯណាទៅដែលថាមិនយំ? តើឪពុកឯណាទៅដែលថាមិន ស្រក់ទឹកភ្នែក? តើពុកឯណាទៅដែលថាមិនតូចចិត្តផ្អិតទ្រូង? គឺមិនមានសោះឡើយ។ បើកូនមិនព្រមស្តាប់ តាមការទូន្មាន



www.elibraryofcambodia.org

របស់ឪពុកម្ដាយយ៉ាងនេះ ពុកឈឺចិត្តណាស់កូន ឈឺសែនឈឺ ឈឺ ហួសនឹងពោលស្ដី។

កូនភ្លេចការសិក្សា មិនចូលសាលា មិនខិតខំរៀនសូត្រ កូនចេញទៅតែពីផ្ទះបាត់ៗ ព្រលឹមបាត់ព្រលប់ឃើញ មិនដឹងថាកូនទៅទីណានោះទេ ទម្រាំតែនឹងដឹង ស្ទើរតែនឹងហួសពេលទៅហើយ។

កូនអើយ សូមកូនអាណិតអាសូរ ដល់ទឹកភ្នែកឪពុកផងណាកូន បើកូនមិនអាណិតដល់ពុកទេ ក៏ហីទៅចុះ សូមឱ្យតែកូនចេះអាណិត ចេះស្រឡាញ់ខ្លួនឯងផងណាកូន ព្រោះថាកូនធំហើយ ពុកសូមឱ្យកូនឈប់ទៅ ឈប់ជក់អាភៀន ឈប់ញៀនកញ្ឆាយ៉ាម៉ា ឈប់ផឹកស្រា ឈប់គេចសាលា បន្តការសិក្សាវិញទៅណាកូន កូនត្រូវចាប់ផ្ដើមកសាងជីវិតថ្មី កូនត្រូវតែចូលសាលាខិតខំសិក្សារៀនសូត្រ សាងជីវិតសាជាថ្មីម្ដងទៀតណាកូន ព្រោះថាពេលវេលា ដែលកូនត្រូវកសាងខ្លួន គឺនៅមានពេលយូរ



www.elibraryofcambodia.org

ណាស់ សម្រាប់រូបកូនដើម្បីកែប្រែ នូវចិត្តគំនិតសាជាថ្មីនោះ គឺអាស្រ័យទៅលើខ្លួនកូនផ្ទាល់ប៉ុណ្ណោះ កូនត្រូវតែព្យាយាមកែទៅ កូនស៊ូឡើង កូនតស៊ូឱ្យបានណាកូន គឺមិនទាន់យឺតពេលនៅឡើយទេ គឺយើងនៅអាចស្រោចស្រង់បាន ដូច្នេះហើយកូនត្រូវតែព្យាយាមតទៅទៀត ពុកសូមអង្វរ។

បំណងល្អពីពុកដ៏កម្សត់របស់កូន!!!!!!

ពុកសែនឈឺចិត្តដ្បិតកូនកុហក
ដូចមច្ចុឆក់ស្រក់ទាំងទឹកភ្នែក
ពុកធ្វើការងារខំទូលពុនរែក
ពុកឈឺពន់ពេកពេលដឹងការពិត។
ពុកស្មានតែកូនទារលុយទៅរៀន
ទៅដក់អាភៀនដល់យប់ងងឹត
ពេលមកដល់ផ្ទះទារលុយជំរឺត
ថ្ងៃស្អែកនេះពិតចូលប្រឡងហើយ។



www.elibraryofcambodia.org

កូនទារប៉ុន្មានពុកឱ្យប៉ុណ្ណឹង
ដោយពុកមិនដឹងកូនកុំព្រួយឡើយ
ពុកបុលខ្ចីគេឱ្យកូនគ្រាណាត្រើយ
ស្រាប់តែកូនឆ្លើយលុយបង់ក្ដូទៀត។
ពេលចេញលទ្ធផលកូនប្រឡងធ្លាក់
បេះដូងឪធ្លាក់ក្នុងទ្រូងចង្អៀត
ពុកអាណិតកូនអត់លុយសូកសៀត
គេជាប់ព្រោងព្រាតកូនបែរជាធ្លាក់។
តាមពិតរូបកូនមិនដែលចូលរៀន
រវល់ជាប់ញៀនជាមួយមិត្តភក្តិ
ហេតុអ្វីយ៉ាងនេះកូនស្រស់វរលក្ខណ៍
ពុកនៅជំពាក់លុយគេវណ្ឌក។
មិនយូរប៉ុន្មានលិខិតមកដល់
ពុកស្មើរដាច់ខ្យល់ពេលអានអក្សរ



www.elibraryofcambodia.org

បានដឹងជាក់ច្បាស់រឿងកូនជើងល្អ
ពុកលែងមាត់កហួសនឹងពោលស្តី។
តើពុកឯណាដែលថាមិនខឹង
ម្តេចធ្វើអ៊ីចឹងណាកូនពិសី
ភូតភរឪពុកដោយពាក្យសម្តី
នៅក្នុងហឫទ័យពុកសែនឈឺណាស់។

**និពន្ធដោយ គង់ ច័ន្ទសុទ័ក្រ**

មនុស្សមិនមែនជាទេវតា ចុះអ្នកណាដែលមិនប្រព្រឹត្តខុស
តែបើដឹងថាខ្លួនធ្វើខុសហើយចេះកែ នោះទើបជាការប្រសើរ។



www.elibraryofcambodia.org

# ៤.ពុករស់ព្រោះដើម្បីកូន

សូរ្យសែងប្រឹងរះ ចាំងជះរស្មីពន្លឺព្រិចៗ ប្រដេញគ្នាក្ដៅហួតហែង ពុកប្រឹងប្រែងធ្វើការងារ សព្វគ្រប់បែបយ៉ាង ទោះ-បីជា ការងារធ្ងន់ស្រាលលីសែងដោយស្មា ឬប្រើកម្លាំងបាយក្រោមកម្ដៅថ្ងៃហាលភ្លៀងហាលខ្យល់ ពុកមិនខ្លាចនឿយហត់សោះឡើយ ដើម្បីបានប្រាក់កម្រៃបន្ដិចបន្តួច យកមកចិញ្ចឹមកូននៅតូចៗ ដែលកំពុងតែអង្គុយរង់ចាំមើលផ្លូវពុក យកអាហារមកឱ្យកូនបរិភោគ កូនរង់ចាំដោយការស្រេកឃ្លានអាហារយ៉ាងក្រៃលែង ចាំរហូតដល់ថ្ងៃត្រង់ ទម្រាំតែពុកបានប្រាក់យកមកទិញអាហារឱ្យកូនបរិភោគ ថ្ងៃកាន់តែជ្រេរទៅលិច ក្នុងចិត្តឪពុកអាណិតកូនយ៉ាងក្រៃលែង ពុកមើលមុខកូន ពុកស្រក់ទឹកភ្នែក ព្រោះថា កូនៗកំពុងតែអង្គុយរង់ចាំ មើលផ្លូវពុកមកពីផ្សារយ៉ាងអន្ទះសា យកអាហារមកឱ្យកូនបរិភោគ កូនចាំពុកយូរពេកធ្វើឱ្យឃ្លានខ្លាំង។ កូនអើយ ឱ្យពុកសុំទោស



www.elibraryofcambodia.org

ដែលពុកធ្វើបាបកូន ឱ្យកូនឃ្លានបាយដល់ថ្នាក់ហ្នឹង ពុកមិនចង់ឱ្យយឺតទេ តែពុកគ្មានលុយសោះឡើយ សូម្បីមួយរៀលក៏ពុកគ្មានដែរ ពុកទៅធ្វើការជាកម្មកររបស់គេ ទម្រាំតែនឹងបានលុយ ពុកប្រញាប់ប្រញាល់ ទៅទិញអាហារយកមកឱ្យកូន នេះហើយ គឺជីវិតអ្នកក្រ ចេះតែទ្រាំរស់ទៅ គឺទ្រាំរស់ដើម្បីកូន។

ដើម្បីកូន ធ្វើគ្រប់យ៉ាងឥតរាថយ
ដើម្បីកូន មិនបណ្តោយឱ្យវេទនា
ដើម្បីកូន ទោះនឿយហត់ឪពុះពារ
ដើម្បីកូន ទោះឈឺជាឥតពោលស្តី។
ដើម្បីកូន ឪខំណាស់គ្មានទំនេរ
ដើម្បីកូន ដល់ថ្ងៃជ្រេរគងព្រៃ
ដើម្បីកូន ធ្វើកិច្ចការដល់រាត្រី
ដើម្បីកូន ឪធ្វើអ្វីក៏ព្រមដែរ។
ដើម្បីកូន ការស្រាលធ្ងន់ទោះលីសែង



www.elibraryofcambodia.org

ដើម្បីកូន ក្រោមក្ដៅហែងតែងធ្វើស្រែ
ដើម្បីកូន ព្រោះស្រឡាញ់បុត្រមាសស្នេហ៍
ដើម្បីកូន រាល់ថ្ងៃខែថែវរមិត្ត។
ដើម្បីកូន ទោះត្រូវសូន្យបង់សង្ខារ
ដើម្បីកូន នឿយយ៉ាងណាមិនដែលគិត
ដើម្បីកូន ចេះតែព្រួយជាប់ក្នុងចិត្ត
ដើម្បីកូន ចេះតែគិតគ្រប់វេលា។
ដើម្បីកូន ឪមិនគិតពីខ្លួនឯង
ដើម្បីកូន ឪប្រឹងប្រែងធ្វើការងារ
ដើម្បីកូន ទោះត្រូវសូន្យបង់ជន្មា
ដើម្បីកូន គ្រប់វេលាក៏សុខចិត្ត។

ក្ដីសង្ឃឹមរបស់ពុក គឺសង្ឃឹមថា នៅពេលដែលកូនធំឡើង កូននឹងក្លាយទៅជាកូនល្អ ដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ មិនដូចជារូបពុក ដែលក្រលំបាកតោកយ៉ាក ប្រើតែកម្លាំងបាយ



www.elibraryofcambodia.org

នោះទេ ដូច្នេះ កូនត្រូវតែខំរៀនយកចំណេះ វិជ្ជាមកដាក់ក្នុងខ្លួនកូនឱ្យបាន ។

វិជ្ជាជាទ្រព្យជាប់នៅនឹងខ្លួន ឱ!កូនមាសស្ងួនសង្វាតកុំខាន
ត្រូវយកវិជ្ជាមកដាក់ក្នុងប្រាណ ទើបរូបកូនបានសេចក្ដីសុខពិត។
វិជ្ជាចេះបានដោយការប្រឹងប្រែង ព្យាយាមខ្នះខ្នែងដើម្បីជីវិត
តស៊ូពុះពារឧបសគ្គឆ្ងាយជិត ជម្នះផ្លូវចិត្តឱ្យមានរស្មី។
វិជ្ជាជាប្រទីបបំភ្លឺផ្លូវ នៅថ្ងៃក្រោយទៅរួចផុតទុក្ខភ័យ
ផុតពីងងឹតនិងភាពក្រក្រី សាងជីវិតថ្មីទឹកដីអ្នកប្រាជ្ញ។

**និពន្ធដោយ គង់ ច័ន្ទសុរ៉ាក្រ**



www.elibraryofcambodia.org

# ៥.ទឹកភ្នែកឪពុកជាជនពិការ

ឱ!កម្មលិខិត ឥតក្តីមេត្តា បានកំណត់ចារវាសនាមនុស្ស មិនដូចគ្នាមែន ឱ្យមានអ្នកមាន ឱ្យមានអ្នកខ្លះក្រ អ្នកអាក្រក់ អ្នកល្អ អ្នកសអ្នកខ្មៅ អ្នកខ្លៅអ្នកឆ្លាត អ្នកទាបអ្នកខ្ពស់ តាម កម្មលិខិតជាអ្នកកំណត់ ជាអ្នកចាត់ចែង ដោយគ្មានអ្នកណា ម្នាក់ អាចជជែកវែកញែក ប្រកែកតវ៉ាបានឡើយ តាមពិតទៅ កម្មបែងចែកសត្វលោក ទៅតាមកម្មរបស់ខ្លួនបានសុក្រឹត ណាស់ ឥតស៊ីសំណូកសូកប៉ាន់ ចំពោះអ្នកណាម្នាក់ឡើយ។

កម្មលិខិត ពិតជាសាហាវណាស់ តាមមកផ្តន្ទាយាយី នៅ ក្នុងឆាកជីវិត ធ្វើឱ្យជីវិតរបស់ពុក ក្លាយខ្លួនទៅជាជនពិការ នូវអវយវៈ ដោយគ្មានចិត្តអាណិតប្រណី ឥតក្តីមេត្តា សន្តោស អាសូរ រស់នៅសព្វថ្ងៃកំដរជីវិតរស់ឥតខ្លឹមសារ ជាជនពិការសុំ ទានគេ ដើម្បីជីវិតនឹងបានរស់នៅជាបន្ត តាំងពីព្រឹកទល់ព្រលប់ ត្រូវទៅដើរសុំគេ ។



www.elibraryofcambodia.org

ពុកលើកម្រាមដៃដប់ប្រណម្យសូមទាន ដោយការស្រេកឃ្លាន ហ៊ានលើកដៃសំពះសុំទានគេ ថ្ងៃខ្លះគេឱ្យដោយការអាណិតអាសូរ ក៏បានទិញចំណីអាហារ យកមកឱ្យកូនបរិភោគហើយ ថ្ងៃខ្លះទៀតក៏សុំមិនបាន ត្រូវគេជេរប្រទេចដាក់បណ្តាសា ដៀលត្មះថា យើងជាអ្នកក្រ អ្នករហាម ជាពូជអ្នកឈាមថោក ត្រូវគេប្រមាថ ត្រូវគេមើលងាយមើលថោក គេរើសអើងគេស្អប់គេខ្ពើម ជីវិតជាជនពិការ រស់នៅអនាថាគ្មានទីពឹងប្រៀបដូចជាសំរាម ដែលត្រូវគេបោះបង់ចោល ដោយគ្មានក្តីអាណិតសន្តោស គេមិនឱ្យយើងហើយ គេថែមជេរស្តីយើងទៀត ពុកនិងកូនត្រូវដេកអត់បាយ ជួនត្រូវគេឱ្យ ជួនគេមិនឱ្យធ្វើម្តេចបើយើងគ្មានមុខរបរ គ្មានចំណេះដឹង មិនបានចូលសាលាសិក្សារៀនសូត្រ បើរស់តែនឹងទៅរៀន វាស្ងិតក្រពះតើបានអាហារអីយកមកបរិភោគ? រស់ដោយលើកដៃសំពះ សុំគេ ព្រោះថាក្រពះវានៅឃ្លាន ហ៊ានដាច់ចិត្តលើកដៃហាមាត់សុំ។



www.elibraryofcambodia.org

យើងជាអ្នកក្រគ្មានទ្រព្យធនអ្វី ដើម្បីបម្រុងទុកបរិភោគនោះទេ ដូច្នេះហើយ ត្រូវគិតក្រពះជាមុនសិន នេះគឺជាជីវិតនៃជនពិការ រស់ដោយសារការសុំទាន។

ឱ!កម្មលិខិតឥតក្ដីមេត្តា ប្រែប្រួលវាសនាគ្មានក្ដីអាសូរ
ធ្លាក់ខ្លួនពិការទឹកភ្នែកស្រក់ហូរ ជីវិតត្រូវប្ដូររស់ឥតខ្លឹមសារ។
រស់នៅមួយថ្ងៃកំដរមួយថ្ងៃ ទម្រាំដល់ក្ស័យបាត់បង់សង្ខារ
ក្នុងភពងងឹតជាជនពិការ ដើរសុំអាហារដោយសារគេរស់។
លើកម្រាមដៃជប់ប្រណម្យសូមទាន អស់លោកអ្នកមានសូមចិត្តសន្ដោស
ដាក់ទានឱ្យខ្ញុំបន្តិចផងចុះ សូមជួយសង្គ្រោះជីវិតអ្នកក្រ។
អូសជើងតត្រុកសំកុកតាមផ្សារ ដៃទាំងទ្វេហាលន់តួអង្វរ
ដៃឱបឈើច្រត់គេមិនមាត់ក អ្នកខ្លះចិត្តល្អក៏គេមេត្តា។
អង្គុយពីព្រឹកសំកុកដល់ថ្ងៃ ផ្ដុំដោយម្រាមដៃដាក់លើសិរសា
ហាមាត់ស្រែកសុំដួងចិត្តខ្លោចផ្សា ដាក់ទានផងណាខ្ញុំប្រាថ្នារស់។



www.elibraryofcambodia.org

អ្នកខ្លះគេឱ្យដោយក្ដីអាណិត ចេញពីដួងចិត្តដោយការសង្គ្រោះ
អ្នកខ្លះក៏ឃើញគេក៏ដើរហួស ខ្ញុំសូមមួយពោះរស់ត្រឹមមួយគ្រា។
រស់នៅសព្វថ្ងៃគេស្អប់គេខ្ពើម គេឃើញរអើមត្រូវគេនិន្ទា
សម្លៀកបំពាក់គឃរីគឃារ ខិតខំពុះពាររស់ដើម្បីកូន។
ដ្បិតត្រូវសង្គមគេខាកគេស្ដោះ តែណ្ដើយចុះមិនអីទេស្ងួន
ពុកអាចទ្រាំបានក្ដីទុក្ខផ្ទួនៗ ទោះបីស្លាប់ខ្លួនឱ្យតែកូនរស់។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**



www.elibraryofcambodia.org

# ៦.សែនអនិច្ចាវាសនាឪពុកចាស់

ជីវិត ពិតជាលំបាក កាលពីនៅក្មេងៗកម្លាំងមាន ចង់ធ្វើអ្វីក៏បានធ្វើអ្វីក៏ស្រួល កាប់គាស់លីសែងរែកពុន ធ្វើស្រែចម្ការ ភ្ជួររាស់ដកស្ទូង ធ្វើបានទាំងអស់ដោយកម្លាំងខ្លួន តែពេលឥឡូវនេះ វ័យក៏កាន់តែចាស់ជរា ប្តូរផ្លាស់ណាស់ទៅហើយ រស់ដោយសារកម្លាំងកូន។

ដ្បិតតែពុកចាស់ប៉ុណ្ណឹង កូនអើយ ទ្រព្យសម្បត្តិរបស់ពុកដែលពុករកបានក៏មិនខ្វះដែរ ព្រោះថា ពុកខិតខំប្រឹងប្រែងស្វែងរកយកមកសន្សំទុក ដើម្បីធ្វើជាកេរ្តិ៍មរតក ទុកចែកឱ្យកូន ក៏មិនតិចតួចប៉ុន្មានដែរ តាំងតែពីក្មេង រហូតមកដល់ពេលនេះ គឺតាំងតែពីសក់ខ្មៅ រហូតមកដល់សក់ស្កូវ នៅពេលដែលកូនមានគ្រួសារ បែកផ្ទះសម្បែងនោះ ពុកនឹងចែកទ្រព្យសម្បត្តិឱ្យកូនធ្វើជាដើមទុន ដើម្បីបង្កើតមុខរបររកស៊ីចិញ្ចឹមជីវិត។



www.elibraryofcambodia.org

តែនៅពេលនេះ ពុកក៏មិនអាចធ្វើអ្វីបាន ដូចមុនទៀតឡើយ ព្រោះពុកចាស់ណាស់ទៅហើយ វ័យកាន់តែចាស់កម្លាំងកាន់តែចុះខ្សោយទៅៗ រស់បានដោយសារកូន គ្មានអ្វីទីពឹងទៀតទេ។

កាលគ្រាដើមឡើយ កាលកូននៅតូចៗចំទង់ មិនទាន់មានប្រពន្ធឬគ្រួសារ កូនគេនិយាយថា គេជានារ៉ាប់រងនឹងចិញ្ចឹមពុកវិញអស់មួយជីវិត គឺមិនឱ្យពុកលំបាកទេ ឱ្យរស់យ៉ាងស្រួល តែនៅពេលដែលពុកមានវ័យចំណាស់ទៅ ពុកខំតែជឿជាក់ទៅលើសម្ដីកូន ថាកូនគឺជាកូនម្នាក់ ដែលធ្វើឱ្យពុកអាចទុកចិត្តបាន អាចឱ្យពុកពឹងពាក់ពំនាក់អាស្រ័យបាន ទៅថ្ងៃក្រោយ ពុកខំតែចែកទ្រព្យសម្បត្តិឱ្យកូនទាំងអស់ ដោយគ្មានសល់អ្វីបន្តិចបន្តួចសោះឡើយ ហើយពុកសូមកូនរស់នៅជាមួយ សូមត្រឹមតែរស់ប៉ុណ្ណោះ។



www.elibraryofcambodia.org

ពុក ខំតែជឿសម្ដីកូន ជឿយ៉ាងស្លុងចិត្ត ជឿទៅលើកូន ថានឹងបានកូនជាទីពឹង ទៅថ្ងៃក្រោយ នៅពេលដែលខ្លួនចាស់ជរា ឈឺគ្រាំគ្រានៅលើគ្រែ ធ្វើអ្វីមិនកើត បានកូនជាអ្នកចិញ្ចឹមបីបាច់ថែរក្សា សង្ឃឹមថាកូន គេនឹងតបស្នងសងគុណចិញ្ចឹមឪពុកវិញ ដូចអ្វីដែលពុកបានធ្វើចំពោះកូន ។

អ្វីៗទាំងអស់ គឺវាបានខុសស្រឡះ អំពីអ្វីដែលពុកបានគិតកន្លងមក ដោយនឹកស្មានមិនដល់ ថាកូនក្លាយទៅជាបែបនេះ ពុកខំសង្ឃឹមយ៉ាងមុតមាំថា កូនគឺជាក្ដីសង្ឃឹមចុងក្រោយបំផុតរបស់ពុក ដែលពុកអាចពឹងពាក់បាន នៅពេលដែលចាស់ទៅនោះ។

តែក្ដីសង្ឃឹមរបស់ពុក បានរលាយសាបសូន្យអស់ទៅហើយគ្មានសេសសល់ ពុកបានត្រឹមតែការខកចិត្ត និងខុសបំណងជាខ្លាំង កូនៗមិនគិតដល់ឪពុកឡើយ ពុកកាន់តែចាស់



www.elibraryofcambodia.org

ជរាខ្លាំងណាស់ទៅហើយ កូនមិនខ្វល់ឡើយចំពោះឪពុក កូនគិតតែគ្រួសាររបស់កូនប៉ុណ្ណោះ ។

កូន គេទុកឪពុកចោល ឱ្យរស់តែម្នាក់ឯងអុជចង្កៀងប្លុងៗក្នុងខ្ទមស្រែ ឯកូនមាសស្នេហ៍រស់ក្នុងវីឡា សម្បូរសប្បាយចាយដុល្លារ ពុកឈឺខ្លោចផ្សាក្នុងខ្ទមចង្អៀត ឆ្ងៀតនឹកកូននោះទៅទៀត បើកូនអាចឆ្លៀតសុំមកមើលពុកផង។

ពុកកាន់តែចាស់វ័យកាន់តែជ្រេ ហេតុអ្វីមាសមេកូនធ្វើដូច្នេះ ឬមួយកូនគិតថាពុកចាស់ជរាទៅហើយ តាចាស់ម្នាក់នេះលែងមានប្រយោជន៍អ្វី សម្រាប់កូនទៀតហើយ នេះឬការតបស្នងសងគុណរបស់កូនមកលើពុក ការលះបង់ដ៏ធំធេងរបស់ពុកវាគ្មានន័យអ្វីសម្រាប់កូនទៀតទេឬ សម្រាប់មនុស្សចាស់ដូចជារូបពុកម្នាក់នេះ?។

ពុកនិងម៉ែតែប៉ុណ្ណេះចេះតែចាស់
កូនណាខ្លះដែលចេះគិតដល់ពុកម៉ែ



www.elibraryofcambodia.org

នឹកតបស្នងសងគុណគាត់ចិញ្ចឹមថៃ
នៅពេលម៉ែហើយនិងពុកចាស់ជរា។
ពុកនិងម៉ែតែងតែគិតនឹកស្រមៃ
មុនដល់ថ្ងៃក្ស័យជីវិតសូន្យជន្មា
ទុកម៉ែចោលឱ្យរងគ្រោះរស់រងា
ម៉ែវេទនាកូនគ្រប់គ្នារស់សប្បាយ។
ពុកនិងម៉ែប្រែគ្រាំគ្រាវ័យចំណាស់
ប្រាកដណាស់ច្បាស់ជាប្រាស់ព្រាត់ទៅឆ្ងាយ
កាលនៅរស់កូនទាំងអស់បង្អត់បាយ
បង់រូបកាយទើបនឹកស្តាយយំស្រណោះ។

កូនអើយ កូនភ្លេចអស់ហើយឬ នូវអនុស្សាវរីយ៍ ដ៏កម្សត់កម្រជាមួយគ្នា គ្រាពុកអៀវកូនឆ្លងទឹក ដឹកដៃកូនចូលសាលាបន្តការសិក្សា ពុកខំធ្វើការងាររកលុយយ៉ាងលំបាក ដើម្បី



www.elibraryofcambodia.org

យកមកឱ្យកូនរៀនសូត្រ ពុកខំស្វែងរកអនាគតឱ្យកូនដោយនឹកសង្ឃឹមថា កូននឹងមានអនាគតល្អ។

ពុក រ៉ាប់រងចិញ្ចឹមកូនតែម្នាក់ឯង ពុកត្រូវសម្លាប់ជីវិតសត្វដទៃ មានត្រីជាដើម ដើម្បីយកមកចិញ្ចឹមកូន ពុកធ្វើដោយគ្មានញញើតដៃមិនប៉ប្រិចភ្នែកឡើយ ទោះបីជាឱ្យពុកធ្វើអ្វីក៏ពុកព្រមដែរ ឱ្យតែបានចិញ្ចឹមកូន ឱ្យតែជីវិតរបស់កូនបានរស់ ពុកសាងកម្មអកុសលច្រើនណាស់ ដើម្បីចិញ្ចឹមកូនឱ្យបានរស់រហូតធំដឹងក្តី ពុកចិញ្ចឹមកូនបួនដប់ម្តៃ រហូតដល់ធំដឹងក្តីបានរស់យ៉ាងស្រួល ចុះចំណែកកូនវិញ តើកូនបួនដប់ម្តៃនាក់ចិញ្ចឹមពុកមួយមិនរស់ទេឬ? គឺប្រហែលជាមិនរស់ទេមើលទៅ តើកូនមិនយល់ថា ជាអយុត្តិធម៌សម្រាប់ពុកទេឬ? ទីបំផុតជីវិតរបស់ឪពុករស់គ្មានទីពឹងមែន។

តំណក់ទឹកភ្នែកស្រក់លើផែនថ្ពាល់ រឿងរ៉ាវជួបផ្ទាល់នៅក្នុងជីវិត
លង់ជឿសម្តីកូនយ៉ាងស្លូងចិត្ត ចែកទ្រព្យមិនគិតភ្លេចខ្លួនជរា។
ដីស្រែចម្ការមានច្បារដំណាំ ដីកេរ្តិ៍រ៉ាប់ឆ្នាំឪខំការពារ
កាត់ជាចំណែកចែកកូនគ្រប់គ្នា សង្ឃឹមបុត្រភ្ញាចិញ្ចឹមពុកផង។



www.elibraryofcambodia.org

មានគោក្របីដីផ្ទះសម្បែង ទ្រូងឪចំបែងសែនខុសបំណង
កូនគេប្រែប្រួលក្រឡាស់បែរខ្នង ជាការតបស្នងឱ្យពុកទឹកភ្នែក។
ពុកនៅក្នុងខ្ទមកូននៅវីឡា ឪរស់ខ្លោចផ្សាដំបូលប្រក់មេឃ
ចង្កៀងប្លុងៗជញ្ជាំងរហែក ក្នុងផ្ទះបាក់បែកជរាពិការ។
កូនរស់សប្បាយឪរស់រងទុក្ខ ថ្ងៃនេះទៅមុខគ្មានអ្នករក្សា
មើលថែពុកចាស់ខ្វះទាំងអាហារ រហូតមរណាកូនធ្វើមិនដឹង។
ពុទ្ធោម្ចាស់ថ្លៃម្រាមដៃធ្លាប់ថ្នម មាត់ច្រៀងល្វងលោមបីបមព្រលឹង
ចាំមើលផ្លូវកូននឹមនួនស្វាត់ឈឹង ឪដេកទន្ទឹងសង្ឃឹមមើលផ្លូវ។
តើដល់ពេលណាទើបកូនភ្ញាក់ខ្លួន មកមើលថែថ្នួនរក្សាម៉ែឪ
វ័យកាន់តែចាស់ជរាហើយពៅ ពីថ្ងៃនេះទៅឪនៅម្នាក់ឯង។
ជីវិតឪរស់ព្រោះកូនអាស្រ័យ កូនមិនអាល័យក្រោមថ្ងៃក្ដៅហែង
រស់យ៉ាងលំបាកចិត្តសែនចំបែង រសាត់ដូចផ្សែងរស់គ្មានទីពឹង។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**



www.elibraryofcambodia.org

## ៧.ទឹកភ្នែកប្រពន្ធដើម

អប្រាត្រស្ងប់ស្ងាត់រសាត់ទឹកហូរ ភ្លៀងធ្លាក់ជន់ហូរសូរលាន់រងំ
រាត្រីក្រៀមក្រោះឮសូរសត្វយំ រាត្រីភ្លៀងធំកូនយំឱបម៉ែ។
យប់កាន់តែជ្រៅម៉ែនៅម្នាក់ឯង ដួងចិត្តចំបែងរងទុក្ខឥតល្ហែ
ម៉ែអាណិតកូនឪមិននៅក្បែរ នៅក្នុងខ្ទមស្រែថែកូនចាំប្តី។
ចាំបាត់ៗចាំមើលតែផ្លូវ តើថ្ងៃណាទៅទើបមករកស្រី
នាមជាភរិយាថែកូនទាំងបី កូនអត់អីឆីសួររកឪពុក។
អូនឆ្លើយប្រាប់កូនថាបងធ្វើការ កូនខំសិក្សាចាំទៅជួបមុខ
ចាំបាត់ៗទាំងចិត្តស្មាញស្មុគ ត្រួសារជួបទុក្ខចាំបងវិលវិញ។
ជួបគ្រាដំបូងថាស្រលាញ់ស្មោះ បានប្រាណក៏ដោះឱ្យស្រីម្នោម្នេញ
ទុក្ខធំផ្ទួនៗនិយាយមិនចេញ កូនតែងទន្ទេញសួររកឪពុក ។
ទឹកភ្នែកប្រពន្ធដើមហូរទម្លាក់ ចុះមកឥតទាក់ដេកឱបក្តីទុក្ខ
មិនដែលស្គាល់ទេថាមានក្តីសុខ ថ្ងៃនេះទៅមុខមិនដឹងយ៉ាងណា។



www.elibraryofcambodia.org

ឱ!កូនសំឡាញ់ស្មើនឹងជីវិត ឪកូនក្បត់ចិត្តលួចមានសង្សារ
មានប្រពន្ធចុងចុះចោលគ្រួសារ ឱ្យម្តាយខ្លោចផ្សាឱរាចុកចាប់។
ម៉ែសែនឈឺចិត្តស្ទើរប្រេះដើមទ្រូង ស្ទើរគាំងបេះដូងជីវិតអួអាប់
មិនចង់រស់ទេចង់តែទៅស្លាប់ ប៉ុន្តែវាយ៉ាប់ព្រោះអាណិតកូន។
ឱ!ប្តីហោងសិយបានផ្តោយគំនិត បានកាយណាយចិត្តស៊ុលោក់បំពួន
មិនស្តប់មិនស្តល់បានប្រាណបានខ្លួន មានបីមានបួនថែមបួនបូកប្រាំ។

**និពន្ធដោយ គង់ ច័ន្ទសុត្រ័ក្រ**



www.elibraryofcambodia.org

## ៨.ជីវិតម៉ែវាសនាកូន

ជាតិជាស្ត្រី វ័យជាម្តាយតែខ្វល់ខ្វាយ ចំពោះកូនជានិច្ច គ្រប់ពេលវេលាទាំងអស់ មិនថាយប់ឬថ្ងៃ តាំងពីថ្ងៃដែលកូនបានមកចាប់បដិសន្ធិ នៅក្នុងផ្ទៃនៃមាតា ម៉ែតែងខ្វល់ខ្វាយថៃរក្សាការពារ កូនគ្រប់ពេលវេលា គ្រប់វិនាទី។

ទោះបីជាម៉ែ ទទួលរងនូវការលំបាក ក្នុងការពពោះ ព្រោះកូនអាស្រ័យក៏ដោយ ក្នុងរយៈពេល ៩ ខែ ១០ ថ្ងៃ ឬ ១០ ខែ ម៉ែជួបប្រទះនូវការលំបាក សព្វគ្រប់បែបយ៉ាងទាំងអស់ ទាំងការដេក ដើរ ឈរ អង្គុយ បរិភោគចំណីអាហារ ជូរ ប្រៃ ហឹរខារ គឺប្រព្រឹត្តទៅមិនស្រួលប៉ុន្មានទេ។

ម៉ែ នៅរង់ចាំមើលផ្លូវកូន ដែលត្រូវប្រសូតចេញពីផ្ទៃរបស់ម៉ែយ៉ាងអន្ទះសា ព្រោះម៉ែចង់ឃើញមុខកូន ថ្នាក់ថ្នមកូនដោយផ្ទាល់ដៃរបស់ម៉ែ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយ



www.elibraryofcambodia.org

ខែ ម៉ែបន់ឱ្យតែដល់ ថ្ងៃកូនប្រសូតនោះទេ មិនយូរប៉ុន្មាន ថ្ងៃក៏មកដល់ ម៉ែនឹងបានឃើញមុខកូន។

ថ្ងៃដែលកូន ប្រសូតចេញពីផ្ទៃរបស់ម៉ែ គឺជាថ្ងៃដែលម៉ែទទួល រងនូវទារុណកម្ម យ៉ាងធ្ងន់ធ្ងរដ៏ក្រៃលែង ចំពោះម៉ែដែលម៉ែមិនធ្លាប់បានជួបកន្លងមក នៅក្នុងមួយឆាកជីវិតរបស់ម៉ែនេះ។

គឺជាថ្ងៃនៃសេចក្ដីទុក្ខរបស់ម៉ែ និងជាថ្ងៃដែលជីវិតរបស់ម៉ែស្ទើរស្លាប់ស្ទើររស់ គឺមិនទាន់បានដឹងនៅឡើយទេ ថាជីវិតរបស់ម៉ែ អាចឆ្លងផុតដែរឬទេ ព្រោះម៉ែឈឺណាស់ ឈឺហួសគណនា ឈឺចុកចាប់ពេញសព្វសារពាង្គកាយ ម៉ែយំម៉ែស្រែកស្រែករកអ្នកជួយ ស្រែករហូតដល់ភ្លាត់សំឡេង គួរឱ្យរន្ធត់តក់-ស្លុតយ៉ាងក្រៃលែង ព្រោះម៉ែឈឺណាស់ ឈឺស្ទើរតែទ្រាំលែងបាន សន្លប់ម្ដងៗ ម៉ែបាត់បង់ស្មារតី ឈាមម៉ែស្រក់ហូរមក ស្ទើរក្លាយជាស្ទឹង លាយជាមួយនឹងសំឡេងរបស់ម៉ែ ដែលស្រែកទ្រហោយំ លាយឡំជាមួយនឹងទឹកភ្នែកស្រក់ហូរមកតក់ៗ កាត់



www.elibraryofcambodia.org

តាមផែនថ្កាល់ទាំងសងរបស់ម៉ែ ព្រោះម៉ែឈឺ សែនឈឺ ឈឺខ្លាំងណាស់កូន នៅពេលដែលម៉ែឈឺខ្លាំង ម៉ែគ្មានសង្ឃឹមឡើយថានឹងបានរស់ បានឃើញមុខកូននោះទេ។

ឈឺអើយសែនឈឺៗគ្មានអ្វីផ្ទឹម
ម៉ែអស់សង្ឃឹមហើយណាមាសមេ
ម៉ែឆ្លងមិនផុតថ្ងៃឆ្លងទន្លេ
មិនសង្ឃឹមទេថាបានរស់ឡើយ។
ទោះម៉ែស្លាប់ទៅក៏ម៉ែមិនស្តាយ
សូមត្រឹមតែម្តាយប្រសូតកូនហើយ
ចម្លងបុត្រថ្លៃឱ្យបានដល់ត្រើយ
ម៉ែឈឺឥតស្បើយឈាមហូរជាស្ទឹង។
សំឡេងកូនយំវាសនាកូនម៉ែ
ម៉ែមិនបានថែទេកូនព្រលឹង
ម៉ែចម្លងកូនបានតែប៉ុណ្ណឹង
ចាប់ពីពេលហ្នឹងកូនត្រូវរៀនរស់។



www.elibraryofcambodia.org

តែទោះបីជា ម៉ែឈឺយ៉ាងណាក៏ដោយ ក៏ម៉ែនៅតែព្យាយាមតស៊ូ ដើម្បីចម្លងឱ្យបានដល់ត្រើយ ព្រោះជីវិតកូនផ្ញើនៅលើម៉ែហើយ ជីវិតម៉ែគឺជាវាសនាកូន បើជីវិតរបស់ម៉ែត្រូវស្លាប់ ជីវិតកូនក៏ត្រូវស្លាប់ដែរ ហេតុដូច្នេះហើយបានជាម៉ែខំណាស់ ខំអត់ធ្មត់ខំដើម្បីកូន ខំដល់ជីវិតចុងក្រោយរបស់ម៉ែ ក៏ម៉ែនៅតែខំ ជីវិតម៉ែស្លាប់ ក៏ស្លាប់ទៅចុះ សូមឱ្យតែជីវិតរបស់កូនបានរស់ ប៉ុណ្ណឹងម៉ែសប្បាយ ចិត្តណាស់ហើយ។

ម្រាមដៃស្រលនគួរស្រឡាញ់ វង់ភក្ត្រគួរក្នាញ់អ្វីម្ល៉េះហ្ន៎
កូនកើតមកភ្លាមម៉ែត្រេកអរ ដួងចិត្តស្មោះសរបង្កើតថ្លៃ។
កូនទើបនឹងកើតចេញពីគភ៌ ម៉ែភ័យញាប់ញ័រឈឺពេកក្រៃ
ម៉ែឈឺចុកចាប់ស្មើរតែក្ស័យ គឺនៅក្នុងថ្ងៃឆ្លងទន្លេ។
ឈាមម៉ែស្រក់ហូរដូចជាស្ទឹង ម៉ែសន្លប់ឈឹងហើយមាសមេ
មិនសង្ឃឹមថាបានរស់ទេ ថៃថ្នូនបំពេកូនព្រលឹង។



www.elibraryofcambodia.org

ជីវិតអ្នកម៉ែវាសនាកូន	ម៉ែចម្លងស្ងួនបានត្រឹមហ្នឹង
ម៉ែឈឺខ្លាំងពេកដេកសម្លឹង	កូនគ្មានទីពឹងអត់ពីម៉ែ។
សន្លប់ផ្ងួនៗខ្លួនសែនឈឺ	សំឡេងលាន់ឮឈឺត្អូញត្អែរ
សូមឱ្យគេជួយព្រួយឥតល្ហែ	ឱ!កូនមាសស្នេហ៍ម៉ែឈឺណាស់។
ឈាមហូរតក់ៗស្រក់ទឹកភ្នែក	ម៉ែឈឺពន់ពេកស្រែកបម្រះ
សូមឱ្យកូនកើតឆាប់រហ័ស	កូនយំដូចដាស់ស្មារតីម៉ែ។
បានឮសំឡេងកូនមាសម្ដាយ	ទុក្ខបានរសាយបន្តិចដែរ
បានឃើញមុខកូនម៉ែបានល្ហែ	បំពៅមាសស្នេហ៍ដោយផ្ទាល់ដៃ។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**

**ម៉ែស៊ូលះបង់ជីវិតខ្លួនឯងដើម្បីកូន**
**តើកូនហ៊ានលះជីវិតដើម្បីម៉ែដែរទេ?**



www.elibraryofcambodia.org

# ៩.ជីវិតអត់ឪ

ដំណើរនៃជីវិត គឺពិតមិនទៀង គ្រប់មនុស្សសត្វទាំងអស់ ដែលបានកើតមក នៅក្នុងលោកិយនេះ បានឃើញនូវពន្លឺ នៃព្រះអាទិត្យ បានស្គាល់នូវរស់ជាតិនៃជីវិត ជីវិតពិតជាមាន សេចក្តីសុខហើយនិងទុក្ខ ជារឿងធម្មតារបស់សត្វលោក។

មនុស្សយើងទាំងអស់ សុទ្ធសឹងតែមានទុក្ខគ្រប់រូបគ្រប់គ្នា ទាំងអស់ គ្រាន់តែសេចក្តីសុខហើយនិងទុក្ខនោះ វាមិនដូចគ្នា តែប៉ុណ្ណោះ អ្នកខ្លះគេក៏មានសេចក្តីសុខ ដោយមានឪពុកម្តាយ នៅរស់រានមានជីវិតជុំផិតជាមួយ នៅរង់ចាំជួយមើលថែរក្សា ការពារផ្តល់នូវភាពកក់ក្តៅ ផ្តល់នូវសេចក្តីស្រឡាញ់ ស្និទ្ធស្នាល គ្រប់ពេលវេលា អ្នកខ្លះទៀត ក៏មានសេចក្តីទុក្ខច្រើនជាង សេចក្តីសុខ ដ្បិតតែបានកើតមកនៅក្នុងត្រកូលអ្នកមាន សម្បូរ សប្បាយចាយដុល្លារ រស់នៅក្នុងដំបូលផ្ទះវីឡា សម្បូរធនធាន ច្រើនក៏ដោយ ក៏ប៉ុន្តែសេចក្តីសុខហើយនិងទុក្ខ វាច្រើនតែដើរ



www.elibraryofcambodia.org

ទន្ទឹមគ្នា ជាពិសេស គឺសេចក្តីទុក្ខដែលបានជួបគ្នាទៅហើយ បែរជាត្រូវព្រាត់ប្រាសគ្នាទៅវិញ នេះគឺជាសេចក្តីទុក្ខដ៏ធ្ងន់ ធំធេងណាស់ សម្រាប់មនុស្សយើងម្នាក់ៗ តែងតែមានគ្រប់រូប គង់តែនឹងជួបគ្រប់ៗគ្នាទាំងអស់។

ព្រោះថា វាគឺជារឿងរ៉ាវនៃច្បាប់របស់ធម្មជាតិ ទៅហើយ ដែលនឹងត្រូវកើតឡើង មិនអាចកែប្រែបាន ចំពោះជីវិតរបស់មនុស្សយើងម្នាក់ៗ តែងតែប្រែប្រួល តែងតែប្តូរផ្លាស់ទៅជារៀងរាល់ថ្ងៃ មិនទៀងទាត់ មិនស្ថិតស្ថេរឡើយ។

ចុះហេតុអ្វី បានជាកម្មលិខិតឥតក្តីមេត្តា កម្រិតវាសនារបស់ខ្ញុំខុសគេ បានកើតមកហើយ មិនដែលបានដឹង មិនដែលបានស្គាល់ឡើយ នូវមុខរបស់ម៉ែ ថាមានរូបរាងបែបណានោះទេ តើកម្មអកុសលអ្វីខ្ញុំ តាមមកផ្តន្ទាយ៉ាងនេះ ដោយគ្មានអាណិតអាសូរ ដល់ជីវិតសត្វលោក បន្តិចសោះឡើយ។



www.elibraryofcambodia.org

តាំងពីតូចដល់ធំ រស់នៅតែជាមួយឪពុក មិនដែលបានស្គាល់ជាតិឡើយ នៃការរស់នៅ បានជួបជុំជាមួយនឹងអ្នកម្ដាយនោះទេ តើមានអ្នកណាទៅដែលមានខ្សែជីវិតនិងវាសនាដូចជារូបខ្ញុំ? តើអ្នកណាទៅដែលរស់នៅកំព្រាក្រខ្សត់អត់ឃ្លានដូចជារូបខ្ញុំ?ប្រហែលជាគ្មានទេមើលទៅ តើហេតុអ្វីបានជាទ្វីបលោកនេះមើលទៅដូចតូចចង្អៀតម្ល៉េះ? ហាក់បីដូចជាអគតិ សម្រាប់រូបខ្ញុំយ៉ាងនេះ ហេតុម្ដេចក៏មិន ប្រហារសម្លាប់ឱ្យស្លាប់ទាំងបីទៅ មិនគួរណាឆក់យកតែជីវិតមួយទុកជីវិតពីរ តើឱ្យរស់នៅធ្វើអ្វី? គិតទៅដូចជាមិនស័ក្តិសមសោះ។

ឱ!ភពផែនដី សែនឃោរឃៅណាស់ ពង្រាត់បង្រាសម្ដាយកូនឱ្យព្រាត់គ្នា ដែលទើបនឹងកើតក្លាយទៅជាកំព្រា រងទុក្ខវេទនា ជាមួយនឹងឪពុក ទឹកភ្នែកឪពុកស្រក់ហូរមិនដាច់ មច្ចុមកផ្ដាច់ឆក់យកសង្ខារ ឱ្យស្លាប់មរណា ចោលកូននៅតូចទាំងដែលគ្នា មិនទាន់ដឹងក្ដី ឪឃើញមុខកូនឪស្រក់ទឹកភ្នែក ក្ដុកក្ដួល



www.elibraryofcambodia.org

អ្នកអាក់ពន់ពេក ឃើញស្លាប់ទាំងស្រស់ ឪសែនស្រណោះទៅដល់កូនតូចដែល គ្មាទើបតែនឹងកើត មិនបានឃើញមុខម្តាយយ៉ាងណានៅឡើយ នោះទេ។

កូនអើយ កូនសំឡាញ់ពុក កូននៅតូចណាស់ ពីថ្ងៃនេះទៅមុខ កូនត្រូវកំព្រាមាតា ខ្វះភាពកក់ក្តៅពីទ្រូងមាតា រស់នៅអនាថាជាមួយឪពុក។

កូនអើយគេងទៅកូននៅនឹងពុក
កូនខានជួបមុខរូបម្តាយទៀតហើយ
ពីថ្ងៃនេះទៅណាកូនត្រាណត្រើយ
កូនកុំយំឡើយអាសូរទ្រូងឪ។
កូនអើយអើយកូនៗនៅតូចណាស់
ស្គាល់ម៉ែមិនច្បាស់មុខយ៉ាងណាទៅ
កូនកើតមកភ្លាមកណ្តាលយប់ជ្រៅ
កូនអើយកូនពៅកូននៅនឹងបា។



www.elibraryofcambodia.org

កូនយំង៉ាៗចិន្តាក្តុកក្តួល

ម៉ែចាប់មិនស្រួលមិនបានរក្សា

ថៃទាំរូបកូនទៅពៅកនិដ្ឋា

មច្ចុប្រហារស្លាប់ចោលកូនហើយ។

ជីវិត កំព្រារស់នៅគ្មានម្តាយ មានតែឪពុក តើអ្នកទាំងអស់គ្នាយល់យ៉ាងណា? តើខ្ញុំមានអារម្មណ៍បែបណា នៅពេលដែលខ្ញុំធំដឹងក្តី? តើចុះអ្នកវិញមានអារម្មណ៍បែបណាដែរ? ប្រសិនបើអ្នកបានជួបប្រទះនូវរឿងរ៉ាវបែបនេះ ដូចជារូបខ្ញុំ។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**

**មនុស្សស្លាប់ព្រោះទ្រព្យ ត្រីចាប់ព្រោះតែនុយ**
**បើរស់គេថាឈ្មោះស្អុយ រស់ព្រោះដើម្បីលុយ**
**គឺរស់ឥតខ្លឹមសារ។**



www.elibraryofcambodia.org

# ១០.សូម្បីតែកូនធំ កូននៅតែជាកូនរបស់ពុក

រសៀលជ្រាលជ្រេ ថ្ងៃរេទន់ទេរទាបទៅ ទុកបន្សល់នូវភាពអន្ធការបន្តិចម្តងៗរហូត ដល់បាត់បង់សម្រស់អស់ពីទ្វីបលោកា ដោយគ្មានអាល័យ រីឯស្បៃងងឹតនៃរាត្រីកាល ក៏ធ្វើដំណើរឈានចូលមកដល់យប់យ៉ាងសន្សឹមៗ ពពករសាត់ផាត់តាមខ្យល់ខ្ចួលខ្ចាញ់ត្របាញ់ចូលគ្នា មេឃខ្មៅងងឹតសូន្យឈឹង មីរដេរដាស បក្សាបក្សីហើរចូលទ្រនំ គ្មានសេសសល់ ប៉ុន្តែបញ្ហាកង្វល់ ទាំងឡាយរបស់ពុក ក៏មិនទាន់បានរសាត់ បាត់នៅឡើយដែរ ។

កណ្តាលអធ្រាត្រ ឪដេកមិនលក់ ចិត្តចេះតែគិត ទ្រូងចេះតែភ័យ ចិត្តចេះតែព្រួយ អារម្មណ៍ចេះតែខ្វល់ ចេះតែខ្លាចកូនមានគ្រោះថ្នាក់ ឬមានបញ្ហា។

កូនមាសឪពុក តើកូនមានដឹងទេ?ថានៅឯផ្ទះ គឺមានបុរសម្នាក់ដែលកំពុងទន្ទឹងរង់ចាំកូន តើពេលនេះកូនកំពុងតែធ្វើអ្វី?



www.elibraryofcambodia.org

ហើយនៅទីណា? តើកូនមានដឹងទេថាទ្រូងរបស់ឪពុកកំពុងព្រួយបារម្ភ ពីកូនកម្រិតណា? ឥឡូវ មេឃក៏ស្រឡះហើយដែរ ថ្ងៃ ១៥ កើត ពេញបូណ៌មី ដួងព្រះខែក៏បង្ហាញខ្លួន ចរចេញយាត្រា បញ្ចេញពន្លឺភ្លឺព្រោងៗពីលើអាកាស ផ្ទៃមេឃក៏ស្រឡះពន្លឺរស្មី នៃដួងព្រះខែក៏រះយ៉ាងសន្សឹមៗ កាត់ផ្ទាំងនៃដុំពពកវាយោក៏បក់ជាត់រសាត់ ទៅដោយគ្មានគោលដៅ ដោយគ្មានត្រឡប់ រឿងរ៉ាវទាំងឡាយរបស់ពុក ចេះតែមានមិនចេះអស់មិនចេះហើយ អស់រឿងនេះចូលដល់រឿងនោះ។

អស់ពីរឿងគ្រួសារចូលដល់រឿងកូន គឺរឿងក្ដីក្ដាំប្ដឹងផ្ដល់រឿងទាស់ទែងប្រកាប់ប្រចាក់គ្នា ពេលដើរលេងយប់ព្រលប់សេពគប់ជាមួយមិត្ត សុទ្ធសឹងតែជាអ្នកហ៊ាន ស្រែកឃ្លានធ្វើបំពានដោយគ្មានញញើតដៃ ដោយអាងកម្លាំង តតាំងនាំរឿងរ៉ាវមកឱ្យពុកឥតឈប់ឈរ អស់ពីរឿងមួយចូលរឿងមួយ មិនចេះចប់មិនចេះហើយ ។



www.elibraryofcambodia.org

កូនអើយ ពេលនេះរូបកូនធំហើយ ពុកសង្ឃឹមថា នៅពេលដែលកូនធំ កូននឹងចេះគិតនិងចេះជួយរំលែក នូវសេចក្ដីទុក្ខលំបាករបស់ឪពុកបានខ្លះ បែរជាផ្ទុយស្រឡះ ពីអ្វីដែលឪពុកបានធ្លាប់គិត ពីអ្វីដែលឪពុកធ្លាប់ស្រមៃ ក្ដីសង្ឃឹមរបស់ឪពុក ត្រូវបានរលាយសាបសូន្យ រាល់បំណងប្រាថ្នារបស់ឪពុកបានត្រឹមខកចិត្តទាំងហាមិនរួច ស្ដីមិនកើត ព្រោះថារូបកូនធំហើយ ប្រដៅលែងបាន ថាលែងតាម ស្ដីលែងស្ដាប់ ដឹងអីថាកូនធំប៉ុណ្ណឹងហើយ បែរជាធ្វើខ្លួនដូចឃ្លោកអីុចឹង។

កូនមិនចេះគិតអ្វីទាល់តែសោះ ចេះតែសុំលុយ បើពុកមិនឱ្យកូនៗធ្វើបាបពុក កូនគំហកគំរាមឪពុក ទៅដើរលេងសប្បាយ ស៊ីចាយហ៊ឹហា ចាយសុទ្ធដុល្លារ ញើសឈាមពុក ប៉ាវមិត្រភក្ដិផឹកសុរា ដើរស៊ីផឹកគ្មានពេលទំនេរ ដើម្បីយកចិត្តផ្គាប់ផ្គុនបំពេញបំណង មិត្តភឿនសេពគ្រឿងស្រវឹង ផ្ដេសផ្ដាសរាំធុងបាស់ បង្កជម្លោះ ប្រកាប់ប្រចាក់គ្នា នៅដល់យប់



www.elibraryofcambodia.org

អធ្រាត្រ មានពេលខ្លះកូន ត្រូវបង់ត្រូវសង ដល់គូភាគីម្ខាងទៀតពីបទបង្ករបួសស្នាម ឪពុកត្រូវលក់ដីលក់ផ្ទះឬដីស្រែចម្ការដើម្បីបង្គ្រប់សំណងសងគេ បើមិនដូច្នោះ ត្រូវគេចាប់ដាក់គុកដាក់ច្រវាក់ តើឪពុកឯណាដាច់ចិត្តនោះ? មិនអាសូរដល់ទ្រូងឪពុកបន្តិចបន្តួចសោះអ៊ីចឹងណាកូន។

កូនគិតតែពីធ្វើរឿងអំពល់មកឱ្យពុក មិនចេះឈប់ឈរ តើឪពុកណាទៅដែលមិនគិតពីកូន? តើឪពុកណាទៅដែលមិនបារម្ភពីកូន? ណាមួយខ្វល់ពីរឿងរកស៊ី ជួនរកបានជួនរកមិនបាន ណាមួយខ្វល់ពីរឿងកូនមិនស្តាប់បង្គាប់ ព្រួយចិត្តណាស់ស្ទើរតែប្រេះដើមទ្រូងទៅហើយ គិតដល់កូនគ្រប់វេលាព្រោះកូនចេញបាត់ៗពីផ្ទះមិនដឹងជាទៅណា ។

រាត្រីយប់នេះ ភ្លឺល្អណាស់ តែកម្មក្រាស់ ពុកកំពុងតែចាំមើលផ្លូវកូន កណ្តាលអធ្រាត្រស្ងប់ស្ងាត់ សព្វសត្វចូលនិទ្រាគ្មានសល់ រសាប់រសល់មិនដឹងថា ពេលណាទើបកូនត្រឡប់



www.elibraryofcambodia.org

ចូលផ្ទះនោះទេ ចាំបាត់ៗចាំស្វាត់សូន្យឈឹង ចាំកូនព្រលឹង ចាំមួយរាត្រីរហូតទល់ភ្លឺ នៅតែមិនឃើញស្រមោល កូនវិលវិញ ពុកខ្លាចកូនមានរឿងអ្វី ឬក៏មានគ្រោះថ្នាក់ មួយយប់ទល់ភ្លឺពុកមិនបាន ដេកព្រោះតែរង់ចាំមើលផ្លូវកូន។

កូនពុក តើមួយយប់ទល់ភ្លឺកូនទៅទីណា? ហេតុអ្វីបានជាពាក្យមួយម៉ាត់ ក៏កូនមិនឱ្យពុកដឹងផងនោះ តើកូនមានដឹងទេ? ថាក្នុងទ្រូងរបស់ពុកនេះ ព្រួយបារម្ភពីកូន ពុកមិនដែលភ្លេចពីកូន តើកូនមានដឹងទេថា ការខិតខំប្រឹងប្រែងសព្វថ្ងៃនេះ ធ្វើដើម្បីអ្នកណា ពុកមិនធ្វើដើម្បីខ្លួនឯងទេ ពុកមិនដែលគិតទេពីខ្លួនឯង ពុកធ្វើដើម្បីកូន តើកូនមានយល់ដល់ចិត្តពុកខ្លះទេ ប្រហែលជាគ្មានទេមើលទៅ កូនគិតតែពីការសប្បាយប៉ុណ្ណោះ កូនមិនដែលគិតពីពុកទេ ទាល់តែកូនមានបញ្ហា ឬមានរឿងអ្វីដែលដោះស្រាយមិនចេញធ្វើមិនកើត ពេលនោះហើយ ជាពេលមករកឱ្យពុកជួយ នេះឬទឹកចិត្តរបស់កូន?។



www.elibraryofcambodia.org

ចាំបាត់ៗចាំដំណឹងកូន រាត្រីស្ងាត់សូន្យកូននៅទីណា
វិលវិញមកកូនពៅកនិដ្ឋា ខុសត្រូវម្តេចម្តាឪមិនថាអ្វី។
ចាំអើយៗចាំចាំមើលតែផ្លូវ អធ្រាត្រយប់ជ្រៅមិនឃើញវិលវ៉ៃ
កូនចេញបាត់ៗស្ងាត់គ្មានស្រដី ពាក្យពេចន៍សម្តីក៏កូនមិនប្រាប់។
ចាំអើយៗចាំៗទាំងផ្សារភ្នែក បារម្ភពន់ពេកក្នុងទ្រូងរសាប់
ស៊ូអង្គុយចាំឱ្យកូនមកឆាប់ ឪឈឺចុកចាប់ទៅប្រាប់អ្នកណា។
ចាំពេលវេលាឱ្យកូនដឹងខ្លួន ហេតុអ្វីមាសស្ងួនមិនភ្ញាក់អាត្មា
អាសូរទ្រូងឪដែលឈឺខ្លោចផ្សា ស្ទើរប្រេះឱរាឬកពារសែនយ៉ាប់។
ចាំបាត់ៗចាំកូនទល់ភ្លឺ ព្រឹកឡើងបញ្ឈឺឬចង់ឱ្យស្លាប់
ទូន្មានប្រាប់កូនតែគេមិនស្តាប់ ពុកសែនឈឺចាប់ព្រោះកូនពន្លក។
ចាំហើយចាំទៀតចាំគ្មានពេលភ្លេច ឪចាំជានិច្ចតែងតែហៅរក
តើនៅពេលណាទើបកូនវិលមក កូនដេកឪយកភួយដណ្តប់ឱ្យ។
ចាំបាត់ៗដោយគ្មានដំណឹង យប់ងងឹតឈឹងអធ្រាត្រទៅហើយ
មិនឃើញមុខកូនទុក្ខឪពុំស្បើយ ដេកមិនលក់ឡើយឪនៅរង់ចាំ។



www.elibraryofcambodia.org

មាន់រងាវម្តងនួនល្អងមាសស្នេហ៍ សម្លឹងមើលខែដួងចិត្តប្រេះស្រាំ
មេឃភ្លឺស្រាងៗភ្នែកឪរកាំ មានកូនរងកម្មចាំកូនទល់ភ្លឺ។
មើលទៅកូនគេមិនពិបាកស្តី តើចុះហេតុអ្វីកូនខ្ញុំនេះឌឺ
និយាយមិនស្តាប់វាធ្វើមិនឮ ថែមទាំងបញ្ឈឺបញ្ចោះមកវិញ។

កូនអើយ សូមកូនអាណិតអាសូរ ដល់ទ្រូងឪពុកផងណាកូន នៅពេលដែលកូនទៅណាមកណា ពុកមិនថាទេ សូមឱ្យតែកូន ស្រដីប្រាប់ពុកមួយម៉ាត់ប៉ុណ្ណឹង ពុកសប្បាយចិត្តណាស់ហើយណាកូនណា ពុកសូមចិត្តកូនប៉ុណ្ណឹង តើបានទេកុំឱ្យពុកព្រួយបារម្ភពីកូនខ្លាំងពេក កុំឱ្យកូនទៅណាមកណា បាត់ស្ងាត់សូន្យ ដោយគ្មានដំណឹងទាល់តែសោះ ពុកខ្លាចកូនមានរឿងអ្វីឬមានគ្រោះថ្នាក់ នៅក្នុងរបស់ចិត្តពុក ព្រួយបារម្ភពីកូន ពុកតែងតែ គិតដល់កូនជានិច្ចគ្រប់ពេលវេលា ។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

## ១១.សប្បាយក្លាយជាទុក្ខ

បានដឹងថាកូនត្រូវគេចាប់ មានគេមកប្រាប់ដល់រូបឪ
កណ្ដាលអធ្រាត្រយប់ក៏ជ្រៅ តើកូនពាលពៅធ្វើអ្វីខុស?។
កាលពីពេលល្ងាចឪទូន្មាន ម្ដេចធ្វើបំពានណាកូនប្រុស
ហូបបាយមិនទាន់កូនក៏ចុះ កូនមិនសន្ដោសទ្រូងឪពុក។
ហូបបាយសឹងតែមិនត្រង់មាត់ ឪបានពោលឃាត់នៅនឹងមុខ
ប្រយ័ត្នបញ្ហាអំពល់ទុក្ខ គេចាប់ដាក់គុកគ្មានអ្វីលស់។
គេចាប់រូបកូនឈឺទ្រូងឪ ម្ដេចកូនពាលពៅមិនគិតសោះ
ពុកសែនអាណិតចិត្តស្រណោះ បានអ្វីទៅដោះឱ្យរួចខ្លួន។
បើគ្រួសារក្រគ្មានទ្រព្យអ្វី មានតែលក់ដីកេរ្តិ៍ជីដូន។
ចងការខ្ចីបុលពីបងប្អូន ព្រោះដើម្បីកូនឪមិនគិត។
មាត់ថាមិនគិតតែចិត្តខ្វល់ ទ្រូងរែងអំពល់ខ្វល់ក្នុងចិត្ត
ឪដេកមិនលក់កូនប្រព្រឹត្ត អារម្មណ៍ភ័យភិតកូនយ៉ាងណា។
គេចាប់រូបកូនទៅដាក់ឃុំ ត្រូវគេវាយដំដល់កាយា
ក្នុងចិត្តសែនឈឺទ្រូងខ្លោចផ្សា ឪស្រក់នេត្រាពេលឃើញភក្ត្រ។



www.elibraryofcambodia.org

ឪលក់ខ្មៅចខ្ចីផ្ទះសម្បែង    ដោយសារកូនឯងណាវរលក្ខណ៍
គ្រួសារសព្វថ្ងៃគឺជំពាក់    លុយកាក់មាសប្រាក់គេវណ្ណក។
ធ្វើម្តេចរូបកូនមិនស្តាប់ឪ    ឃើញទេឥឡូវកូនជើងល្អ
ឪស្តីឪថាហើយអង្វរ    រឿងរ៉ាវរីកវរធ្លាក់ដល់ពុក។
នេះជាទង្វើកូនប្រព្រឹត្ត    ជួបជុំមូលមិត្តបំពេញមុខ
គ្រួសារទាំងអស់នៅមិនសុខ    បញ្ហាស្មាញស្មុគដល់ម៉ែឪ។
គេហៅពុកម៉ែទៅព្រមាន    ញាតិគេទិតៀនមិនប្រដៅ
បណ្តោយឱ្យកូនដើរខុសផ្លូវ    អំពើល្ងង់ខ្លៅជនពាលា។
រូបកូនសប្បាយចាយអឹងកង    ចេញដើរម្តងៗជួបជុំគ្នា
ដើរយប់ដើរថ្ងៃគ្មានលស់គ្រា    មិនបាននិទ្រាស្រែកឡូឡា។
រូបកូនដើរលេងសប្បាយណាស់ ផឹកស្រារាំបាសប្រើហិង្សា
ប៉ាវមិត្តផិតឆ្វាយសុទ្ធដុល្លារ    បង្កបញ្ហាត្រូវជាប់ឃុំ។
កណ្តាលវង់បាសប្រើទោសៈ    កូនវាយកាប់ចាក់កើតរឿងធំ
បង្កជម្លោះចងគំនុំ    ឪកើតទុក្ខធំដោយសារកូន។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**



www.elibraryofcambodia.org

## ១២.ពុកម៉ែស្រក់ទឹកភ្នែកដោយសារកូន

ដុំនោរត្រជាក់ធ្លាក់មករំភើយ បោកបក់ទៅតាមខ្សែនៃស្បៃវាតា នៅក្នុងពេលនារាត្រីកាល ដ៏សែនស្ងាត់ជ្រងំ លាយឡំជាមួយនឹងសំឡេងសត្វយំ ទឹកសន្សើមក៏ធ្លាក់ចុះ មកបន្តិចម្តងៗ រហូតដល់កណ្តាលអធ្រាត្រ។

សម្លឹងមើលទៅមេឃ ឃើញដួងព្រះចន្ទ្រា ដែលកំពុងតែរះពេញវង់ បញ្ចេញពន្លឺរស្មីភ្លឺត្រចះច្រចង់ នៅលើផ្ទៃនៃមេឃាកំព្រាឯកោអនាថាតែឯង កណ្តោចកណ្តែងកណ្តាលនៅ លើផ្ទៃនៃវេហា។

យប់កាន់តែជ្រៅ ខ្យល់បក់កាន់តែខ្លាំង រាត្រីកាន់តែស្ងាត់ពពករសោត់បាំងបិទដួងព្រះចន្ទ្រា ដែលខំប្រឹងរះ បែរជួបប្រទះនឹងមេឃខ្មៅទៅវិញ ដោយគ្មានអ្នកជួយ ខ្លួនមួយតែម្នាក់ឯង។

ដុំពពកខ្មៅ មីរដេរដាស ក៏មានកាន់តែច្រើនទៅៗ ធ្វើឱ្យដុំពពកខ្មៅខ្ទួលខ្មាញ់ ត្របាញ់ចូលគ្នា ធ្វើឱ្យដួងព្រះចន្ទ្រា ដែល



www.elibraryofcambodia.org

កំពុងតែរះ បញ្ចេញពន្លឺភ្លឺត្រចះត្រចង់ ប្រែក្លាយទៅជាងងឹត មិនអាចបញ្ចេញពន្លឺរស្មីបាន។

មិនយូរប៉ុន្មាន ដុំពពកខ្មៅទាំងឡាយ បានធ្វើឱ្យមេឃក្លាយទៅជាភ្លៀង មួយមេយ៉ាងធំក៏ធ្លាក់ចុះមកទាំងកណ្ដាលរាត្រី ទៅវិញ ដោយនឹកស្មានមិនដល់។

យប់កាន់តែជ្រៅ ភ្លៀងកាន់តែខ្លាំង ផ្លេកបន្ទោរព្រាក់ៗ លាយឡំជាមួយនឹងផ្គររន្ទះ ពុកម៉ែអង្គុយរង់ចាំមើលតែផ្លូវកូន យ៉ាងអន្ទះសា យ៉ាងក្រៃលែងនៅក្នុងចិត្ត ព្រោះពុកម៉ែកំពុងតែព្រួយបារម្ភពីសុវត្ថិភាពរបស់កូន តើនៅក្នុងពេលនេះកូនកំពុងតែធ្វើអ្វី?តើកូនមានដឹងទេ?ថានៅឯផ្ទះឯណោះ គឺមានបុរសម្នាក់និងស្ត្រីម្នាក់ ដែលមានវ័យចំណាស់ ចាស់ជរាទ្រុឌទ្រោមកម្លាំង គឺកំពុងតែអង្គុយនៅរង់ចាំកូននៅឯផ្ទះ យ៉ាងតក់ក្រហល់? ចង់ដឹងពីដំណឹង និងសុខទុក្ខរបស់កូន មិនដឹងជាពេលនេះកូននៅទីណានោះទេ ព្រោះថា កូនបានចេញទៅពីផ្ទះបាត់ៗ តាំងពី



www.elibraryofcambodia.org

ក្បាលព្រលប់ម្លេះ មិនទាន់ឃើញកូនវិលចូលផ្ទះវិញនោះទេ បាត់ដំណឹងសូន្យឈឹង យប់ងងឹតយ៉ាងនេះទៅហើយ តើកូនមានរឿងអ្វី?

អធ្រាត្រណាស់ទៅហើយ ហេតុម្ដេចក៏នៅតែមិនឃើញកូនវិលមកផ្ទះវិញយ៉ាងនេះ ឬមួយកូនមានរឿងអ្វីបានជាមិនឃើញដូច្នេះ តើកូនមានរឿងអ្វី?ៗ

កូនមាសឪពុក ពេលនេះរូបកូនធំហើយ មិនមែននៅក្មេងទៀតទេ ហេតុអ្វីបានជាកូន គិតតែពីរឿងដើរលេង សប្បាយស៊ីចាយហ៊ឺហា ចាយសុទ្ធតែដុល្លារ ជក់បារី ផឹកស្រាកូនចេះគ្រប់មុខ ល្បែងអបាយមុខគ្រប់យ៉ាង ជួបជុំមិត្តភក្តិ ជារឿងរាល់ថ្ងៃមួយថ្ងៃៗកូនដើរដល់យប់អធ្រាត្រ កូនមិនដែលគិតអាណិតអាសូរ ដល់ទ្រូងឪពុកទ្រូងម្ដាយបន្តិចបន្តួចសោះឡើយ កូនគិតតែពីរឿងមិត្តភក្តិ ជួបជុំគ្នា ផឹកស៊ីស្រីញីអូនបងស្មើរតែ



www.elibraryofcambodia.org

រៀងរាល់ថ្ងៃ គឺកូនតែងតែគិតថា តើនៅក្នុងថ្ងៃស្អែកនេះ? តើពួកយើងត្រូវទៅផឹកស៊ីនៅទីកន្លែងឯណា?

កូនមិនដែលនឹកគិត អាណិតទៅដល់ដួងចិត្ត នៃទ្រូងឪពុកម្ដាយបន្តិចសោះឡើយ កូនធ្វើបាបចិត្តម៉ែ ឱ្យម៉ែអង្គុយរង់ចាំមើលផ្លូវកូន រហូតទល់ភ្លឺ ម៉ែសម្លឹងមើលទៅមុខផ្ទះ រង់ចាំស្ដាប់ស្នូរសម្រឹបជើងរបស់កូន ទាំងចិត្តភ័យព្រួយបារម្ភពីកូន ទឹកភ្នែករបស់ម៉ែ ហូរធ្លាក់ចុះមកដោយមិនដឹងខ្លួន នៅពេលដែលម៉ែនឹកឃើញ អំពីទង្វើរបស់កូនកាលណា ម៉ែខ្លោចផ្សាកាលនោះ។

ម៉ែឆ្អែត ឆ្អែតចិត្តនឹងកូនរបស់ម៉ែ រហូតដល់ម៉ែហាស្ដីមិនកើត ហាស្លាក់ខ្ទាក់ស្លែង ស្ដោះលើទ្រូងឯង ម៉ែដេកឱបទុក្ខតែម្នាក់ឯង លាក់ទុកនៅក្នុងដើមទ្រូងរបស់ម៉ែ និយាយទៅវាមិនកើត កូនគេមិនស្ដាប់ដដែល ដូច្នេះម៉ែបានត្រឹមតែសម្លឹងមើលមុខកូន ម៉ែស្រែកអង្វរសូមឱ្យ កូនអាណិតមេត្តាដល់ឪវាឪពុកម្ដាយផង។



www.elibraryofcambodia.org

កូនអើយ ឪពុកនិងម្ដាយ មិនដែលខឹងមានគំនុំគុំកួន នឹង
រូបកូនម្ដងណាឡើយ ប៉ុន្តែនៅពេលដែលពុកម៉ែទូន្មាន ប្រៀន
ប្រដៅអប់រំកូនមិនបានល្អ ម៉ែតែងតូចចិត្តខឹងនឹងខ្លួនឯង ដែល
អប់រំកូនមិនបានល្អដូចកូនគេដទៃ នេះគឺជាកំហុសរបស់ម៉ែ ម៉ែ
គ្មានអ្វីយកមកលុបលាងនូវទោសកំហុសរបស់ម៉ែនោះទេ មាន
តែទឹកភ្នែកនេះទេ ដែលអាចជួយរំលែកនូវសេចក្ដីទុក្ខ របស់ម៉ែ
បាន ក្រែងលោកូនអាណិតម៉ែ អាចបង្វែរចិត្តកូនឱ្យក្លាយជា
កូនល្អរបស់ពុកហើយនិងម៉ែ តែការសង្ឃឹមបានត្រឹមខកចិត្ត។

ទោះបីជាម៉ែ យំៗរហូតដល់ក្ស័យប្រាណទៀត ក៏កូននៅ
តែមិនព្រមកែប្រែផ្លាស់ប្ដូរគំនិត កូនមិនខ្វាយខ្វល់ កូននៅតែមិន
អើពើ នូវសេចក្ដីទុក្ខលំបាករបស់ម៉ែឡើយ កូនគិតតែពីខ្លួន
ឯងប៉ុណ្ណោះ។

កូនមិនដែលធ្វើរឿងអ្វីមួយ ឱ្យម៉ែសប្បាយចិត្តម្ដងណា
ឡើយ កូនធ្វើឱ្យលំបាកចិត្ត កូនធ្វើឱ្យម៉ែស្រក់ទឹកភ្នែក កូនធ្វើឱ្យ



www.elibraryofcambodia.org

ម៉ែភ័យ ម៉ែព្រួយបារម្ភពីកូន ម៉ែនឿយទាំងកាយនឿយទាំងចិត្ត គិតពីរឿងរកស៊ី ដើម្បីយកប្រាក់មកចិញ្ចឹមជីវិត ទាំងលំបាកវេទនា ក្នុងការចិញ្ចឹមកូនឱ្យធំដឹងក្តី ម៉ែសង្ឃឹមថាកូនអាចជួយរំលែកនូវកិច្ចការងារ ជួយជំនួសដៃ ជំនួសជើងរបស់ពុកម៉ែបានខ្លះ ដឹងអីនៅពេលដែលកូនធំឡើងហើយ ការស្រមៃនិងការសង្ឃឹម មិនដូចបំណងទាល់តែសោះ កូនកាន់តែធំម៉ែកាន់តែលំបាក តើកូនមានអាណិតម៉ែខ្លះទេ?

បើកូនមិនអាណិតម៉ែ គួរតែមាសស្នេហ៍គិតខ្លួនឯងផងណា ព្រោះថា កូនកំពុងប្រលែងលេង ជាមួយនឹងល្បែងវិនាស ដូចមមាចឃើញភ្លើងហើរប្រលែងលេង ជាមួយនឹងភ្លើងយ៉ាងសប្បាយរីករាយដោយមិនដឹងខ្លួន ថាខ្លួនត្រូវស្លាប់ ដោយត្រូវភ្លើងឆេះស្លាប់នោះទេ ចេះតែសប្បាយៗទៅយ៉ាងនេះ។

កូនអើយ មនុស្សយើងក៏ដូចគ្នា កាលណាបើកូន សប្បាយកុំសប្បាយហួសហេតុពេក កុំសប្បាយដល់ភ្លេចខ្លួន ភ្លេចស្មារតី



www.elibraryofcambodia.org

នោះណាកូន ដូចពាក្យគេលើកឡើងថា សប្បាយគូ នឹងទុក្ខ ស្រណុកគូនឹងវេទនា ចូរពិចារណាឱ្យបានគ្រប់គ្នាណាកូន។

ពុកស្រក់ទឹកភ្នែកសង្វេគក្នុងទ្រូង
ស្ទើរតាំងបេះដូងហើយណាមាសមេ
ខ្លួនកាន់តែចាស់វ័យកាន់តែជ្រេ
រស់មិនយូរទេណាកូនព្រលឹង។
ពុកសែនក្តុកក្តួលអួលណែនឱរា
ណែនាំស្តីថាកូនមានចិត្តខឹង
មិនព្រមស្តាប់សោះក្រោកស្ទុះចេញរឹង
ដើរធ្វើមិនដឹងមិនខ្វីមាត់ក។
ពុកស្តីម៉ែថាណែនាំប្រាប់ផ្លូវ
ទូន្មានប្រដៅចង់ឱ្យកូនល្អ
ស្រឡាញ់ស្មគ្រស្មោះដួងចិត្តស្មោះសរ
ឪសូមអង្វរសូមកូនស្តាប់សិន។



www.elibraryofcambodia.org

ពុកម៉ែនិយាយកូនចេញទៅបាត់
សម្ដីមួយម៉ាត់ថាដូចសុបិន
ពុកសែនខូចចិត្តណាស់កូនមាសឆ្អិន
ហេតុម្ដេចកូនមិនព្រមស្ដាប់ម៉ែសោះ។
សម្ដីពុកម៉ែរាងល្វីងបន្តិច
ឥតមានកលល្បិចលាក់ទុកគៀនកោះ
ពេលកូនធ្វើខុសមុខម៉ែមិនស្រស់
ម៉ែសែនស្រណោះដល់កូនមាសស្និទ្ធ។
ម៉ែចង់ឱ្យកូនចេះគិតវែងឆ្ងាយ
ពេលអត់ពីម្ដាយរៀបចំជីវិត
រស់ក្នុងសង្គមជុំដោយញាតិមិត្ត
ដេកដើរប្រព្រឹត្តគិតធ្វើឱ្យសម។
សម្ដីសំដៅកូនឱ្យសុភាព
ដើរខិនឱ្យទាបកិត្តិយសឧត្តម



www.elibraryofcambodia.org

បើចេញរកស៊ីកូនកុំបន្លំ
រឿងតូចកុំផ្សំផ្ដុំទៅជាភ្លើង។
ចំណែកជីវិតមានគ្រប់រសជាតិ
ចេះគោរពញាតិកុំធ្វើឫកឆ្មើង
គេសួររកពូជគេលើកតម្កើង
ហើយគេដំឡើងថាជាកូនល្អ។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

## ១៣.ពុកម៉ែនៅរស់កូនឈ្លោះដណ្តើមកេរ្តិ៍

ជុំនោររាត្រីរវៃយំពេលល្ងាច សុរិយាទន់ទាបរៀបអស្តង្គត ខ្យល់បក់រំភើយឆ្លើយប្រាប់ថាយប់ លាន់ឮគ្រលួចក្ងួចបោកបក់តាមខ្សែ នៃស្បៃវាយោរំភើយៗ ទឹកសន្សើមក៏ធ្លាក់នារាត្រីកាលគួរឱ្យស្រណោះ ដល់រឿងដើម កាលគ្រាក្រកូនល្អគ្រប់យ៉ាងកាលដែលកូននៅតូចៗ កូនចេះស្រឡាញ់ចេះអាណិត មានចិត្តសន្តោសប្រណី កូនមានអ្វីក៏កូនចេះចែករំលែកបងចេះចែកប្អូនស្រឡាញ់គ្នារស់ជួបជុំគ្នា ក្នុងដំបូលផ្ទះតែមួយ មិនដែលធ្វើឱ្យពុកម៉ែព្រួយលំបាកចិត្តដោយសារកូនឡើយ ថ្ងៃខ្លះប្អូនធ្វើខុសបងចេះអធ្យាស្រ័យអភ័យទោសអត់ឱនឱ្យប្អូន ក្នុងនាមកូន ជាកូនច្បងនៃគ្រួសារ ពុកម៉ែពេលដែលឃើញកូនៗចេះស្រឡាញ់គ្នាយ៉ាងនេះ ពុកម៉ែសប្បាយចិត្តណាស់។



www.elibraryofcambodia.org

ពុកម៉ែតែងតែមាន សេចក្ដីសង្ឃឹម ញញឹមទុកនៅក្នុងចិត្ត យ៉ាងមុតមាំថា បើអត់ពីពុកពីម្ដាយទៅ ក្នុងនាមកូនជាកូនច្បង ត្រូវស្រឡាញ់ប្អូនៗ មើលថែប្អូនជំនួសម៉ែ ពេលដែលម៉ែមិននៅ។

អ្វីៗទាំងអស់ ដែលម៉ែធ្លាប់គិតធ្លាប់សង្ឃឹម បានត្រឹមខកចិត្ត ពេលនេះរូបកូនធំរៀងៗខ្លួនហើយ កូនលែងគិតថាជាបងប្អូន សាច់ឈាមឯងទៀតហើយ កូនគិតតែពីចង់មានចង់បាន គិតតែពីគ្រួសាររបស់កូនប៉ុណ្ណោះ សូម្បីតែម៉ែក៏កូនមិនគិតផង។

កូនអើយ កាលដែលកូននៅតូចៗ កូនចេះស្រឡាញ់បងប្អូន ចេះស្ដាប់ដំបូន្មាន ដែលពុកម៉ែទូន្មានប្រាប់ដល់កូន គ្រប់ពេលគ្រប់ពាក្យ នៅពេលដែលម៉ែនិយាយ កូនស្ដាប់ម៉ែណាស់។

តែពេលឥឡូវ កូនធំហើយធំហួសនឹងពុកម៉ែនិយាយបាន កូនមានស្លាបហើររៀងៗខ្លួន ទោះបីជាម៉ែនិយាយ ដល់ដាច់បំពង់កទៀត ក៏កូនមិនស្ដាប់ម៉ែដែរ កូនលែងស្ដាប់ម៉ែទៀតហើយ កូនស្ដាប់តែប្រពន្ធរបស់កូនប៉ុណ្ណោះ។



www.elibraryofcambodia.org

ហេតុអ្វីក៏ធ្វើដូច្នេះកូន ម្ដេចក៏មិនអាសូរ ឪពុកខ្លះផងកូនពុក ខំប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិ តាំងពីក្មេងរហូតដល់ចាស់ សក់ស្កូវពេញក្បាលទៅហើយ ម្ដេចឡើយក៏កូនមិនអាណិតទ្រូង ឪពុកម្ដាយបន្តិចបន្តួចសោះអ៊ីចឹង ទ្រព្យសម្បត្តិ ដែលឪពុកម្ដាយមានសព្វថ្ងៃនេះ គឺពុកទុកចែកឱ្យកូនៗគ្រប់គ្នា។

ចុះហេតុអ្វី បានជាកូនមកទាមទារ ចង់បានកេរ្ដិ៍មរតកពីម៉ែទាំងដែលពុកម៉ែ មិនទាន់ស្លាប់បាត់បង់ជីវិតផងនោះ កូនមកទាមទារយករៀងៗខ្លួន បងក៏ទារកូនប្អូនទាមទារគ្រប់ៗតែគ្នាឱ្យពុកម៉ែគិតយ៉ាងណា កូនមកទាមទារយកដីស្រែចម្ការ ច្បារដំណាំ ផ្ទះសម្បែងដែលពុកម៉ែ កំពុងតែរស់នៅរាល់ថ្ងៃនេះ ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់កូន ។

ឥឡូវនេះ កូនចង់បានអ្វីកូនយកទៅចុះ សូមកូនកុំទាស់គ្នាតែពេលនេះ កូនចាប់ផ្ដើមទាស់គ្នា ប្ដឹងផ្ដល់ទាមទារយកកេរ្ដិ៍មរតកចង់ឈ្នះចង់ចាញ់ ដោយគ្មានយោគយល់ ថាជាបងប្អូន



www.elibraryofcambodia.org

ឯងឬសាច់ឈាមឯងឡើយ ធ្វើយ៉ាងណាឱ្យតែឈ្នះ ដោយមិនអាណិត ដល់ចិត្តម៉ែបន្តិចសោះឡើយ។

ម៉ែសែនឈឺចិត្តណាស់ នៅពេលដែលកូនទាស់ទែងខ្វែងគំនិតគ្នា ចង់ស៊ីសាច់ហុតឈាមគ្នាយ៉ាងនេះ។

កូនសំឡាញ់មាសម្ដាយ កូនមានចាំទេ គ្រាដែលកូននៅតូចៗម៉ែថ្នមម៉ែថ្នាក់ ម៉ែទូន្មានប្រៀនប្រដៅកូនយ៉ាងដូចម្ដេចខ្លះ តើកូនមានចាំទេ? ឬមួយកូនភ្លេចអស់ហើយ បើកូនភ្លេចអស់ហើយ ម៉ែនឹងប្រាប់កូនម្ដងទៀត កូនត្រូវចាំស្ដាប់ណា:

ពុកម៉ែសែនឈឺឮកូនទាស់គ្នា ក្នុងទ្រូងគ្រាំគ្រាណាស់កូនព្រលឹង
ម៉ែនៅនឹងមុខឈរឡើងជង្រ្គឹង កូនធ្វើអ៊ីចឹងមិនអាណិតម៉ែ។
បងប្អូនបង្កើតឃើញគ្នាដូចខ្លា ជេរបណ្ដាសាដណ្ដើមយកកេរ្ដិ៍
ពុកម៉ែនៅរស់មិនទាន់ស្លាប់ទេ ជួបគ្នាជុំជេរទារកេរ្ដិ៍ពីម៉ែ។
កូនខ្លះទាមទារគឺចង់បានផ្ទះ កូនប្អូនចង់ឈ្នះសូមយកដីស្រែ
ចំណែកកូនពៅក៏មិនល្មមដែរ ម៉ែខ្ញុំអ្នកថៃតើខ្ញុំបានអ្វី។



www.elibraryofcambodia.org

ទេៗទេៗខ្ញុំមិនព្រមទេ　ខ្ញុំកូនពៅគេបានផ្ទះនិងដី
ចំណែកបងៗយកគោក្របី　រីឯប្លង់ដីផ្ទះត្រូវបានខ្ញុំ។
ឯកូនទីពីរគេមិនសុខចិត្ត　ចែកមិនសុចរិតសូមកុំច្រឡំ
ត្រូវចែកឱ្យស្មើខណ្ឌចែកជាព្រំ　ខ្ញុំតូចគេធំខ្ញុំមិនព្រមទេ។
កូនស្រីក៏ថាតវ៉ាបន្ត　គំនិតមិនល្អមានចិត្តវៀចវេរ
ខ្ញុំជាកូនស្រីត្រូវច្រើនជាងគេ　កូនប្អូនឆ្លើយទេខ្ញុំជាកូនពៅ។
បើបងមិនព្រមតើចង់ដូចម្តេច　ចំណែកខ្ញុំតិចដូចជាមិនត្រូវ
បងជាកូនច្បងយកចម្ការទៅ　ដីផ្ទះស្រែស្រូវបានខ្ញុំទាំងអស់។
បងប្អូនបង្កើតកើតរឿងប្តឹងផ្តល់　ឥតក្តីយោគយល់បងប្អូនឯងសោះ
ចង់ឈ្នះគ្រប់គ្នាគ្មានក្តីស្រណោះ　អាណិតទៅចុះឱ្យម៉ែស្លាប់សិន។
ពេលនេះពុកម៉ែនៅមានដង្ហើម　កូនៗចាប់ផ្តើមបង្អោចបង្អិន
ទាមទារចង់បានខ្លាំងម្ល៉េះមាសឆ្អិន　ចាំម៉ែស្លាប់សិនសឹមកូនទាស់គ្នា។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

# ១៤.ពុកសែនឈឺចិត្ត

ឆាកជីវិត គិតទៅប្រែប្រួលរហ័សមែន មួយប៉ប្រិចភ្នែកសោះ អ្វីៗទាំងអស់ ក៏ត្រូវបានផ្លាស់ប្តូរ ដោយនឹកស្មានមិនដល់ កូនប្តូរទាំងរូបប្តូរទាំងរាង ប្តូរទាំងចិត្តគំនិត ប្តូរទាំងការគិត ប្តូរទាំងពាក្យសម្តី ប្តូរទាំងចរិយាមារយាទ និងការប្រព្រឹត្ត គ្រប់បែបយ៉ាង។

ដើមឡើយ កូនគឺជាកូនល្អម្នាក់របស់ពុកម៉ែ ហើយក៏ជាសិស្សល្អម្នាក់របស់លោកគ្រូអ្នកគ្រូផងដែរ ហើយក៏ជាប្រជាពលរដ្ឋល្អរបស់ប្រទេសជាតិ ពុកម៉ែមិនលំបាក ក្នុងការនិយាយស្តីណែនាំឡើយ កូនមិនដែលធ្វើឱ្យម៉ែ លំបាកចិត្តម្តងណាទេ។

ប៉ុន្តែពេលនេះ កូនបានផ្លាស់ប្តូរនូវឫកពា គួរឱ្យបារម្ភចេះដើរលេងសប្បាយ ស៊ីចាយហ៊ឺហាផឹកស្រាមិនចូលផ្ទះ ដល់យប់អធ្រាត្រ តើកូនទៅទីណា?



www.elibraryofcambodia.org

យប់កាន់តែជ្រៅ រាត្រីក៏កាន់តែងងឹត ជិតនឹងភ្លឺទៅហើយនៅឡើយ មិនឃើញរូបកូន ត្រឡប់ចូលផ្ទះនោះទេ ពុករង់ចាំមើលផ្លូវកូនយ៉ាងអន្ទះសា ដោយការព្រួយបារម្ភនៅក្នុងចិត្តយ៉ាងក្រៃលែង ព្រោះពុកខ្លាចកូនមានគ្រោះថ្នាក់ ។

កូនអើយ ឈប់ទៅ ឈប់ធ្វើឱ្យពុកលំបាកចិត្ត ដោយសារកូនទៀតទៅ នៅពេលដែលពុកទូន្មានកូនមិនបាន ពុកសែនឈឺចិត្តណាស់កូន ស្ទើរតែធ្លាយទ្រូងទៅហើយ ប្រសិនបើពុកអាចពុះទ្រូងរូងយកបេះដូងថ្លើមប្រមាត់ មកឱ្យកូនឃើញបានពុកនឹងធ្វើភ្លាម ដើម្បីឱ្យកូនបានយល់អំពីជម្រៅចិត្តរបស់ពុក ថាពុកស្រឡាញ់កូនប៉ុនណា បារម្ភពីកូនដល់កម្រិតណា ដើម្បីឱ្យកូនបានយល់ពីជម្រៅចិត្តពុករបស់ខ្លះ ។

ពុកសែន ឈឺចិត្តដ្បិតកូនមិនស្តាប់
ពុកសែន ចុកចាប់ក៏កូនមិនខ្វល់
ពុកសែន ឆ្អិតទ្រូងថប់ស្ទើរដាច់ខ្យល់



www.elibraryofcambodia.org

ពុកសែន អំពល់គិតកូនគ្រប់គ្នា។
ពុកសែន ភិតភ័យស្រដីមិនសម
ពុកសែន ទុក្ខធំស្មើរគ្រប់វេលា
ពុកសែន ខ្លោចផ្សាចិន្តាគ្រាំគ្រា
ពុកសែន វេទនាណាស់ថ្លៃគ្រាណាត្រើយ។
ពុកសែន តក់ស្លត់ស្រយុតហឫទ័យ
ពុកសែន ព្រួយភ័យបុត្រធ្វើកន្តើយ
ពុកសែន ខូចចិត្តសួរកូនមិនឆ្លើយ
ពុកសែន ស្តាយក្រោយណ្ហើយស៊ូទ្រាំទៅ។
ពុកសែន ខ្លាចណាស់ក្រែងកូនធ្វើខុស
ពុកសែន សន្តោសណែនាំប្រាប់ផ្លូវ
ពុកសែន ខ្វាយខ្វល់ដល់កូនពាលពៅ
ពុកសែន សោកសៅពេលកូនដើរយប់។
ពុកសែន អួលណែនចំបែងតតស្រាក



www.elibraryofcambodia.org

ពុកសែន លំបាកព្រោះកូនមិនឈប់
ពុកសែន ស្វះស្វែងក្រែងហូបមិនគ្រប់
ពុកសែន រកទប់តស៊ូប្រឹងប្រែង។
ពុកសែន ខំណាស់ពេលខ្លះក៏អត់
ពុកសែន ក្រខ្សត់នឿយហត់ម្នាក់ឯង
ពុកសែន ខំប្រឹងទោះក្រោមសូរ្យសែង
ពុកសែន ចំបែងព្រោះដើម្បីកូន។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**



www.elibraryofcambodia.org

# ១៥.ខំអើយសែនខំៗដើម្បីកូន

ខំអើយៗខំខំគ្មានពេលឈប់ ខំថ្ងៃខំយប់ខំគ្រប់វេលា
ខំគ្មានសម្រាកខំធ្វើការងារ ខំរកទ្រព្យាខំគ្មានពេលល្ហែ។
ខំអើយៗខំៗចិញ្ចឹមកូន ខំបាត់មាត់សូន្យមិនត្អូញមិនត្អែរ
ខំស្ទើរតែក្ស័យបុត្រថ្លៃមាសស្នេហ៍ ខំរាល់ថ្ងៃខែព្រោះតែនរណា។
ខំអើយៗខំៗគ្មានពេលភ្លេច ខំដល់ថ្ងៃលិចចោលទីបលោកា
ខំដល់អាគ្រាត្រទើបដល់គេហា ខំព្រោះបុត្រាបុត្រីគ្រប់គ្នា។
ខំព្រឹកខំល្ងាចខំស្ទើរតែសូន្យ ខំដើម្បីកូនមិនថាឈឺជា
ខំដោយកម្លាំងតតាំងការពារ ខំព្រោះបុត្រភ្វាលុះជីវិតក្ស័យ។
ខំភ្ជួរខំរាស់ខំដកខំស្ទូង ខំស្ទើរបែកទ្រូងវិលមុខល្ងិតល្ហែ
ខំតាំងពីព្រឹកស្អឹកអស់ជើងដៃ ខំប្រឹងរាល់ថ្ងៃគ្មានទេពេលឈប់។
ខំអើយៗខំស្វែងរកសម្បត្តិ ខំរកបាត់ៗខំទាំងថ្ងៃយប់
ខំរកប៉ុណ្ណឹងបានត្រឹមទល់ទប់ ខំទាំងថ្ងៃយប់ផ្គត់ផ្គង់គ្រួសារ។
ខំធ្វើយ៉ាងហ្នឹងប្រឹងដោយកម្លាំង ខំពីខែប្រាំងរហូតវស្សា



www.elibraryofcambodia.org

ខំរែកខំពុនធ្វើស្រែចម្ការ ខំលីនឹងស្មាមិនថាមិនស្ដី។
ខំដើម្បីកូនលុះសូន្យជីវិត ខំទាញខំឃឹតជីវិតក្រក្រី
ខំប្រឹងឱ្យហើយណាកូនពិសី ខំដើម្បីអ្វីគឺដើម្បីកូន។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**

ពេលវេលាមានតម្លៃ បើចេះច្នៃមានប្រយោជន៍
ទោះបីស្លាប់ទៅជាខ្មោច គឺយ៉ាងហោចមានសីលប្រាំ។



www.elibraryofcambodia.org

# ១៦.សំឡេងព្រះធម៌

សំឡេងព្រះធម៌លាន់ឮរងំ     ព្រះអភិធម្មទ្រង់ត្រាស់សំដែង
ព្រះពុទ្ធដីកាបិដកជាក់ស្ដែង     មរតកនេះឯងមួយរយដប់ភាគ។
ព្រះធម៌វិន័យអង្គព្រះសម្ពុទ្ធ     សែនល្អវិសុទ្ធស្ដាប់កុំឱ្យឃ្លាត
សាវកសម្ដែងចូរផ្ទៀងត្រចៀក ព្រះមានព្រះភាគទ្រង់ប្រាប់ប្រកាស។
សាសនានៅមានកុំនៅបង្អង់     ឱវាទព្រះអង្គពន្យល់យ៉ាងច្បាស់
ប្រាប់ដល់សព្វសត្វឱ្យឆាប់រហ័សតើសត្វណាខ្លះដែលមាននិស្ស័យ។
ចូរធ្វើថ្ងៃនេះកុំចាំថ្ងៃស្អែក     ជីវិតបាក់បែកកុំចាំថ្ងៃក្ស័យ
មិនដឹងពេលណាថានឹងដល់ថ្ងៃ  មច្ចុចង្រៃឆក់យកសង្ខារ។
កុំធ្វើកន្តើយត្រូវតែប្រញាប់     ខំអានរៀនស្ដាប់ធម៌ព្រះសាស្ដា។
ខំស្ដាប់ឱ្យហើយកុំឡើយចាំយូរធម៌គឺជាគ្រូនាំចិត្តជ្រះថ្លា
ដឹកនាំសត្វលោកឱ្យរួចទុក្ខា     ពីវដ្ដសង្សារពោលគឺនិព្វាន។
ធម៌ជាឱសថព្យាបាលផ្លូវចិត្ត   ព្យាយាមប្រព្រឹត្តផ្លូវព្រះសម្មា



www.elibraryofcambodia.org

កុំចាញ់បញ្ឆោតកិលេសតណ្ហា បំភាន់នេត្រាធ្លាក់ទៅអវិចី។
យើងជាបរិស័ទអ្នកបដិបត្តិធម៌ ចិត្តកុំញាប់ញ័រលោកធម៌ប្រាំបី
ប្រយ័ត្នចំណង់ចងក្នុងលោកីយ ស្លាប់លើផែនដីគ្មានអ្វីទីពឹង។
ព្រោះហេតុដូច្នេះអស់អ្នកប្រយ័ត្ន ខិះខិសព្វសត្វអ្នកត្រូវខំប្រឹង
ត្រូវកាត់បន្ថយទោសៈដែលខឹង អ្នកកុំស្រវឹងលង់នឹងសំឡេង។
ទានសីលភាវនាអ្នកកុំកន្តើយ គួរធ្វើឱ្យហើយទាន់ខ្លួននៅក្មេង
ស្មារតីនៅល្អមិនទាន់វង្វេង ទុក្ខសោកសង្រេងគង់តែមកបៀត។
ឥឡូវបានកើតកំណើតនៅមាន ធ្វើបុណ្យដាក់ទានជួបជុំផៅញាតិ
មួយខែបួនសីសអស់អ្នកត្រូវឆ្លៀត ចូរកុំឱ្យឃ្លាតពីបុណ្យកុសល។

**និពន្ធដោយ គង់ ច័ន្ទសុរិក្រ**



www.elibraryofcambodia.org

# ១៧.បើចង់ម្ដេចក៏មិនធ្វើ

បើចង់បានមានម្ដេចសាងប្លង់ក្រ
បើចង់បានល្អម្ដេចសាងអាក្រក់
បើចង់មានទ្រព្យម្ដេចទៅលួចឆក់
បើមិនអាក្រក់ម្ដេចសាងវេរា។
បើចង់បានសុខម្ដេចសាងបញ្ហា
បើចង់សុខាម្ដេចសាងនិន្ទា
បើចង់រស់ជុំម្ដេចក៏ឈ្លោះគ្នា
បើចងកម្មពៀរមានទុក្ខវែងឆ្ងាយ។
បើចង់បានបុណ្យម្ដេចមិនឱ្យទាន
បើចង់បាត់ឃ្លានម្ដេចមិនហូបបាយ
បើចង់បានល្អម្ដេចភ្លេចគុណម្ដាយ
បើមិនចេះស្រាយហេតុម្ដេចក៏ចង។



www.elibraryofcambodia.org

បើចង់បានចេះម្ដេចមិនសិក្សា
បើមានបញ្ញារក្សាស្មោះត្រង់
បើឃើញចំណេញកុំភ្លេចរឿងបង់
បើមានចំណង់កុំភ្លេចស្មារតី។
បើស្រឡាញ់ខ្លួនម្ដេចពួនធ្វើបាប
បើទឹកមាត់សាបម្ដេចខំស្រដី
បើដឹងខ្លួនខុសខំកែប្រែថ្មី
បើខុសសម្ដីគ្មានអ្វីនឹងជួស។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

# ១៨.ចូលឆ្នាំថ្មីហើយ

បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ជួបជុំផៅញាតិជាតិជាខេមរា
មកស្រុកកំណើតជួបជុំគ្រួសារ ទទួលទេវតានៅក្នុងឆ្នាំថ្មី។
បុណ្យចូលឆ្នាំថ្មីសែនប្រពៃពិត បងប្អូនញាតិមិត្តទទួលសិរី
ប្តូរពីឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី ទទួលសួស្តីអ្វីៗកន្លង។
បុណ្យចូលឆ្នាំថ្មីប្រុសស្រីជួបជុំ ស្លៀកពាក់សមរម្យក្មេងចាស់ប្អូនបង
ទៅពូនភ្នំខ្សាច់ផ្តាច់កម្មសៅហ្មង សូមសច្ចាផ្សងប៉ងមកពីឆ្ងាយ។
បុណ្យចូលឆ្នាំថ្មីសិរីមង្គល រឿងរ៉ាវអំពល់វិនាសខ្ចាត់ខ្ចាយ
សេចក្តីសោកសៅសូមឆាប់រសាយ សេចក្តីអន្តរាយចូរជៀសឆ្ងាយទៅ
បុណ្យចូលឆ្នាំថ្មីប្រុសស្រីដើរដាសដំណើររហ័សហូរហែតាមផ្លូវ
ទៅវត្តទៅវ៉ាខ្លះក៏ចែចូវ កត្តិកច្រូតស្រូវចូលស្តុកទុកដាក់។
បុណ្យចូលឆ្នាំថ្មីប្រុសស្រីទៅវត្ត ខ្មែរប្រកាន់ខ្ជាប់ជាមួងអាវប៉ាក់
ពានាក្រមាដៃកាន់យួរស្រោក់ សក់វែងទម្លាក់ទន់ដូចអប្សរា។
បុណ្យចូលឆ្នាំថ្មីអ្វីៗប្តូរផ្លាស់ ក្មេងរាំធុងបាស់ចាស់ជុំធម៌អាថ៌



www.elibraryofcambodia.org

ប្រជុំធ្វើបុណ្យស្តាប់ធម៌ទេសនា ដោយចិត្តជ្រះថ្លាធ្វើតាមសទ្ធា។

បុណ្យចូលឆ្នាំថ្មីវ័យកាន់តែចាស់ រូបកាយប្តូរផ្លាស់កាន់តែគ្រាំគ្រា
ភ្នែកក៏ស្រវាំងស្បែកចាប់ផ្តើមយារ ដើរត្រូវមានគ្នាគ្រាន់ជាជំនួយ។

បុណ្យចូលឆ្នាំថ្មីសប្បាយភ្លេចខ្លួន កម្លាំងមាំមួនឥឡូវជួបព្រួយ
ស្វែងរកឈើច្រត់ដើម្បីឱ្យជួយ ជីវិតតែមួយព្រួយរាល់ឆ្នាំខែ។

បុណ្យចូលឆ្នាំថ្មីសប្បាយផឹកស៊ី បុណ្យប្រពៃណីរបស់ជាតិខ្មែរ
ផ្អាកពីការងារទៅជួបពុកម៉ែ រស់នៅឯស្រែរង់ចាំមើលផ្លូវ។

បុណ្យចូលឆ្នាំថ្មីបងប្អូនពលករ សប្បាយត្រេកអរគេឱ្យវិលទៅ
លេងស្រុកកំណើតជាទីលំនៅ មានម៉ែមានឪនៅចាំទទួល។

**និពន្ធដោយ គង់ ច័ន្ទសុទ័ក្រ**



www.elibraryofcambodia.org

## ១៩.អំណាចនៃលុយ

លុយជាសន្ទូចស្ទូចអ្នកក្រ លុយជាលម្អនៃអ្នកមាន
លុយជាជំនួយជួយអ្នកឃ្លាន លុយជាជើងពានទ្រឱ្យខ្ពស់។
លុយជាក្រដាសឥតវិញ្ញាណ លុយគឺជាស្ពានមានកិត្តិយស
លុយក៏ជាផ្លូវឱ្យល្បីឈ្មោះ លុយក៏ជាគ្រោះធ្លាក់អវិចី។
លុយជាប្រភពនៃបញ្ហា លុយនាំហិង្សាជនប្រុសស្រី
លុយនាំប្រពន្ធក្បត់ស្វាមី លុយនាំឱ្យប្ដីក្បត់ភរិយា។
លុយដឹកនាំចិត្តឱ្យសាវ៉ា លុយឱ្យឈើផ្សាបែកបាក់គ្នា
លុយអាចប្រហារឱ្យវេទនា លុយឱ្យគ្រាំគ្រាដល់ជីវិត។
លុយដឹកនាំចិត្តឱ្យព្រៃផ្សៃ លុយនាំឱ្យដៃប្រហារមិត្ត
លុយឱ្យរើសអើងញាតិឆ្ងាយជិត លុយនាំវិបរិតទុក្ខឥតល្ហែ។
លុយអាចឱ្យកូនបំភ្លេចឪ លុយនាំឱ្យឪបំភ្លេចម៉ែ
លុយជាអាគមគួរឱ្យស្នេហ៍ លុយអាចបង្វែរចិត្តដែលស្មោះ។



www.elibraryofcambodia.org

លុយអាចឱ្យមនុស្សធ្វើជាខ្មាក់ លុយនាំបែកបាក់ញាតិស្រីប្រុស
លុយនាំឱ្យចិត្តមិនសន្តោស លុយនាំឱ្យខុសនូវសីលធម៌។
លុយជាអាគមអន្ទងចិត្ត លុយចូលសណ្ឋិតចិត្តញាប់ញ័រ
លុយជាជំនួយតាមខ្សែរល្បិ លុយអាចលាបពណ៌ខ្មៅជា-ស។
លុយដឹកនាំមនុស្សឱ្យវង្វេង លុយធ្វើអ្នកលេងទាក់ជាប់ក
លុយជាមាសប្រាក់ចាយមួយត លុយជួយកំដរពេលមួយគ្រា។
លុយគឺជាហេតុនៃគុកកម្ម លុយប្រើប្រចាំគ្រប់វេលា
លុយដឹកនាំចិត្តចងកម្មពៀរ លុយនាំឈ្លោះគ្នាចិត្តអប្រិយ។
លុយគឺជាមិត្តដ៏ស្និទ្ធស្នាល លុយអាចបណ្តាលឱ្យមានភ័យ
លុយនាំមកនូវភាពសេរី លុយនាំសួស្តីដល់គ្រួសារ។
លុយមានអំណាចបញ្ជាមនុស្ស លុយនាំប្រទូស្តទ្រុស្តសាសនា
លុយអ្នកសម្រេចជោគជតា លុយដូចទេវតាឥតវិញ្ញាណ។
លុយជាដើមហេតុនៃមេរោគ លុយនាំវិយោគឱ្យយើងហ៊ាន
លុយនាំឱ្យមនុស្សធ្វើបំពាន លុយជាធនធានឱ្យវង្វេង។



www.elibraryofcambodia.org

លុយជាអាវុធដ៏ព្រៃផ្សៃ លុយនាំឱ្យដៃមនុស្សបែកឆ្វេង
លុយនាំឱ្យមនុស្សចេះដើរលេង លុយឱ្យទាស់ទែងបងប្អូនឯង។
លុយប្រើខុសផ្លូវគួរឱ្យស្តាយ លុយនាំអន្តរាយយូរអង្វែង
លុយនាំជីវិតដូចជាផ្សែង លុយនាំចំបែងប្រើមិនគិត។
លុយគួរស្រឡាញ់គួរឱ្យស្អប់ លុយអាចបញ្ចប់នូវជីវិត
លុយដឹកនាំមនុស្សសាងវិបរិត លុយដឹកនាំចិត្តភ្លេចញាតិផៅ។
លុយនាំមកនូវព្រេងសំណាង លុយធ្វើគ្រប់យ៉ាងតាមតម្រូវ
លុយជួយសម្រេចតាមគោលដៅ លុយជារណ្តៅនៃចំណង់។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

## ២០.សេចក្តីល្អជាលម្អនៃជីវិត

សេចក្តី ល្អជាលម្អនៃជីវិត

សេចក្តី ពិតធ្វើជីវិតឱ្យមានន័យ

សេចក្តី ទុក្ខគឺជាគុកដាក់ប្រុសស្រី

សេចក្តី ភ័យក្នុងភពបីមិនអាចឃាត់។

សេចក្តី សោកទុក្ខវិយោគឥតមានល្ហែ

សេចក្តី ស្នេហ៍តែងប្រួលប្រែឥតទៀងទាត់

សេចក្តី សុខហើយនិងទុក្ខជួបតែងព្រាត់

សេចក្តី ស្លាប់តែងទៀងទាត់ឃាត់មិនបាន។

សេចក្តី ល្ងង់តែងជាប់ផុងលង់គំនិត

សេចក្តី ពិតធ្វើជីវិតស្លាប់ចោលប្រាណ

សេចក្តី ស្មោះអស់ពីចិត្តទាំងប៉ុន្មាន

សេចក្តី ថ្កានគង់តែងបានស្រាន្តគ្រប់មុខ។



www.elibraryofcambodia.org

សេចក្តី ជឿក្នុងជំនឿនៃសាសនា

សេចក្តី ចារក្បួនតម្រាជាទំនុក

សេចក្តី ត្រង់តែងមិនបង់នាំជាសុខ

សេចក្តី ផុតគង់រលត់សូន្យជាក់ច្បាស់។

សេចក្តី លោភជាចំណងចងទម្លាក់

សេចក្តី ធ្លាក់ជាប់ជំពាក់ជាកម្មក្រាស់

សេចក្តី ដឹងរឿងអស់ហ្នឹងប្រឹងរហ័ស

សេចក្តី ប្រាសប្រាកដណាស់ច្បាស់ជាបាត់។

សេចក្តី ស្ងប់គង់បញ្ចប់ពេលមិនដឹង

សេចក្តី ខឹងក្នុងខ្លួនហ្នឹងប្រឹងទប់ស្កាត់

សេចក្តី សុខរួចចាកទុក្ខគ្រប់មនុស្សសត្វ

សេចក្តី ព្រាត់ត្រូវប្រយ័ត្នគ្រប់វេលា។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**



www.elibraryofcambodia.org

## ២១.តើខំ យកទៅណា?

តើខំរាល់ថ្ងៃដើម្បីនរណា ខំព្រោះបុត្រាហើយនិងបុត្រី
តើខំយ៉ាងនេះព្រោះដើម្បីអ្វី ខំខ្លាចគ្មានអ្វីផ្គត់ផ្គង់គ្រួសារ។
តើខំម្ល៉ឹងហើយនៅឡើយខ្ញុំគេ ខំគ្មានទំនេរលីសែងដោយស្មា
តើខំរកលុយយកប្រាក់ទៅណា ខំឱ្យសិក្សារហូតថ្នាក់ខ្ពស់។
តើខំខ្នះខ្នែងស្វែងរកកម្រៃ ខំធ្វើដោយដៃបែកប្រេះកៀមក្រោះ
តើខំប៉ុណ្ណឹងប្រឹងស្មើរតែខ្សោះ ខំធ្វើទាំងអស់ឱ្យតែបានប្រាក់។
តើខំថ្ងៃនេះគ្រប់ទេថ្ងៃស្អែក ខំរៀបបែងចែករៀបចំទុកដាក់
តើខំពេលថ្ងៃញើសហូរសស្រាក់ ខំខ្លាចជំពាក់ទ្រព្យបំណុលគេ។
តើខំស្វះស្វែងភ្លេចបាយភ្លេចទឹក ខំតាំងពីព្រឹករហូតថ្ងៃជ្រេ
តើខំប៉ុណ្ណឹងដឹងទេមាសមេ ខំគ្មានទំនេរព្រោះកូនព្រលឹង។

**និពន្ធដោយ គង់ ច័ន្ទសុរ័ក្រ**



www.elibraryofcambodia.org

## ២២.ខ្មែរនៅឯណា

១៤កុម្ភៈអន្ទាក់ជីវិត
ខ្មែរអើយគួរគិតជួយពិចារណា
វប្បធម៌គេសោះជំនួនជាតិខេមរា
ចេះជូនបាច់ផ្កាផ្ញើផ្កាសម្តី។
១៤កុម្ភៈជូនផ្កាកុលាប
សម្តីផ្អែមខាបទាក់ទាញចិត្តស្រី
ឱ្យផ្កាមួយទងប្តូរព្រហ្មចារី
ភ្លេចប្រពៃណីគឺជាតិខ្លួនឯង។
១៤កុម្ភៈទាក់ចិត្តកូនខ្មែរ
ងប់ងុលនឹងស្នេហ៍ចិត្តវល់ដូចផ្សេង
ជួបភ័ក្ត្រប្រុសបងនួនល្អងតុបតែង
សក់ពណ៌ទង់ដែងក្រែងបងមិនស្និទ្ធ។



www.elibraryofcambodia.org

១៤កុម្ភៈវរល្ខណ៍ជួបគ្នា
ជួបបងមួយគ្រាទោះយប់ងងឹត
ប៉ាវបងផឹកស្រាបូជាកាយចិត្ត
នាំគ្នាស្មាលស្និទ្ធភ្លេចខ្លួនជាខ្មែរ។
១៤កុម្ភៈទូរស័ព្ទឆ្លើយឆ្លង
ណាត់ជួបប្រុសបងនូនល្អងថ្នមថៃ
ចេញបាត់ពីផ្ទះមិនបាច់ប្រាប់ម៉ែ
ទៅជួបប្រុសស្នេហ៍ជាគូសង្សារ។
១៤កុម្ភៈជឿជាក់ថាស្មោះ
អ្វីៗហួសអស់មិនដូចប្រាថ្នា
បានប្រាណស្រីហើយដោះដៃសារ៉ា
ស្រក់ទឹកនេត្រាព្រោះលង់សម្ដី។
១៤កុម្ភៈឱ្យស្រីខ្មាសគេ
មិនចង់រស់ទេនៅក្នុងលោកិយ



www.elibraryofcambodia.org

ចាញ់បោកប្រុសព្រានមានចិត្តអប្រិយ
បាត់ភាពស្ត្រីលក្ខណៈនារី។
១៤កុម្ភៈស្នេហ៍ខុសតម្រា
ពុកម៉ែគ្រួសារខ្មាសគេពេញទី
មិនគិតកិត្តិយសកេរ្តិ៍ឈ្មោះជាន់ឈ្លី
ខុសប្រពៃណីកូនឥតខាន់ស្លា។
១៤កុម្ភៈលាក់មុខភូមិឃុំ
ចង់តែស្រែកយំដាក់បណ្តាសា
ស្រលាញ់គ្នាមុនដោយគ្មានមេបា
ចំណង់តណ្ហាស្នេហាផ្កាប់មុខ។
១៤កុម្ភៈឃើញតុបតែងកាយ
ឥឡូវសប្បាយក្លាយទៅជាទុក្ខ
មិនអាណិតម៉ែដល់ទ្រូងឪពុក
ឱ្យគេស៊ីចុកខ្មាសគេទាំងភូមិ។

**និពន្ធដោយ គង់ ច័ន្ទសុរិក្រ**



www.elibraryofcambodia.org

## ២៣.ចំណង់ចងមិនចេះចប់

ចំណង់ចំណងចងជាប់ស្អិត ចំណង់ផ្លូវចិត្តស្និទ្ធស្នេហា
ចំណង់ស្រឡាញ់គូសង្សារ ចំណង់កាមាស្នេហ៍ប្រុសស្រី។
ចំណង់ចំណូលពិតចំណាយ ចំណង់ផ្លូវកាយបង់អ្វីៗ
ចំណង់ដែលចង់ផ្ដាប់ហឫទ័យ ចំណង់ភពបីផ្ដាប់តណ្ហា។
ចំណង់ចំណាយចាយសម្បត្តិ ចំណង់មនុស្សសត្វក្ដីសុខា
ចំណង់ម៉ែឪឃើញរៀបការ ចំណង់មេបាត្រូវចូលស្ដី។
ចំណង់ចំណូលត្រូវទំនៀម ចំណង់ក្នុងនាមជាស្ត្រី
ចំណង់មង្គលប្រពៃណី ចំណង់អត្ថន័យពេលក្រាបផ្ទឹម។
ចំណង់មនុស្សការប្រព្រឹត្ត ចំណង់ដូចចិត្តមុខញញឹម
ចំណង់បង្ខំធ្វើសន្សឹម ចំណង់សង្ឃឹមពេលព្យាយាម។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

# ២៤.ជីវិតគ្រប់គ្នា

ជីវិតអ្នកក្ររស់ដោយអត់ឃ្លាន ជីវិតអ្នកមានរស់ដោយសប្បាយ
ជីវិតព្រះសង្ឃផ្តាច់កម្មទាំងឡាយ ជីវិតអ្នកម្តាយរស់រងវេទនា។
ជីវិតឪពុកសម្រុកធ្វើការ ជីវិតចម្ការប្រឹងធ្វើការងារ
ជីវិតជាសិស្សស្វែងរកវិជ្ជា ជីវិតកំព្រារស់គ្មានទីពឹង។
ជីវិតអ្នកល្ងង់ផុងនឹងអំនួត ជីវិតអ្នកអួតរស់គ្មានលំនឹង
ជីវិតអ្នកក្រោធទោសៈតែងខឹង ជីវិតអ្នកបឹងប្រឹងធ្វើនេសាទ។
ជីវិតអ្នកក្រុងលង់ភាពហ៊ឺហា ជីវិតអ្នកផ្សារគិតចំណេញខាត
ជីវិតជាក្មេងចង់បានភាពស្អាត ជីវិតអ្នកឆ្លាតខំប្រឹងសិក្សា។
ជីវិតជនពាលបង្កជម្លោះ ជីវិតអ្នកបួសទ្រទ្រង់សិក្ខា
ជីវិតអ្នកផឹកច្រើនប្រើហិង្សា ជីវិតអនាថាខ្វះការអប់រំ។
ជីវិតសុំទានគ្មានទ្រព្យសម្បត្តិ ជីវិតរបស់សត្វរស់តាមព្រៃភ្នំ
ជីវិតឃាតកររស់ក្នុងគំនុំ ជីវិតជាខ្ញុំរស់បម្រើគេ។

**និពន្ធដោយ គង់ ច័ន្ទសុរ៉ាក្រ**



www.elibraryofcambodia.org

# ២៥.កូនមាសឪពុក

កូនមាសឪពុក កូនត្រូវចាំទុក ត្រូវប្រុងប្រយ័ត្ន
រាល់ពាក្យសម្ដី ពាក្យសង្ឃពាក្យសត្យ ពោលទៅគ្រប់ម៉ាត់
កូនត្រូវតែគិត។

កូនមាសព្រលឹង ត្រូវគិតជញ្ជឹង ចេះប្រើគំនិត
ប្រាជ្ញាស្មារតី ទោះនៅឆ្ងាយជិត ជួបជុំមុលមិត្ត
ប្រយ័ត្នសម្ដី។

កូនមាសស្នេហ៍ស្និទ្ធ មុនកូនប្រព្រឹត្ត ត្រូវគិតវែងខ្លី
ពាក្យពេចន៍ជ្រៅរាក់ ត្រូវប្រុងស្មារតី បញ្ញាឆ្លាតវៃ
រឿងរ៉ាវប្រែប្រួល។

កូនមាសពន្លក ញាតិអញ្ជើញមក កូនត្រូវទទួល
ទោះមានរឿងអ្វី អារម្មណ៍មិនស្រួល កូនត្រូវសម្រួល
ដូចភ្លៀងរលឹម។



www.elibraryofcambodia.org

កូនមាសស្នេហ៍ស្នង គោរពប្អូនបង ដែសងផ្គុំត្រឹម
ឃើញពីចម្ងាយ ផ្តល់ក្តីសង្ឃឹម ទឹកមុខញញឹម
ទទួលរាក់ទាក់។

កូនមាសសម្លាញ់ កូនកុំចុះចាញ់ ទោសះជាផ្ទាក់
កូនត្រូវទន់ភ្លន់ នោះទើបមិនធ្លាក់ ប្រយ័ត្នមាសប្រាក់
ទាក់ទៅអវិចី។

កូនពៅសំណព្វ រឿងស្រឡាញ់ស្អប់ លោកធម៌ប្រាំបី
ព្យាយាមទប់ស្កាត់ នៅក្នុងហឫទ័យ ប្រយ័ត្ននាំភ័យ
ជិតដល់ខ្លួនយើង។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ្ត**



www.elibraryofcambodia.org

## ២៦.ត្រៃលក្ខណ៍ធម៌

ដំណើរជីវិត	ប្រែប្រួលប្រឌិត	ល្វឹងប្រែជូរចត់
ថ្ងៃខ្លះសុខស្រួល	ថ្ងៃខ្លះនឿយហត់	ថ្ងៃខ្លះក៏អត់
ថ្ងៃខ្លះសប្បាយ។
ជីវិតទាំងអស់	ស៊ីមិនរើសសោះ	ក្មេងចាស់តាយាយ
អ្នកខ្លៅអ្នកឆ្លាត	ស៊ីគ្មានប្រណី	ទាំងប្រុសទាំងស្រី
ជួបភ័យអន្តរាយ។
គ្រប់វិនាទី	មច្ចុមកស៊ី	មិនរើសរូបកាយ
ស៊ីទាំងក្រមុំ	ស៊ីទាំងមេម៉ាយ	ស៊ីមិនធិនណាយ
ជីវិតត្រូវប្តូរ។
ឱ!ពេលវេលា	ត្រឹមតែមួយគ្រា	មិនអាចទិញដូរ
ចេះតែទៅមុខ	ដោយគ្មានអាសូរ	ដូចទឹកដែលហូរ
ហូរមិនត្រឡប់។
ចំណែកជីវិត	ដើរទៅកៀកជិត	ដល់ថ្ងៃបញ្ចប់



www.elibraryofcambodia.org

ដោយមិនដឹងខ្លួន	ដល់ក្លាយជាសព	បានត្រូវគេកប់
គឺចប់គ្រប់យ៉ាង។

កាលនៅពីក្មេង	លេងនឹងសំឡេង	តុបតែងស្អិតស្អាង
ថាខ្លួនមិនចាស់	បុណ្យក៏មិនសាង	ថាមានសំណាង
ថាខ្លួនមិនស្លាប់។

ឱ!ធម៌ត្រៃលក្ខណ៍	ជរាទាញទាក់	ព្យាធិចុកចាប់
រុករុលរុករាន	មិនដឹងយូរឆាប់	ព្រោះគ្មានអ្នកប្រាប់
ថាស្លាប់ថ្ងៃស្អែក។

ឱ!អនិច្ចំ	គ្មានអ្នកតតាំង	ទោះបីប្រឹងស្រែក
កុំចាស់កុំជ្រួញ	សរសៃឈាមស្បែក	បែកជាចំណែក
ប្រេះគ្មានតំណ។

រូបំទុក្ខំ	ទុក្ខព្រោះស្គមស្គាំង	ស្រែកសុំអង្វរ
ពីក្មេងនៅហំ	សាច់ស្បែកនៅស	ចិត្តគួរត្រេកអរ
ប្រែជាជ្រួញស្វិត។



www.elibraryofcambodia.org

អនត្តាតាមក្បួន	ខ្លួនមិនមែនខ្លួន	គង់សូន្យជីវិត
ប្រែប្រួលបម្លាស់	ដោយគ្មានអាណិត	ទៅដល់ដួងចិត្ត
មនុស្សសត្វសោះឡើយ។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

# ២៧.លាមួយរយៈ

លាហើយព្រឹក្សព្រៃទឹកដីជនបទ
លាខ្ទមកំសត់លាផ្ទះបាក់បែក
លាទាំងអាល័យដំបូលរហែក
លាទាំងទឹកភ្នែកហូរជ្រែកកាត់ភក្ត្រ។
លាបងលាប្អូនលាផ្ទះប្រក់ស្បូវ
លាទីលំនៅខ្ញុំសូមលាអ្នក
លាញាតិជិតខាងធ្លាប់តែពឹងពាក់
លាមួយរយៈផ្ញើខ្លួនស្រុកគេ។
លាហើយៗលាទាំងអាល័យ
លាទីអាស្រ័យលាទាំងដីស្រែ
លាចានលាឆ្នាំងមុងភួយខ្នើយគ្រែ
លាវាលដីកេរ្តិ៍ទាំងចិត្តទោម្នេញ។
លាទីធ្លាប់ស្នាក់លាឃ្លាតទីឆ្ងាយ



www.elibraryofcambodia.org

លាទីផ្ញើកាយខ្ញុំនឹងវិលវិញ

លាស្រុកកំណើតទឹកភ្នែកប្រដេញ

លាឈានដើរចេញដៃកាន់បង្វេច។

លាស្រែចម្ការលាច្បារដំណាំ

លាពីរបីឆ្នាំកូនចាំមិនភ្លេច

លាទៅគ្រានេះម៉ែផ្តាំពាក្យពេចន៍

លាទៅតិចៗឱ្យប្រុងស្មារតី ។

លាពុកលាម៉ែធ្លាប់តែថ្នមថ្នាក់

លាទាំងអួលអាក់ក្តុកក្តួលហឫទ័យ

លាឃ្លាតតែកាយចងចាំសម្តី

លាពាក្យវែងខ្លីសម្តីពីរោះ។

លាទាំងត្រដរអង្វរទេវតា

លាដោយហត្ថាចិន្តាក្រៀមក្រោះ

លាទៅពេលនេះលាអ្វីទាំងអស់



www.elibraryofcambodia.org

លាទាំងអាឡោះអាល័យក្នុងចិត្ត។
លាទៅសិក្សាប្រាថ្នាវិជ្ជា
លាត្រឹមមួយគ្រានឹងមកជុំជិត
លាទៅពេលនេះដើម្បីជីវិត
លាទាំងចិត្តនឹកមិនចង់ឃ្លាតទេ។
លាទៅតែកាយតែចិត្តចាំនៅ
លាម៉ែលាឪដោយហត្ថទាំងទ្វេ
លាមួយរយៈផ្ញើខ្លួនស្រុកគេ
លាពាក្យបំពេគ្រាកូននៅតូច។

**និពន្ធដោយ គង់ ច័ន្ទសុរិក្រ**



www.elibraryofcambodia.org

## ២៨.ស្គាល់រូបស្គាល់រាងតែមិនស្គាល់ចិត្ត

ស្គាល់រូបស្គាល់រាងតែមិនស្គាល់ចិត្ត
បានស្គាល់គំនិតឥឡិតបាននៅក្បែរ
ចរិតឫកពាតាំងពីពោះម៉ែ
មិនអាចនឹងកែប្រែប្រួលបានឡើយ។
មាឌតូចមាឌធំដំបងរាងខ្ពស់
យើងបានស្គាល់ឈ្មោះរួចអស់ទៅហើយ
សម្បុរស្រអែមសជ្រះតោះតើយ
មុខក៏មិនឱ្យក្រោយក៏មិនបែរ។
សម្ដីផ្អែលហ្វាល្អនាខាងក្រៅ
ខាងក្នុងដង្កូវរលួយស្អុយប៉ែ
ពណ៌ក្រហមទុំគួរឱ្យឆ្ងាញ់ដែរ
ប៉ុន្តែទាស់តែស្អុយខាងក្នុងផ្លែ។
ស្គមធាត់ទាបខ្ពស់ស្ដើងខ្ពស់ស្រឡះ



www.elibraryofcambodia.org

ប្រែប្រួលរហ័សក្រឡាស់ប្រួលប្រែ
បើមិនប្រយ័ត្នច្បាស់ទុក្ខឥតល្ហែ
មិនអាចបង្វែរបច្ចុប្បន្នឥឡូវ។
សមុទ្រសែនធំគង់គេវាស់បាន
ចិត្តពិបាកស្មានឱ្យដឹងជម្រៅ
អាក្រក់ទៅល្អសទៅជាខ្មៅ
ខុសទៅជាត្រូវបំភ្លៃឱ្យសម។
ពិតថាមិនពិតមិនពិតថាពិត
ព្យាយាមប្រឌិតហើយខំបន្លំ
ទោសតិចខំទាញយកមកផ្សៀផ្សំ
បើឃើញមិនចំសូមកុំនិយាយ។

**និពន្ធដោយ គង់ ច័ន្ទសុត្រ័**



www.elibraryofcambodia.org

## ២៩.តើកូនចាំទេ?

កូនអើយចាំទេកាលគ្រាក្រ យើងហូបបបរទាំងអស់គ្នា
ម៉ែចិញ្ចឹមកូនដោយវេទនា ក្នុងខ្ទមជរាផ្ទះបាក់បែក។
ផ្ទះតូចប្រក់ស្បូវសង់ជាប់ដី ម៉ែ ត្រកងបីឱ្យកូនដេក
ដំបូលរហែកមើលឃើញមេឃ ផ្ទះធ្លាយរហែកមើលឃើញផ្កាយ។
ពេលភ្លៀងផ្គរលាន់ត្រូវភ្លៀងសាច ជញ្ជាំងក៏ជាចសើមជោកកាយ
អាណិតកូនស្ងួននួនមាសម្តាយ ជួនត្រូវអត់បាយគ្រានេះហើយ។
ម៉ែស៊ូយកខ្លួនមកការពារ បាត់ភាពរងាកូនត្រាណត្រើយ
ម៉ែនៅហាលភ្លៀងមិនគិតឡើយ ព្រោះកូននេះហើយជីវិតម៉ែ។
ធ្វើម្តេចវាសនាម៉ែមិនល្អ ម៉ែមានចិត្តធម៌ថ្នាក់ថ្នមថៃ
ស្រឡាញ់ស្ម័គ្រស្មោះឥតគេចកែ ម៉ែរស់នៅក្បែរថៃកូនពន្លក។
ពេលនេះម៉ែឈឺខ្លួនស្គាំងស្គម ដេកក្នុងផ្ទះខ្ទមជាជម្រក
ចាំកូនមកមើលនិងមករក ពេលនេះម៉ែក្រោកមិនរួចទេ។



www.elibraryofcambodia.org

ចាំបាត់ចាំបាត់ស្ងាត់សូន្យឈឹង ចាំគ្មានដំណឹងកូនមាសមេ
ចាំតាំងពីព្រឹកដល់ថ្ងៃជ្រេ មិនដឹងកូនគេទៅទីណា។
ម៉ែរង់ចាំបាយតាំងពីព្រឹក អត់បាយស្រេកទឹកឃ្លានអស្ចារ្យ
ម៉ែដេកសង្ឃឹមនឹកគិតថា នឹងបានអាហារកូនផ្ដល់ឱ្យ។
ឱ!ក្ដីសង្ឃឹមត្រឹមខកចិត្ត កូនមិនបានគិតដល់ម៉ែឡើយ
ឃ្លានស្ទើរដាច់ពោះស្លាប់ទៅហើយ ឱកូនត្រាណត្រើយឱ្យម៉ែស្លាប់។
កូនអើយជីវិតម៉ែមិនយូរ ផ្ដាំតាមមីងពូឱ្យជួយប្រាប់
ឱ្យកូនវិលមកយ៉ាងប្រញាប់ ក្នុងពេលឆាប់ៗមើលម៉ែផង។
ពេលនេះម៉ែឈឺកាន់តែធ្ងន់ ត្រូវអស់ព្រះជន្មពេលនេះម្ដង
ជិតដាច់ខ្យល់ហើយពៅនួនល្អង ទាំងប្អូនទាំងបងនៅទីណា។
ម៉ែខំសាកសួរហៅរកកូន មុនជីវិតសូន្យបង់សង្ខារ
សូមត្រឹមឃើញភ័ក្ត្រទោះមរណា ក៏ម៉ែមិនថាណាតូចតន់។
សម្រែកម៉ែស្រែកឮល្វើយៗ ខំស្រែកខ្វើយៗឮស្រទន់
រង់ចាំមើលផ្លូវខំគយគន់ ម៉ែឈឺយ៉ាងធ្ងន់ណាស់ពុំងា។



www.elibraryofcambodia.org

ម៉ែលាកូនទៅមិនអស់ចិត្ត ម៉ែនៅតែគិតកូនគ្រប់គ្នា
ពីថ្ងៃនេះទៅនៅកំព្រា រស់រងវេទនាគ្មានកោះត្រើយ។
កូនមកមិនទាន់ដង្ហើមម៉ែ មិនបានថ្នមថៃម៉ែសោះឡើយ
មិនបានឃើញមុខគ្រាបង្ហើយ សូម្បីចម្លើយឆ្លើយថាលា។
ពីថ្ងៃនេះទៅខានឃើញមុខ កូនដេកឱបទុក្ខពេលនិទ្រា
មិនឃើញមុខម៉ែមុនបូជា ម៉ែកូនបែកគ្នាគ្រានេះឯង។
គេហែសពម៉ែដល់ប៉ាឆា បូជាទាំងក្ការឆេះក្រៃលែង
នៅក្នុងទ្រូងកូនសែនចំបែង បានឃើញត្រឹមផ្សែងព្រះអគ្គី។
ឱ!ព្រះអគ្គីចាប់ឆាបឆេះ សពម៉ែជាផេះហ្មត់ខ្មៅចខ្មី
នៅសល់តែធាតុលើធរណី កូនៗមូលមីរឱនរើសធាតុ។
កូនរើសធាតុម៉ែដាក់ក្នុងកោដ្ឋ ដោយក្ដីក្រៃងកោតចិត្តចង្អៀត
លែងបានឃើញម៉ែតទៅទៀត ពេលនេះម៉ែឃ្លាតពីកូនហើយ។

**និពន្ធដោយ គង់ ច័ន្ទសុភ័ក្រ**



www.elibraryofcambodia.org

## ៣០.ទឹកចិត្តលោកគ្រូ

កូនរៀនពូកែម៉ែថាពីពូជ    បើកូននោះខូចថាមកពីគ្រូ
បង្ហាត់មិនកើតមិនធ្វើគំរូ    បង្រៀនយូរៗទារយកតែប្រាក់។
សិស្សខ្លះមកវៀនទៀងពេលរាល់ថ្ងៃ    សរសេរនឹងដៃរៀនលេខអក្ខរៈ
ស្តាប់គ្រូពន្យល់គឺនៅក្នុងថ្នាក់    យកចិត្តទុកដាក់ស្តាប់គ្រូបង្រៀន។
ម៉ោង៧ព្រឹកសិស្សតម្រង់ជួរ    ស្លៀកពាក់សមគួរនៅពេលចូលរៀន
គោរពទង់ជាតិប្រាណប្រុងជំហាន    មានមេប្រធានប្រាប់យើងគ្រប់គ្នា។
ក្នុងនាមសិស្សល្អគោរពវិន័យ    ទាំងប្រុសទាំងស្រីក្រេបយកវិជ្ជា
មកដាក់ក្នុងខ្លួននេះជាវេលា    ត្រូវខំពុះពារស្វែងរកគោលដៅ។
ទ្រព្យអ្វីមិនស្មើនឹងទ្រព្យចំណេះ    ដល់ពេលយើងចេះប្រាក់រត់តាមហៅ
បង្ហាត់បង្រៀនណែនាំប្រាប់ផ្លូវ    មិនចង់ឱ្យខ្លៅត្រូវខំសិក្សា។
ទាន់ខ្លួននៅក្មេងប្រឹងប្រែងខំរៀន    គ្រប់មុខរបៀននៅតាមសាលា
រៀនអានរៀនស្តាប់បង្កើនប្រាជ្ញា    ចូរខំឧស្សាហ៍ព្យាយាមប្រព្រឹត្ត។
ស្មូរជួងបន្លឺដាស់ដល់ស្មារតី    កូនខ្មែរប្រុសស្រីឱ្យមានគំនិត



www.elibraryofcambodia.org

ស្វែងរកចំណេះដាក់ក្នុងជីវិត កុំឱ្យងងឹតរហូតមរណា។

ធ្វើម្ដេចសង្គមនិយមអ្នកចេះ អ្នកមានតម្រិះគេយកធ្វើការ

អ្នកល្ងង់អ្នកខ្លៅអ្នកប្រើហិង្សា អ្នកមិនបានការយកមកធ្វើអ្វី?

សម័យឥឡូវគេបានប្តូរផ្លាស់ គំនិតចាស់ៗផ្លាស់ប្តូរជាថ្មី

វប្បធម៌បុរាណជាប្រពៃណី រក្សាទឹកដីខ្មែរឱ្យគង់វង្ស។

**និពន្ធដោយ គង់ ច័ន្ទសុត្ថ័ក្រ**



www.elibraryofcambodia.org

-ឧ.សិ អ៊ឹង មួយ...........៣០.០០០៛ ចេង យូស្រេង.ប៉ោ វណ្ណី ៨០.០០០៛
-ឧ.សិ ច្រឹង សុផល.កូន ...៣០.០០០៛ -ឧ.សិ អ៊ុំ សុជាតិ.សារឿន.៣០.០០០៛
-ឧ.សិ ពីន ឈុនហៀង .....១៥.០០០៛ -អ្នកនាង គីន ណារី.កូន . ១៥.០០០៛
-ឧ.ស ផូ អត.ហុង ស៊ីវន ...១៥.០០០៛ -អ្នកស្រី គិន វត្ថា.ស្វាមី... ១០.០០០៛
-ឧ.ស ឱក សារុណ.ភរិយា. ១០.០០០៛ -ឧ.សិទ្បេង សែហេង.......៦.០០០៛
-អ្នកស្រី ផៃ ស្រីមុំ.ស្វាមី....១០.០០០៛ -ឧ.សិ ប៊ិច.កូនចៅ...........៦.០០០៛
-អ្នកស្រី ស្រៀង.ទ្រី ហួង......៩.០០០៛ -បងស្រី ឈូក ចាន់ពៅ ..៣០.០០០៛
-ឡយ មួយ....................១៥.០០០៛ -ឡយ អេង .................. ១៥.០០០៛
-ឧ.សិ វណ្ណី ......................១៥.០០០៛ -ឧ.សិ សៀង ............... ១៥.០០០៛
-ឧ.សិ អ៊ូ សុភ័ក្រ.............១០.០០០៛ -ឧ.សិ គីម វ៉ុង .............. ១៥.០០០៛
-ឧ.សិ ម៉ា អេង .............. ១៥.០០០៛ -ឧ.សិ សុខ ទៀង.បុត្រ... ១៥.០០០៛
-ឧ.សិ រស់ សារ៉េត ..........១០.០០០៛ -ហៀង ណៃ ស៊ឹម..........៣០.០០០៛
-ឧ.ស ព្រំ វ៉ែន.ទុយ វណ្ណារី. ១៥.០០០៛ -ឧ.សិ ហ្គេក សៀង........ ១៥.០០០៛
-ទាយុ ប៉ាវ គីម ចុន ............៦.០០០៛ -ហ៊ី ផល្លី .....................៣.០០០០៛
-ឧ.សិ ឈុន ហៀង .........២០.០០០៛ -ឧ.សិ ម៉ក់.........................៦.០០០៛
-ឧ.សិ ឡៅ សម្បត្តិ .........១៥.០០០៛ -សុ ម៉ាលី..........................៦.០០០៛
-ឧ.សិ នៅ .....................១៥.០០០៛ -តា ប្រាក់ ស៊ើន ............ ១៥.០០០៛
-ហេង សុខា....................១៥.០០០៛ -ឧ.សិ ប៊ុល គីម.ស្វាមី ... ១៥.០០០៛
-ល.លុន លៀងសុខ.ភរិយា១៥.០០០៛ -តាសក ស្រ៊ុនលុន.ភរិយា១៥.០០០៛
-កញ្ញា លុន សុគន្ធទេវី ........៦.០០០៛ -ល លុន រដ្ឋាមុនី ............៦.០០០៛
-ចៃ វណ្ណា ......................១០.០០០៛ -ស្រ៊ុន សុខ ហួរ ............១៥.០០០៛



www.elibraryofcambodia.org

-ម៉េង ស្រ៊ុន ផល្លា ..........១៥.០០០៛ -ទាយិកា ប៊ុន ពៅ.........១០.០០០៛
-ឧ.សិ វ៉ាន់ គឹម ហឿន......១០.០០០៛ -ឧ.សិ ប៉ន គីម.ស្វាមី .....១០.០០០៛
-ទាយិកា ឈាន់ សំណាង .១០.០០០៛ -ទាយិកា វ៉ាន់ គីមហាន់ .....៥.០០០៛
-ឧ.សិ អាំង សៃឡា .........១០.០០០៛ -ឧ.សិ ចែ អូន ..............១០.០០០៛
-ឧ.សិ ហូ សូភី ...............១៥.០០០៛ -ឧ.សិ លាន់ ធា..............៥.០០០៛
-ឧ.សិ យៀង ស៊ីផាន.........៥.០០០៛ -ឧ.សិ ស៊ីន .................១០.០០០៛
-ឧ.សិ ម៉ៅ.ឧ.សិ យឹង ......... ៣.០០០៛ -ល.សុខ សារី.ភរិយា.កូន ១៥.០០០៛
-ឧ.សិ គឹម នាង ..............១០.០០០៛ -ល.គិន វណ្ណា.វង្ស សុភា ២០.០០០៛
-ល.គិន ណារ៉ា.ម៉ូលីកា.កូន២០.០០០៛ -ឧ.សិ ជា លី វណ្ណៈ.......... ៣.០០០៛
-ឧ.សិ ជា សារី ................ ៣.០០០៛ -ឃុន ណាង ...................៦.០០០៛
-ហុង ពុធ ....................... ៣.០០០៛ -តាំង ហៀង ....................៦.០០០៛
-លោក ខ្នាអ្នកស្រី ៣ច .......៦.០០០៛ -ឧ.សិ ឈុន វួចសៀម.... ១៥.០០០៛
-ឧ.ស កើត លីម...............១៥.០០០៛ -ឧ.សិ សេង ស៊ីហ៊ាន ...... ១៥.០០០៛
-ឧ.ស វេន សុផល .............៦.០០០៛ -ឧ.ស.ឥត ផ្លង.ឧ.សិ ភាព៣.០០០៛
-ឧ.ស.ទិព ឧ.សិ.ផុន .......... ៣.០០០៛ -ទាយុគ្រី.ឧ.សិ.ណាន ...... ៣.០០០៛

**តាមរយៈឧបាសិកា យី បូច័ន្ទ ខេត្តកំពង់ចាម**

-ឧ.សិ យី បូច័ន្ទ ............. ៣០.០០០៛ -ឧ.សិហឹម គីមហា.ស្វាមី ៣០.០០០៛
-ល.ចយ ធារិទ្ធ.ភរិយា.......១៥.០០០៛ -ឧ.សិ ច័ន្ទប៊ុនធីម.ស្វាមី..១៥.០០០៛
-ទាយិកា វុធ.....................៣.០០០៛ -អ្នកស្រី ឌី ចាន់រី ............ ៣.០០០៛
-អ្នកស្រី ឆៃ សុវត្ថារា.ស្វាមី ...៦.០០០៛ -កញ្ញា ស៊ីម ធីម ..............៦.០០០៛
-ល.វ៉ាន់ សារ៉េត.ភរិយា សុជា៦.០០០៛ -ឧ.សិ ពេជ្រ យី............. ៣.០០០៛



www.elibraryofcambodia.org

-ឧ.សិ អ៊ឹង ហ្កេកហ៊ាង.........៣.០០០៛ -អ្នកស្រី រស់ សំអឿន.ស្វាមី៦.០០០៛
-អ្នកស្រី កែវ វ៉ារី.................៣.០០០៛ -ទាយិកា សន សំអាង......៣.០០០៛
-ឧ.សិ តាន់ គីមគ្រុយ.......៣០.០០០៛ -ហម លីហេង.ឈឹមគឹមហុង...១០ក
-ឡុង គៀន.អេង ឡាំង .....១៥.០០០៛ -ចយ សុខ.អ៊ិន ណៃស៊ុ...១៥.០០០៛
វង្ស គីណាល់.ចាន់បូណ៌ាព្រឹក......២ម៉ឺន

## តាមរយៈឧបាសិកា ឌី សួរ ខេត្តបាត់ដំបង

-ឧ.សិ ឌី សួរ.......................៦.០០០៛ -យាយ រីន .......................៣.០០០៛
-បង ឡម ............................៣.០០០៛ -បង យី ...........................៣.០០០៛
-មីង ឡប ...........................៣.០០០៛ -បង នេត..........................៣.០០០៛
-ប្អូន និមល.......................៣.០០០៛ -បង លឿម .......................៣.០០០៛
-តា គីក..............................៣.០០០៛ -ក្មួយ ធី .........................៣.០០០៛
-ឧ.សិ ម៉ៅ វណ្ណី...........៣០.០០០៛ -ឧ.សិ ភិម សេត..........៥.០០០៛
-ឧ.សិ ភិម យ៉ាង ............៥.០០០៛ -ឧ.សិ លក់ផ្កាអន្លង់វិល . ៥.០០០៛
-ឧ.សិ អ៊ឹម ហ៊ាងផា ..........១២.០០០៛ -ឧ.សិ ឡឹក រ៉េត................៦.០០០៛
-ឧ.សិ ស៊ុំ នួម................ ៣០.០០០៛ -ឧ.សិ ជុំ សុភាព ...........៣០.០០០៛
-ឧ.សិ ឃុត ថន ............. ៣០.០០០៛ -ប៉ គីម លៀង ...................៩.០០០៛
-កុមារី ប៉ គីមជូ. ................ ៣.០០០៛ -កុមារា ប៉ គីមតយ........... ៣.០០០៛
-កុមារី ហ៊ុន ភាឌី.................៣.០០០៛ -យ៉ាន សុខវិសាល(BBU). ៣.០០០៛
-ឧ.សិ យ៉ាំ សុបិន្ត............ ៣០.០០០៛ -ឧ.សិ តែ ហ៊ុន..............៣០.០០០៛
-សាមណេរ ទូច.ញោមស្រី ៤០.០០០៛ -បងប្រុស ធឿន រដ្ឋា ......២០.០០០៛
-លោក អ៊ុក បេ.បុត្រ.........១០.០០០៛ -អ្នកគ្រូ ហឿនសារុំ ........ ១០.០០០៛



www.elibraryofcambodia.org

| | |
|---|---|
| -ឧ.សិ ឌី ឡូម..................១០.០០០៛ | -បងស្រី យន...................៥.០០០៛ |
| -ប្អូនស្រី ពៅ.......................៥.០០០៛ | -រិន វន្នារី.ឌុល ចន្ទសេដ្ឋា ១៥.០០០៛ |
| -ដូនជី ជា សុភី ...............១៥.០០០៛ | -ដូនជី ពេច សារឿន......១៥.០០០៛ |
| -សួន ធា.......................១៥.០០០៛ | -ឧ.សិ គូ ធារី ...............១៥.០០០៛ |
| -ឧ.សិ មុំ ស្រីទូច.ស្វាមី.កូន ១០.០០០៛ | -ឧ.សិ វិញ......................៦.០០០៛ |
| -ឧ.សិ វើន .......................៦.០០០៛ | -ឧ.សិ វិញ......................៦.០០០៛ |
| -ឧ.សិ ទ្រី...........................៦.០០០៛ | -ឧ.សិ ប៉ិច.....................៣.០០០៛ |
| -ឧ.សិ ខឹម យីម ..............១៥.០០០៛ | -ឧ.សិ ចឿង យន់............៦.០០០៛ |
| -ឧ.សិ ម៉ាក់ ភួង ..................៦.០០០៛ | -ឧ.សិ ខឹម យីម ..........១៥.០០០៛ |
| -ឧ.សិ ចឿង យន់..............៦.០០០៛ | -ឧ.សិ សំរិត កញ្ញា............៩.០០០៛ |
| -ល.ហួង ហេង.ឧ.សិ ចន្ថា ៣០.០០០៛ | -ឧ.សិ ទ្រី.កូនចៅ.........១០.០០០៛ |
| -ឧ.សិ ស្រី យ៉ា ព្រមទាំងបុត្រ៣.០០០៛ | -ល.ហ៊ា ហេង.ថៃ ផល្លី... ១៥.០០០៛ |
| -កញ្ញា សុវណ្ណារី..............១២០០០៛ | -ហុង សារិត ...............១២.០០០៛ |
| ល.គង់ ម៉េង.ខន សុរិន.កូន១២.០០០៛ | -លោក ម៉ៅ អ្នកស្រីថៃ......៦.០០០៛ |
| -អួច សុវណ្ណរត្ន័.ភរិយា ......១៥.០០០៛ | -ហុក ធីតា ..................១២.០០០៛ |
| -ឧ.សិ ឈុន សុខា ...........១៥.០០០៛ | -ឧ.សិ សាត ស៊ន .........១២.០០០៛ |
| -ឧ.សិ តាំង លៀងគាវ.កូន.១២.០០០៛ | -ឧ.សិ អ៊ឹង ស្រៀង........១២.០០០៛ |
| -ដូជី ពេជ្យ សារឿន.កូនចៅ១៥.០០០៛ | -ឧ.សិ ទន់ ពៅ.............១៥.០០០៛ |
| -ប្អូនប្រុស ធី ធីរ៉ា.អ្នកម្តាយ ១០.០០០៛ | -ឧ.សិ វង្ស សារឿន...........៦.០០០៛ |
| -ណាក់ រឿន.កូនចៅ.........១០.០០០៛ | -ឧ.សិ គ្រី.កូនចៅ ............៦.០០០៛ |
| -បងស្រី ផុក យ៉េត ..........១៥.០០០៛ | -តា អៀត យាយ រុំ...........៦.០០០៛ |



www.elibraryofcambodia.org

| | |
|---|---|
| -ស៊ិម សំណាង.សុខ សាវេត ៣០.០០០៛ | -វើន ផន ........................៦.០០០៛ |
| -ស៊ិម ចាន់ណា ...................៩.០០០៛ | -អ៊ុំ អាត ........................៣០.០០០៛ |
| -អ្នកគ្រូ វ៉ានី.ស្វាមី.បុត្រ ........៩.០០០៛ | -អ្នកគ្រូ តិច ផល្លា.ស្វាមី.បុត្រ៦.០០០៛ |
| -ឧ.សិ ឈុន សុខា ...........១៥.០០០៛ | -ឧ.សិ ឃុត ......................៥.០០០៛ |

**តាមរយៈឧបាសិកា យាងស៊ីផល ខេត្តកំពង់ចាម**

| | |
|---|---|
| -ឧ.សិ យាង ស៊ីផល.........២០.០០០៛ | -លោក អៀងធារ៉ា.ភរិយា ១០.០០០៛ |
| -ឧ.សិ លាន់ ធា ...............១០.០០០៛ | -ឧ.សិ កើត ស្រ៊ុន .......... ១០.០០០៛ |
| -ឧ.សិ ឆាយ ងិម..............១០.០០០៛ | -អ្នកស្រី យាង ស៊ីផាន.... ១០.០០០៛ |
| -ឧ.សិ ណៃ ស៊ុន ..............១០.០០០៛ | -ឧ.សិ ចេង ជីវ៉ា............. ១០.០០០៛ |
| -ឧ.ស វ៉ា ហូ .......................៥.០០០៛ | -ឧ.សិ ប៊ិន សុខយាង ........៥.០០០៛ |
| -ឧ.សិ សូ តាំងសាត............៥.០០០៛ | -ឧ.សិ ហ៊ាង ......................២.០០០៛ |
| -ឧ.សិ ក្រឹម ឡាញ់ .............២.០០០៛ | -អ្នកស្រី អាង ចន្ថា............២.០០០៛ |
| -ឧ.សិ សៀក លាវ .............៣.០០០៛ | -ឧ.សិ សយ ហ៊ាង......... ១០.០០០៛ |
| -ឧ.សិ អ៊ីម ឡូញ..................៥៥.០០៛ | -ឧ.ស អៀ គឹម ហ៊ាង ........៥.០០០៛ |
| -ឧ.សិ សុខ លី .................. ២.០០០៛ | -ឧ.ស សុខ ទុន..................២.០០០៛ |
| -ឧ.សិ យាង ស៊ីផាត............៥.០០០៛ | -ឧ.សិ ម៉ៅ ........................២.០០០៛ |
| -ឧ.សិ យិន ........................១.០០០៛ | -កុមារា ម៉ានិត.................១.០០០៛ |
| -កុមារា អយ សម្ផស្ស ..........១.០០០៛ | -កុមារី ធារា ......................១.០០០៛ |
| -កុមារី មុនីនាថ....................១.០០០៛ | ឧ.សិ ថន សុវណ្ណៈ......... ១០.០០០៛ |
| -ឧ.សិ ឡុក សាយគីម.កូន.១៥.០០០៛ | |

**តាមរយៈឧបាសិកា ខែក វិបុល.ឧបាសិកា សោម ណាត**



www.elibraryofcambodia.org

## ភូមិជប់ ឃុំជប់ ក្រុងសួង ស្រុក ត្បូងឃ្មុំ ខេត្តកំពង់ចាម

-ឧ.សិ សោម ណាត.បុត្រ..៤០.០០០៛ -ឧ.ស ម៉ាសា វ៉ន .......... ៤០.០០០៛
-ល.សេង សុក.ហ្គេច ហុង ៣០.០០០៛ -ឧ.ស ថៃ ថុល.ភរិយា ....២០.០០០៛
-ឧ.សិ នៅ អ៊ឹម ...............២០.០០០៛ -ឧ.សិ ហុង នាង .......... ១០.០០០៛
-ឧ.ស គង់ យ៉ែម .............១០.០០០៛ -ឧ.សិ ខែក វិបុល.កូនចៅ៣០.០០០៛
-ឧ.សិ សុក សារួម.កូនចៅ ៣០.០០០៛ -ឧ.សិ ឆោម ម៉ាឡា .ក្មួយ ..១៥.០០៛
-ឧ.ស ចៅ ដុង ...............១០.០០០៛ -ឧ.សិ ឈិត ណៃចេង.កូន១០.០០០៛
-ឧ.សិ ម៉ក់ គឹមហាន.កូន ...១០.០០០៛ -អ្នកស្រី ឈាន វន្នី.កូន...៣០.០០០៛
-អ្នកស្រី សុក វណ្ណា.កូន ....១០.០០០៛ - លោក ហ៊ត់ ឡាវី......... ១០.០០០៛
-ឧ.សិ ម៉ៅ ធួក.កូនចៅ .....១០.០០០៛ -អ្នកស្រី វៀម សុខាកូន .. ១០.០០០៛
-ឧ.សិ ហេង មួយហួរ..........៦.០០០៛ -ឧ.សិ ទុយ វណ្ណា ........... ៣.០០០៛
-ឧ.សិ មាស គឹមស្រាង ....... ៣.០០០៛ -អ្នកស្រី ស៊ុន ណារី .......... ៦.០០០៛
-ឧ.សិ ហ៊ី ណារុំ ..............១៥.០០០៛ -ឧ.សិ អៀន ស្រី.កូន .....៣០.០០០៛

## តាមរយៈឧបាសិកា សេត សឿន ភូមិមាន់ហើរ ខេត្តកំពង់ចាម

-ឧ.សិ សេត សឿន .........២៥.០០០៛ -ឧ.ស យី ស្រ៊ុ..............២៥.០០០៛
-ម៉េត ហល់....................២៥.០០០៛ -ហឿង គៀន................២៥.០០០៛
-ហឿន ........................២៥.០០០៛ -ខា ខេង.......................២៥.០០០៛
-ហេ គន្ធា .......................៥.០០០៛ -តា ភូមិ យាយ ចាន់ .........៥.០០០៛
-យាយ ហៀក ...............២០.០០០៛ -យាយ យាង..................២៥.០០០៛
-ថៃ គឹម ហ៊ន.....................៥.០០០៛ -ម៉េក យឹម .................. ១០.០០០៛
-យាយ អៀង .................២៥.០០០៛ -កុង ឈិន យាយ ថៃ .....២៥.០០០៛



www.elibraryofcambodia.org

| | |
|---|---|
| -យាយ វួច.....................២៥.០០០៛ | -កុង គឿន យាយ អេង...២៥.០០០៛ |
| -យាយ គ្រឿន ...............២៥.០០០៛ | -តា ឈឿន ព្រៀប........២៥.០០០៛ |
| -តា យាន យាយ សឿន.......៥.០០០៛ | -តា សឿន យាយ ស្រ៊ុន .២៥.០០០៛ |
| -តា នី យាយ ហៃ............២៥.០០០៛ | -យាយ អ៊ុក .....................៥.០០០៛ |
| -លឹម ហ៊ាន.ឡាំង អេង .....២៥.០០០៛ | -យាយ ស្រាន.............. ១០.០០០៛ |
| -តា ង៉ន.យាយ ស្រ៊ុយ....... ១០.០០០៛ | -គ្រូ ឈាន.យាយ ឡាង .២៥.០០០៛ |
| -តា ដៀន យាយ សាន .....២៥.០០០៛ | -យាយ ចី......................២៥.០០០៛ |
| -តា ឡៃ.យាយ ហេន..........៥.០០០៛ | -តា ស៊ុ.យាយ ណាក់ .......៥.០០០៛ |
| -នាង អ៊ុល សំបូរ................៥.០០០៛ | -យាយ គីម ......................៥.០០០៛ |
| -តា សឿន យាយស្រ៊ុន .....២៥.០០០៛ | -តា នី យាយ ហៃ .........២៥.០០០៛ |
| -យាយ អ៊ុក .........................៥.០០០៛ | -លឹម ហ៊ាន.ឡាំង អេង...២៥.០០០៛ |
| -យាយ ស្រាន ................ ១០.០០០៛ | -តា នីន យាយ ស្រ៊ុយ.... ១០.០០០៛ |
| -តា ដៀន យាយ សាន ....២៥.០០០៛ | -យាយ ចី......................២៥.០០០៛ |
| -តា ឡៃ យាយ ហេន..........៥.០០០៛ | -តា ស៊ុ យាយ ណាក់ .......៥.០០០៛ |
| -នាង អ៊ុល សំបូរ................៥.០០០៛ | -យាយ គីម ......................៥.០០០៛ |
| -សី ភាព...........................៥.០០០៛ | -តា ហ៊ាន យាយ អ៊ាន .......៥.០០០៛ |
| -តា អ៊ាន យាយ ម៉ៅ.........២៥.០០០៛ | -យាយ ផាន ................២០.០០០៛ |
| -គ្រូ ទិន យាយ ខេង ...........៥.០០០៛ | -គ្រូ ផុល យាយ អយ .....២០.០០០៛ |
| -យាយ ហ៊ាន .....................៥.០០០៛ | |

**ឧ.ស.ហោ ផល្លី និងឧ.សិ.ហ៊ាន់ ម៉េងហៀង ខេត្តកំពង់ចាម**

| | |
|---|---|
| -ហួន ធី.ហ៊ុន ហុធី .............៥.០០០៛ | -លៀង ហ៊ាន់.ស្រី ហៀប ...៥.០០០៛ |



www.elibraryofcambodia.org

| | |
|---|---|
| -ល.កុសល.ភរិយា ............ ៣.០០០៛ | -អ៊ុំ វ៉េត ............................ ៥.០០០៛ |
| -ស្រួច ចាន់ថុល ................. ៥.០០០៛ | -អ៊ុំ ស្ងួរ ........................ ២០.០០០៛ |
| -វង់ គឹមថូ ...................... ១៥.០០០៛ | -ល.សុធា.ស្រីនាង ............ ៥.០០០៛ |
| -ហេង ចន្ធូ ...................... ៥.០០០៛ | -ហ៊ាន់ សៀងលី ............... ៥.០០០៛ |
| -ល.ផា.អ្នកស្រី ហៀប.......... ៥.០០០៛ | -តា ហឺ យាយ រី ............... ៥.០០០៛ |
| -តឹក ផល្លា ...................... ៥.០០០៛ | -ខៃសៀងហ៊ាន់.លាតសំណាង ១០.០០០៛ |
| -នួន.ស៊ីណេត .................. ៣.០០០៛ | -តេង ហ៊ាន ..................... ៣.០០០៛ |
| -យាយ ណៃ ហួយ ............. ៥.០០០៛ | -ងឹម សៀងហេង .............. ៣.០០០៛ |
| -រិត ថេត.ថេត លាត ........... ៥.០០០៛ | -ល.អាត អ្នកស្រី សំបូរ ...... ៥.០០០៛ |
| -ម៉ៃ ស្រីម៉ៅ...................... ៥.០០០៛ | -យាយ អ៊ិន ..................... ៥.០០០៛ |
| -ល.ហ៊ុច........................... ៥.០០០៛ | -រ៉ែ គិន ........................... ៥.០០០៛ |
| -អ៊ុំ ព្រំ ............................ ៣.០០០៛ | -អ៊ុំ នឹម ........................... ៥.០០០៛ |
| -លោកម្ចាស់ យ៉ុក ចិន្តា .....១២.០០០៛ | -លោកម្ចាស់ ដៀប ឆេង .៣០.០០០៛ |
| -លឹម ទូកហេង .................. ៥.០០០៛ | -ឧ.ស.ហោ ផល្លី .......... ១៥.០០០៛ |

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមរបស់ពុទ្ធបរិស័ទ ទ្រង់ឯកឧត្តម លោកជំទាវ លោកគ្រូ អ្នកគ្រូសិស្ស និសិត្ស ចានចំណាយថវិកា ផ្ទាល់ខ្លួន បានចំណាយថវិកា ធ្វើវិភាគទាន សាងពូជបញ្ញា តាមរយៈការបោះពុម្ពនូវកូនសៀវភៅនេះ និងសៀវភៅថ្មីៗ បន្ថែមទៀត ប្រព្រឹត្តទៅក្នុងចំណែកធម្មទាន គ្មានការលក់ទិញ។ យើងខ្ញុំក្នុងក្រុមការងារទាំងអស់ សូមជូនពរអស់លោកទាំងអស់ សូមឱ្យតែសេចក្តីសុខ នឹងសេចក្តីចម្រើនគ្រប់ពេលវេលា សូមអរព្រះគុណ និងសូមអរគុណ។



www.elibraryofcambodia.org

រក្សាសិទ្ធិដោយ

CADE

MP
Printing House
រោងពុម្ព ម៉ៅ ផុន
MAO PHON PRINTING HOUSE
Tel: 077 777 800 / 088 8888 908 / 023 63 63 524
Email: phonmao@yahoo.com

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ចៅ យុនសំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ រ៉ាមុន

ខ្ចៅ ភារាដា ខ្ចៅ ចំរើន ខ្ចៅ ភារី

បាននឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្ចៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា** និង **ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **លី សិរីរត្ន**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

# សុខចិត្ត



សុខចិត្ត ធ្វើល្ងង់ចំណោមបណ្ឌិត  សុខចិត្ត ធ្វើមិត្តជាមួយអ្នកប្រាជ្ញ
សុខចិត្ត មិនស្គាល់អ្នកកោងអ្នកកាច  សុខចិត្ត ខ្លបខ្លាចចោរលួចចោរឆក់ ។
សុខចិត្ត ក្រទ្រព្យមិនក្រគំនិត  សុខចិត្ត ប្រព្រឹត្តគិតមិនកុហក
សុខចិត្ត ដើរចេញមិនធ្វើអាក្រក់  សុខចិត្ត ឲ្យស្រក់តក់ៗខំប្រឹង ។
សុខចិត្ត ចុះចាញ់ដាក់ចុះមានះ  សុខចិត្ត យកឈ្នះចិត្តដែលធ្លាប់ខឹង
សុខចិត្ត មិនផឹកនូវទឹកស្រវឹង  សុខចិត្ត ជញ្ជឹងគិតធ្វើរឿងល្អ ។
សុខចិត្ត ទៅរៀននៅតាមសាលា  សុខចិត្ត រក្សាឯកសណ្ឋានស
សុខចិត្ត ស្តាប់គ្រូមិនធ្វើមាត់ក  សុខចិត្ត ស្តាប់ធម៌ព្រះពុទ្ធអង្គ ។
សុខចិត្ត រក្សានូវពាក្យសម្តី  សុខចិត្ត ធ្វើអ្វីតាមការទៀងត្រង់
សុខចិត្ត គោរពចំពោះព្រះសង្ឃ  សុខចិត្ត កម្សង់ ផ្គុំដោយហត្ថា ។
សុខចិត្ត ធ្វើទានតាមកម្លាំងទ្រព្យ  សុខចិត្ត កាន់ខ្ជាប់មិនប្រើហិង្សា
សុខចិត្ត ស្តាប់ម៉ែទូន្មានស្តីថា  សុខចិត្ត ប្រាថ្នាចំណេះវិជ្ជា ។

ISBN-9789996331336
9 789996 331336
រោងពុម្ព ម៉ៅ ផុន
MAO PHON Printing House

www.elibraryofcambodia.org